អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២**

**ម៉ោង ០៩:០៥ នាទី**

**សវនាការលើកទី៨៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

លោក អេនឌ្រូ ចេមស៍ ម៉ាគីនថាយអ៊័រ
*(Andrew James MCINTYRE)*

លោក ស៊ីម៉ុន មេសិនប៊ឺជ
*(Mr. Simon MEISENBERG)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

កញ្ញា សុង ឆវ័ន្ត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក សាលីម ណាកចាវ៉ានី
*(Mr. Salim NAKHJAVANI )*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ *(Mr Jasper PAUW)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Mr. Arthur VERKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក ម៉ៃខល កាណាវាស

*(Mr. Michael KARNAVAS)*

លោក អាង ឧត្តម

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ហ្សាស្ពើ ប៉ៅ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អេនឌ្រូ អ៊ីនូហ្សី | អង់គ្លេស |
| លោក ដេវីដ ឆេនម័ល័រ (TCE-11) | អង់គ្លេស |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅអ្នកជំនាញ៖ លោក ដេវីដ ឆេនដ៍ល័រ** (TCE-11)

សួរបន្តដោយលោក ម៉ៃខល កាណាវាស ផ្តើមពី៖ ........................................................ ...ទំព័រ ៦

សួរដោយលោក គង់ សំអុន ផ្តើមពី៖ ....................................................................... ..ទំព័រ ៦៦

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:៥៧]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគដែលបានគ្រោងទុក កិច្ចដំណើរការពិភាក្សាដេញដោលថ្ងៃនេះ នឹងបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ដោយក្រុមមេធាវីការពារក្តី គឺក្រុមមេធាវីការពារក្តីលោក អៀង សារី ហើយនិងក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ជាបន្តនោះ សូមក្រឡាបញ្ជីលោក ឌុច ផារី ឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន។ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួន នៅខាងក្រោមសាលសវនាការ។ ជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះសម្រាប់រយៈពេលពេញមួយថ្ងៃនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីបម្រុងសម្រាប់សវនាការថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម TCW-564។ សាក្សីរូបនេះនឹងមកដល់អង្គជំនុំជម្រះនៅម៉ោងដប់ព្រឹកនេះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសូមសម្រេចលើសំណើសុំរបស់ជនជាប់ចោទ អៀង

សារី។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ ដោយនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដំណើរការពេញមួយថ្ងៃនេះ។

[០៩:០៨:៥៨]

វេជ្ជបណ្ឌិត តុង ហុង ដែលទទួលបន្ទុកពិនិត្យ និងថែទាំសុខភាពជនជាប់ចោទ នៅមន្ទីរឃុំឃាំង អ.វ.ត.ក បានបញ្ជាក់ថា ជនជាប់ចោទ អៀង សារី នៅព្រឹកនេះមានអាការៈហត់ខ្លាំងនៅពេលធ្វើចលនាបន្តិចបន្តួច។ គាត់បានផ្តល់អនុសាសន៍ថា គួរតែត្រូវបានអនុញ្ញាតឲ្យនៅតាមកិច្ចដំណើរ -- ឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោមសវនាការ ដើម្បីកាត់បន្ថយការធ្វើចលនា។

អង្គជំនុំជម្រះយល់ឃើញថា នាពេលនេះជនជាប់ចោទ អៀង សារី ដែលបានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ និងក៏អាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បានដែរ។

[០៩:០៩:៤៩]

ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ក្នុងអំឡុងពេលធ្វើសវនាការពេញមួយថ្ងៃនេះ។ បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលធ្វើសវនាការថ្ងៃនេះ។

បាទជាកិច្ចបន្ត ដើម្បីឲ្យមានភាពកាន់តែច្បាស់លាស់ថែមទៀត ហើយនិងសម្រួលដល់កិច្ចពិភាក្សាដេញដោល ដែលនឹងបន្តធ្វើដោយក្រុមមេធាវីការពារក្តីលោក អៀង សារី អង្គជំនុំជម្រះសម្រេចទៅលើបញ្ហាសំណើសុំរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ដែលបានស្នើសុំដាក់ឯកសារដេញដោលនៅចំពោះមុខសវនាការ ដែលគាត់បានស្នើឡើងកាលពីល្ងាចម្សិលមិញ។

អង្គជំនុំជម្រះសូមផ្ដល់ភារកិច្ចនេះជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ក្នុងនាមអង្គជំនុំជម្រះ ដើម្បីសម្រេច -- បញ្ជាក់ពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះលើសំណើសុំរបស់ក្រុមមេធាវីការពារក្ដីលោក អៀង សារី។ សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

[០៩:១១:២០]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ តាមសំណើកាលពីម្សិលមិញនេះរបស់មេធាវីការពារក្ដី លោក អៀង សារី បានផ្ដល់ជូនអង្គជំនុំជម្រះនូវឯកសារចម្លងនូវតារាង ដើម្បីខ្លួនយកប្រើ ដើម្បីតាំងសំណួរទៅអ្នកជំនាញ។ អង្គជំនុំជម្រះបានសម្រេចដូចខាងក្រោមនេះ៖

តារាងគឺមានឯកសារភ្ជាប់ជាមួយគឺដោយមានឯកសារអ៊ីម៉ែល តាមទស្សនៈរបស់អង្គជំនុំជម្រះនោះគឺថាខ្លួនមានពេលតិចតួចណាស់ ដើម្បីពិនិត្យឯកសារទាំងអស់នេះ ដែលបានបន្ថែមឲ្យមានការភ័ន្តច្រឡំដោយមិនបានបំភ្លឺបញ្ហានេះទេ។ បញ្ហាចំពោះមុខនេះគឺតម្រូវឲ្យភាគីដែលចង់យោងទៅរកឯកសារនោះជួបនូវបញ្ហាមួយ ដែលថាដាក់ឯកសារនេះនៅក្នុងតារាងបញ្ជីរបស់ខ្លួនច្រើនសប្ដាហ៍មកហើយ។ តុលាការនេះដំណើរការផ្អែកទៅលើឯកសារសំណុំរឿង ហើយនិងផ្អែកលើឯកសារមិនថ្មីនោះទេ។ ឯកសារដែលត្រូវយកមកប្រើក្នុងសវនាការ គប្បីតែជូនដំណឹងទៅដល់ភាគីទាំងអស់ឲ្យបានមុនអ្នកជំនាញ ឬក៏សាក្សី ចូលមកផ្ដល់សក្ខីកម្ម។

[០៩:១២:៥២]

សាស្ត្រាចារ្យ ឆេនដ័ល័រ ត្រូវបានផ្ដល់កាលវិភាគជាច្រើនខែរួចមកហើយមកដល់ពេលនេះ។ ហើយអង្គជំនុំជម្រះ -- ហើយភាគីទាំងអស់ក៏បានដឹងច្បាស់អំពីកាលវិភាគនេះដែរ។ អាស្រ័យហេតុនេះ ឯកសារណាមួយដែលត្រូវយកមកពិភាក្សា ត្រូវតែ -- សូមកែតម្រូវ គឺថាក្រុមមេធាវីការពារលោក អៀង សារី គឺចង់ពិភាក្សាឯកសារណាមួយនោះ ដែលលើកស្នើនេះគឺយឺតពេលតាមនីតិវិធី។ និយាយអំពីតារាងឯកសារ ឬក៏ព័ត៌មាននេះមិនមានស្ថានភាពជាផ្លូវការចំពោះមុខតុលាការទេ។ មិនមានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលយោងទៅរក -- សម្រាប់ការពិចារណាដែលថាអ្នកជំនាញនេះបាននិយាយហើយគាត់ថាគាត់មិនមែនជាអ្នកជំនាញខាងវិទ្យាសាស្ត្រនោះទេ។ ហេតុដូច្នេះឯកសារទាំងឡាយណាដែលអាចនឹងមានខ្លឹមសារនៅក្នុងឯកសារដែលលើកឡើងនេះ គឺថាអាចប្រើនៅក្នុងការតាំងសំណួរទៅសាក្សីនោះ ដែលទាក់ទងទៅនឹងឯកសារវិទ្យាសាស្ត្រនោះអាចនឹង គឺថាមានសារប្រយោជន៍តិចតួចចំពោះ

អង្គជំនុំជម្រះ ដោយសារថាលោកអ្នកជំនាញគាត់អះអាងថា គាត់មិនមានជំនាញផ្នែកនេះ។

[០៩:១៤:១៩]

នៅទីបញ្ចប់ នៅក្នុងខ្លឹមសារនៃអ៊ីម៉ែលដែលភ្ជាប់មកជាមួយតារាងនេះ គឺថាមានសំណើដែលត្រូវបានបដិសេធរួចហើយ។ អង្គជំនុំជម្រះមិនចាំបាច់បញ្ជាក់ពីមូលហេតុ ឬក៏ឯកសារទាំងអស់នោះដែលត្រូវបានបដិសេធនោះទេ ហើយមិនអាចយកមកប្រើដើម្បីតាំងសំណួរក្នុងវិធីណាមួយចំពោះសាក្សីនោះទេ។ នេះគឺសេចក្តីសម្រេចទាក់ទងនឹងបញ្ហានេះ ទាក់ទងទៅនឹងភាពបន្ទាន់ដែលអង្គជំនុំជម្រះដែលត្រូវសម្រេចជាបន្ទាន់នេះ។ ហើយបើសិនជាលោក លោកស្រីចៅក្រមចង់បំភ្លឺអ្វីសូមមេត្តាអញ្ជើញ។

សូមអរគុណលោកប្រធាន។

[០៩:១៥:០៥]

**ប្រធានអង្គជំនុំ៖**

បាទ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរ សូមអរគុណលោកប្រធាន ហើយសូមជម្រាបសួរលោក លោកស្រីចៅក្រមភាគី និងសាធារណជនទាំងអស់ ហើយនិងសាស្ត្រាចារ្យ ឆេនឌ័ល័រ មុននឹងចូលដល់ការសួរសំណួរ។ ខ្ញុំចង់បំផ្លាញនៅក្នុង -- អ៊ំ! បំភ្លឺនៅក្នុងប្រតិចារឹកគឺថា តារាងនេះយើងមានគោលបំណងគឺថា យើងមិនចាត់ទុកថាជា -- សូមចាត់ទុកជាភស្តុតាងទេ គឺគ្រាន់តែប្រើដើម្បីជាបង្អែកនូវការតាំងសំណួរជាវិធីសាស្ត្រដែលគេប្រើទូទាំងពិភពលោកនៅក្នុងសាលាក្តីផ្សេងៗ។ ហើយខ្ញុំមិនយល់ច្បាស់អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះថា យើងខ្ញុំមិនអាចប្រើ ឬក៏សំណើនេះមិនសមស្របនោះទេ។

[០៩:១៦:០០]

ហើយឯកសារ១០ហ្នឹង គឺថាមានប្រាំមួយគឺត្រូវបានដាក់ជូនហើយ គឺថាមានឯកសារថ្មីតែបួនទេដែលយើងប៉ុនប៉ងនឹងប្រើ។ ឯកសារទាំងអស់ហ្នឹង ខ្ញុំសូមដាក់ជូនហ្នឹងគឺថាជាឯកសារដែលលោកអ្នកជំនាញបានលើកឡើង។ ចំណុចមួយទៀត គឺថាលោកអ្នកជំនាញគាត់ថា គាត់មិនមែនជាអ្នកប្រជាសាស្ត្រទេ។ ចំណុចដែលគាត់អនុវត្ត ឬក៏ធ្វើឆ្លើយនោះ គឺអនុញ្ញាតឲ្យខ្ញុំធ្វើបែបនោះ ហើយខ្ញុំនឹងប៉ុនប៉ង

នឹងសួរសំណួរមួយចំនួននៅក្នុងផ្នែកនេះ ដើម្បីបង្ហាញថា -- ប្រសិនបើយើងចង់មើលភស្តុតាងនេះ ឯកសារដែលអ្នកជំនាញបានសរសេរឡើងហ្នឹង គឺគាត់យោងទៅរកចំណុចមួយដែលថា មិនមានប្រភពឯកសារសម្រាប់គាត់យោងនោះទេ។ ខ្ញុំចង់ឲ្យតុលាការកត់ត្រា ខ្ញុំបញ្ចប់សិនសឹមលោកជំទាស់ -- គឺថាការអះអាងរបស់គាត់ គឺថាមិនមានយោងទៅរកឯកសារជាក់លាក់ទេ។

[០៩:១៧:០០]

សំណួររបស់ខ្ញុំមិនមែនថា គាត់មិនមែនជាអ្នកជំនាញខាងប្រជាសាស្ត្រ ខ្ញុំចង់សួរថា តើគាត់បានតួលេខហ្នឹងមកពីណា? ឥឡូវនេះ ខ្ញុំចង់ស្តាប់មតិជំទាស់របស់ភាគីខាងសហព្រះរាជអាជ្ញា។

**លោក អាប់ឌុលឡាក់ ថារីក៖**

នេះជាវិធីសាស្ត្រមួយដែលយើងបានឃើញភាគីមេធាវីការពារលើកឡើងជាញឹកញាប់ ហើយគឺអង្គជំនុំជម្រះបានសេចក្តី -- ចេញសេចក្តីសម្រេចហើយគឺ មិនបាច់ស្នើសុំឲ្យតុលាការកត់ត្រាទេ គឺមាននៅក្នុងប្រតិចារឹកហើយ ហើយដូច្នេះមេធាវីការពារគប្បីតែគោរពសេចក្តីសម្រេចហ្នឹង ហើយបន្តតាមនីតិវិធី។

[០៩:១៧:៤៥]

**លោក ម៉ៃខល កាណាវាស៖**

នេះជាករណីហើយនៅក្នុងដែលលោកយល់ ដូច្នេះហើយយើង -- ពេលខ្លះយើងទទួលពាក្យថាយើងមិនបានត្រៀមរៀបចំ ហើយចាត់ទុកថាយើងធ្វើការងារមិនត្រឹមត្រូវ។ ហើយការបញ្ជាក់បែបនោះគឺថា និយាយមិនត្រឹមត្រូវអំពីអ្វី ពីការងាររបស់យើងជាភារកិច្ចសាធារណៈ ដើម្បីការពារក្តីនោះ--

**ប្រធានអង្គជំនុំ៖**

លោកមេធាវី លោកបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ អង្គជំនុំជម្រះបានសម្រេចលើសំណើសុំរបស់លោករួចហើយ។ នេះជាឱកាសក្នុងការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសម្រេចទាំងឡាយរបស់អង្គជំនុំជម្រះបានចេញរួចហើយពាក់ព័ន្ធនឹងឯកសារទាំងឡាយដែលត្រូវដេញដោលចំពោះមុខអង្គជំនុំជម្រះ។ ឯកសារដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះ និងឯកសារដែលមិនបាន -- ថ្មីដែលមិនបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ វិធីសាស្ត្រក្នុងការសួរដេញដោលតាមសេចក្តីណែនាំដែលអង្គជំនុំជម្រះបានជម្រាបជូនរួចហើយ។

[០៩:១៨:៤៥]

សង្ឃឹមថា លោកមេធាវីមិនឆ្លៀតឱកាសនេះ ដើម្បីធ្វើសេចក្ដីថ្លែងការណ៍អ្វីផ្សេងៗនាំឲ្យបាត់បង់ពេលវេលានោះទេ។

**ការតាំងសំណួរបន្តដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោក ឆេនដ៍ល័រ ពីម្សិលមិញលោកបាននិយាយថា លោកបានអានការសិក្សាមួយអំពីរបាយការណ៍ប្រជាសាស្ត្រដោយ *ផាទ្រីក ផៅវ៉ែរឡាញ* នោះ ខ្ញុំអាចអានឈ្មោះនេះខុស -- ក្នុងការពិនិត្យមើលឯកសារពិសេសនោះ គឺខ្ញុំមើលឃើញថាឯកសារនោះបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៩៨ តើយើង -- លោកយោងទៅរកការសិក្សាដូចគ្នាហ្នឹងដែរឬទេ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** បាទ មានតែមួយហ្នឹងទេ ដែលខ្ញុំដឹងនោះ។

[០៩:១៩:៣៨]

**ស៖** ឥឡូវនេះ មុនឆ្នាំ១៩៩៨ លោកបានអាន សរសេរក្នុងឱកាសមួយចំនួន ជាពិសេសនៅក្នុងឆ្នាំ១៩៩១, ៩២, ៩៤ ហើយក្រោយមកលោកក៏បានសរសេរ ដែលនៅក្នុងនោះ ការបោះពុម្ពផ្សាយរបស់លោក លោកបានៗបានកំណត់ចំនួនមនុស្សស្លាប់ខុសៗគ្នាមួយចំនួន ដែលថាមានចំនួនពី១លាន ជាង១លាន ឬក៏ មួយចុច -- ១ ក្នុងចំណោម ៨នាក់, ១ ក្នុងចំណោម ៧នាក់។ នៅក្នុងឆ្នាំ១៩៩៩ លោកនិយាយថា ១លានកន្លះ មនុស្សស្លាប់នោះ។ ហើយក្រោយមក គឺលោកបានសរសេរបានមានមនុស្សស្លាប់ជាង២លាននាក់។ ហើយលោកក៏បានធ្វើការប៉ាន់ប្រមាណអំពីការសម្លាប់ដោយឃោរឃៅ គឺមាន ១០.០០០ ឬក៏ច្រើនម៉ឺន ហើយខ្ញុំមើលការបោះពុម្ពផ្សាយរបស់លោកជាច្រើននោះ ខ្ញុំមើលឃើញថាជាពិសេសពីដំបូងនោះ គឺលោកបានកំណត់យកតួលេខ ហើយលោកមិនបានយោងទៅលើប្រភពដើម្បីកំណត់ចំនួននោះទេ។ ម្សិលមិញលោកបាននិយាយថា លោកមិនមែនជាអ្នកប្រជាសាស្ត្រទេ។ តើលោកអាចពន្យល់ប្រាប់ខ្ញុំបានទេ ថាតើលោកបានតួលេខហ្នឹងបានពីណា ដើម្បីឲ្យអង្គជំនុំជម្រះគឺថាអាចនឹងយល់បានថា តើលោកប្រើវិធីសាស្ត្រអ្វី ដើម្បីកំណត់យកតួលេខនេះទាក់ទងនឹងការងារប្រវត្តិសាស្ត្រដែលលោកបានធ្វើការស្រាវជ្រាវមុននឹងសរសេរ? សូមលោកជម្រាបប្រាប់ខ្ញុំថា តើលោកបានតួលេខហ្នឹងតាមវិធីសាស្ត្រអ្វី?

[០៩:២១:២៦]

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

**ឆ៖** សូមអរគុណ។ ខ្ញុំសង្ឃឹមថា តួលេខខុសៗគ្នានេះគឺថា -- ដែលថា ចេញមកពីលើសពី ១លាននេះ គឺក្នុងឆ្នាំ១៩៩១ ដែលខ្ញុំមកកម្ពុជាហ្នឹង គឺថាខ្ញុំកំណត់ថា ១.៥លាន ឬក៏លើសពីហ្នឹង ហ្នឹង គឺផ្អែកទៅលើការសិក្សាប្រជាសាស្ត្រដែលខ្ញុំបានក្នុងពេលដែលការសិក្សា។ ខ្ញុំសូមទោស ដែលខ្ញុំមិនបាន យោងតួលេខហ្នឹង អ្វីដែលលោកបានយោងហ្នឹងទេ របាយការណ៍នោះ។ ហើយខ្ញុំកំណត់មើលឯកសារ ផ្អែកលើឯកសារមួយចំនួន គឺថាឯកសារភាគច្រើនដែលលោកបានយោងហ្នឹង ខ្ញុំមិនបានឃើញថា តើអ្វី ជាឯកសារនោះ ខ្ញុំភ្ញាក់ផ្អើលដែលមិនអនុញ្ញាតឲ្យខ្ញុំពិនិត្យមើលកាលពីមុននោះ ហើយខ្ញុំ -- ហើយមាន អត្ថបទអ្នកសារព័ត៌មាននៅក្នុងលេខយោងរបស់ខ្ញុំ ហើយដូចជា អេរវីនីន ហើយ ស្ទីវីនស្ទី ជារបាយ-ការណ៍របស់ប្រជាសាស្ត្រ ហើយខ្ញុំស្របយកចំនួននោះ គឺថាខ្ញុំមិនមានមោទនភាព គឺថា ហើយចំនួន នេះគឺថា អ្នកប្រជាសាស្ត្របានបែបនោះ គឺថាមិនជាក់ច្បាស់ទេ ក៏ប៉ុន្តែគឺថាជាចំនួនប៉ាន់ប្រមាណ ហើយប្រសិនបើលោកសួរខ្ញុំទាក់ទងទៅនឹងការសិក្សាប្រវត្តិសាស្ត្រផ្សេងទៀត គឺខ្ញុំអាចឆ្លើយបានតែ ប៉ុណ្ណឹង។

[០៩:២២:៤៧]

**ស៖** មួយខ្ញុំមិនយោងទៅរកការចុះផ្សាយរបស់អ្នកសារព័ត៌មាន ឬក៏ទស្សនៈរបស់សារព័ត៌មាន ឬសេចក្ដីសន្និដ្ឋានសាធារណៈទេ ប៉ុន្តែខ្ញុំយោងទៅរកស្នាដៃជាបញ្ញវន្តខាងថ្នាក់បណ្ឌិតរបស់លោកជាអ្នក ប្រវត្តិវិទូ ហើយថាតើប្រវត្តិវិទូហ្នឹងអាចធ្វើការសន្និដ្ឋានដោយមិនផ្អែកទៅលើប្រភពផ្សេងៗ ដូចជា មិនដឹងថាឯកសារប្រភពណាមួយជាបង្អែក ប៉ុន្តែលោកអាចសន្មតថាចំនួនមនុស្សស្លាប់ប៉ុណ្ណេះ ប៉ុណ្ណោះ ដូចដែលលោកបញ្ជាក់ហ្នឹងដែរឬទេ? ឧទាហរណ៍ថា លោកមានឋានៈជាប្រវត្តិវិទូដែលមានជំនាញខ្ពស់ ខាងប្រវត្តិសាស្ត្រកម្ពុជា លោកអាចធ្វើអ៊ីចឹង ឬក៏យ៉ាងណា?

[០៩:២៣:៣៦]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយ មាន -- ក្បាលមីក្រូៗ អត់ទាន់ប្រតិបត្តិការទេ លោកអ្នកជំនាញកុំ អាលទាន់ឆ្លើយ។

**លោក លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** បាទ គឺជាការអនុវត្ត ប៉ុន្តែឯកសារមួយចំនួនគឺដូចជាដីការបស់តុលាការ។ ខ្ញុំមិនអាច សរសេរឯកសារ៣០០ទំព័រ មានជើងទំព័រ១ពាន់ជាងនោះទេ។ ប៉ុន្តែខ្ញុំត្រូវតែពិនិត្យមើលនៅពេលដែល

ខ្ញុំគប្បីតែយោងទៅរកប្រភពទាំងអស់នេះ។ ហើយខ្ញុំឃើញថាតួលេខហ្នឹង គឺថាវាផ្ទុះបញ្ចាំងពីអ្វីដែលខ្ញុំសរសេរ អ្វីដែលខ្ញុំបានជម្រាបលោកពីម្សិលហើយ ពីប្រភពទាំងឡាយដែលខ្ញុំបានយោងនោះ។

**ស៖** ខ្ញុំមានសំណួរពីរបីទាក់ទងរឿងនេះ ខ្ញុំនឹងបញ្ចប់។ ហើយខ្ញុំពិនិត្យមើលចំណុចមួយ។ លោកជាអ្នកប្រវត្តិវិទូ មិនមែនជាអ្នកប្រជាសាស្ត្រទេ ហើយលោកបានកំណត់តួលេខបែបនេះ ហើយលោកមិនបញ្ជាក់ថា យកប្រភពមកពីណាទេ ហើយលោកអះអាងថា លោកបានពិនិត្យមើលអ្នកផ្សេងៗទៀតគេបានធ្វើ ហើយលោកនិយាយពីការសិក្សាមួយនៅឆ្នាំ១៩៩៨ របស់អ្នកប្រជាសាស្ត្រ គឺថាមានអ្នកជំនាញម្នាក់មកពីបារាំង ដែលធ្វើការនេះពីមុនមក។ តើអ្វីដែលធ្វើឱ្យលោកទុកចិត្ត ដែលថាអ្វីដែលគេផលិតនោះ គឺពិតជាត្រឹមត្រូវ ហើយអាចទុកចិត្តបាននោះ។

[០៩:២៥:១២]

ប្រសិនបើលោកជាអ្នកវិទ្យាសាស្ត្រ នៅក្នុងសក្ខីកម្មនេះ គឺលោកបានពិភាក្សាជាមួយពួកគាត់ដើម្បីឱ្យដឹងថានីតិវិធី ឬក៏បែបបទម៉េចដែលនាំឱ្យអ្នកវិទ្យាសាស្ត្រនោះ គេឈានដល់សេចក្តីសន្និដ្ឋាននោះ។ តើលោកអាចជម្រាបបានឬទេ?

**ឆ៖** ប្រភពហ្នឹងពី អេសវីលៀន នោះគឺថាបានយោងនៅក្នុងអត្ថបទសារព័ត៌មាន។ ខ្ញុំមិនបានត្រៀមដើម្បីសុំនូវលេខយោងរបស់ពួកគាត់នោះទេ។ ខ្ញុំ -- បើខ្ញុំឆ្លល់ គឺខ្ញុំមិនដែលសុំរកលេខយោងនោះទេ ខ្ញុំផ្អែកលើអ្វីដែលគេចុះផ្សាយនោះឯង គឺថាមានសៀវភៅពីរ។ ខ្ញុំនឹងរកនៅក្នុងសៀវភៅទាំងពីរនេះការសិក្សាពីរ ហើយនិងមានអត្ថបទសរសេរ។ ខ្ញុំមិនឃើញភស្តុតាងណាផ្ទុយពីហ្នឹងដែលគួរឱ្យជឿបាននោះទេ ខុសពីហ្នឹង។ ប្រភពទាំងអស់នេះ ខ្ញុំអាចនិយាយបានញឹកញាប់ គឺថាខ្ញុំសូមសោកស្តាយដែលថាតួលេខនោះ គឺថាគេមិនដឹងច្បាស់តួលេខពិតប្រាកដទេ។ គឺមានជំរឿននៅក្នុងឆ្នាំ៦២ ហើយ១៩៩៨ ហើយពេលនោះគឺថាអ្នកវិទ្យាសាស្ត្រ ហើយនិងអ្នកកាសែតតែងតែសរសេរផ្អែកលើការសន្និដ្ឋានតែប៉ុណ្ណោះ។ ហើយតួលេខនៅក្នុងឆ្នាំ១៩៦២ អាចប្រើជាតួលេខគោល ហើយនិងឆ្នាំ១៩៩៨ ជាៗតួលេខគោលដើម្បីសេចក្តីសន្និដ្ឋាន ហើយគេផ្អែកទៅលើចំនួនគោលនេះ ដើម្បីសន្និដ្ឋាន។

[០៩:២៦:៤៣]

**ស៖** ដូច្នេះតើប្រភពដែលពួកគាត់ប្រើជាមូលដ្ឋានហ្នឹង តើលោកបានដឹង លោកនឹកឃើញទេ? ពួកគេបានប្រាប់លោកទេ?

**ឆៈ** *ណូ* ខ្ញុំមិនបាន -- មិននឹកឃើញទេ។ ខ្ញុំបានឃើញអត្ថបទសារព័ត៌មានជាញឹកញាប់ ពីកាលមុន ប៉ុន្តែខ្ញុំមិនចាំថាឃើញប្រភពនោះទេ។

**សៈ** នៅៗក្នុងបញ្ជីបោះឆ្នោតឆ្នាំ១៩៩២ តើលោកបានពិនិត្យឃើញទេថា ចំនួនប្រជាជនមានចំនួនប៉ុន្មាននោះ?

**ឆៈ** ខ្ញុំមិនបានឯកសារទេ ពីព្រោះថាពេលខ្លះ គឺថាចំនួនគឺថាវាអាចផ្ទុយពីអ្វីដែលគេសន្និដ្ឋានពីមុន។

**សៈ** ឥឡូវនេះ ខ្ញុំនឹងចូលដល់ប្រធានបទមួយផ្សេងទៀត ហើយយើងនឹងចំណាយពេលសមល្មមអ្វីដែលលោកបានប្រាប់យើងនៅទីនេះ នៅក្នុងតុលាការនោះ ខ្ញុំមិនគិតថា ខ្ញុំត្រូវយោងទៅរកឯកសារដែលមិនស្ថិតនៅក្នុងសំណុំរឿង ឬក៏មិនបានដាក់ជូនតុលាការដើម្បីគោលបំណងដេញដោលនោះទេ។

[០៩:២៧:៥២]

ខ្ញុំអាចពិនិត្យមើលទំព័រមួយចំនួនបើសិនជាចាំបាច់។ ហើយខ្ញុំនឹងសួរឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ផ្អែកទៅតាមចម្លើយដែលលោកបានឆ្លើយនោះឯង។ ហើយចាប់ផ្តើម ខ្ញុំនឹងចាប់ផ្តើមថ្ងៃទីមួយ ដោយសារតែយើងមិនមានឯកសារជាភាសាខ្មែរ ឬក៏បារាំងទេ ឥឡូវនេះ គឺថាខ្ញុំនឹងជូនតុលាការជ្រាបអំពីទំព័រ ហើយនិងពេលដែលលោកបានឆ្លើយ ដែលយើងអាចរកឃើញចម្លើយដែលលោកបានឆ្លើយនៅថ្ងៃទីមួយ។ នៅចំណុចមួយនោះ នៅទំព័រ២៤ នៅថ្ងៃទីមួយ ដែលលោកបានមកឆ្លើយ។ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ គឺបន្តិចបន្ទាប់ពីម៉ោង ១០:០២:១១ ដែលនិយាយពី "ផែនការ ប៉ុល ពត ទៅអនាគត"។ "លោកសុំឲ្យលោកឆ្លើយ ថាអ្នកណាជាអ្នករៀបចំឯកសារនោះ?" នៅក្នុងសំណួរនោះលោកបានឆ្លើយថា "លោកមិនអាចបញ្ជាក់បានទេ ក្រៅពីមានឯកសារមួយនោះ។ ខ្ញុំមិនអាចថាអ្នកណាជាអ្នករៀបចំឯកសារ ហើយខ្ញុំធ្វើការស្មាននៅចំណុចមួយចំនួន។" ហើយនៅពេលដែល -- ពេលនោះលោកនិយាយថា "ប៉ុល ពត ឃើញឈ្មោះ ប៉ុល ពត នៅលើឯកសារនោះ"។ តើលោកនៅចាំថា លោកបានឆ្លើយអ៊ីចឹងទេ?

[០៩:២៩:៣៥]

**ឆៈ** បាទ។

**សៈ** នៅពេលដែលលោកនិយាយថា "ខ្ញុំស្មាន" តើលោកធ្វើសេចក្តីសន្មតទេក្នុងឋានៈជាប្រវត្តិវិទូនោះ កាលណាលោកនិយាយបែបនេះ?

**ឆ៖** បាទ។

**ស៖** បន្ទាប់មកនៅទំព័រ២៦ នៅចំពីក្រោមពេល ១០:០៥:៤២ លោកបានបញ្ជាក់ថា លោកមិនបានដឹងថាមានឯកសារចំនួនប៉ុន្មានទេ នៃឯកសារដែលបានផ្ញើជូនទៅកន្លែងផ្សេងៗនោះ។ លោកបាននិយាយថា នៅទំព័រ២៦ បន្ទាត់១៣ ដល់១៦ នៃប្រតិចារឹក គឺថាមានឯកសារ ១០ ឬ១៥ ដែលត្រូវបានរៀបចំឡើងនៅពេលប្រជុំនីមួយៗនោះ។ តើលោកបានតួលេខ១០ ទៅ១៥ច្បាប់ នៃកំណត់ហេតុអង្គប្រជុំហ្នឹង តើលោកបានមានចំណេះដឹង ឬសាក្សីអ្វីបញ្ជាក់ច្បាស់ពីរឿងហ្នឹង ឬក៏លោកសន្មតទេ?

**ឆ៖** នេះមិនមានជាការងារស្មានទេ គឺថាឯកសារហ្នឹងគឺមានបញ្ជីអ្នកដែលត្រូវទទួលឯកសារនេះ គឺថាមានឯកសារនោះចំនួន គឺថាមានប្រាំមួយ ប្រាំពីរ ឬ១០ គឺមិនមែនជាឯកសារចំហរទេ គឺថាខ្ញុំមិននិយាយស្មានទេ គឺថាមានអ្នកចូលរួមមានកំណត់ គឺថានៅចុងឯកសារ គេបញ្ជាក់អ្នកត្រូវទទួលមានប្រាំមួយ ប្រាំពីរនាក់។ នេះគឺជាសមាជិកនៃគណៈអចិន្ត្រៃយ៍ដែលត្រូវទទួលនោះបាទ។

[០៩:៣១:១៤]

**ស៖** ឥឡូវនេះយើងបន្តទៀត ខ្ញុំសូមឲ្យមានការបញ្ជាក់បំភ្លឺ គេសួរលោកអំពីយថាភាពនៃឯកសារជាពិសេសគឺសេចក្តីសម្រេចរបស់គណៈមជ្ឈិម ហើយលោកនិយាយថានៅទំព័រ២៨ គឺប្រហែលជានៅពេល ១០:០៨:០៤ ហើយនៅពេលនោះលោកនិយាយថា "ខ្ញុំទាយ ខ្ញុំស្មាន"។ ដូច្នេះ ថាលោកនិយាយថាតាមការស្មានរបស់លោក គឺថានេះគឺជាឯកសារដែលមានយថាភាព។ ដូច្នេះតើលោកព្យាយាមឆ្លើយនូវចម្លើយនេះ នៅពេលដែលលោកនិយាយថា ខ្ញុំស្មានអំពីការសន្និដ្ឋាន? តើការសន្និដ្ឋានរបស់លោកនោះគឺជាការស្មាន តើមែនទេ?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

សាក្សីកុំ -- អ្នកជំនាញកុំអាលទាន់ឆ្លើយតប! ចាំស្តាប់សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាជាមុនសិន។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

បញ្ហាគឺថា អ្នកជំនាញបានផ្តល់នូវពាក្យមួយចំនួន ដែលក្រៅបរិបទ ហើយអាចនិយាយឲ្យបានលម្អិត។ ប្រសិនបើយើងមើលទៅលើទំព័របន្តទៀត គឺថាយើងអាចនឹងឃើញថា ប្រសិនបើយើងអាននូវការដកស្រង់ទាំងមូល គឺមានន័យថា ការបញ្ជាក់ ឬក៏ការសន្និដ្ឋានរបស់លោកសាស្ត្រាចារ្យ គឺច្បាស់

លាស់ណាស់ មិនមែនជាការស្មាន ឬក៏ជាការទាយនោះទេ។ ដូច្នេះហើយ យើងអាចមើលឃើញប្រសិនបើយើងមើលទាំងស្រុងតែម្តង យើងនឹងឃើញថាតើគាត់នឹងទាយស្មាន ឬក៏គាត់ទាញសន្និដ្ឋានបានយ៉ាងដូចម្តេច ដែលច្បាស់លាស់។

[០៩:៣៣:០១]

ដូច្នេះបើសិនយើងនិយាយតែមួយបន្តិច ឬក៏យកតែមួយបន្តិចហ្នឹង គឺវាហាក់ដូចជាការទាយស្មាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំរីករាយ ដែលធ្វើការកែ ឬក៏ផ្លាស់ប្តូរនូវសំណួររបស់ខ្ញុំ។ ឥឡូវនេះ ខ្ញុំសូមនិយាយអំពីចម្លើយរបស់លោក។ ខ្ញុំមិនមានបញ្ហា ឬក៏ខ្ញុំមិនមានការឆ្ងល់អំពីយថាភាពនៃឯកសារនោះឡើយ ហើយខ្ញុំក៏មិនមានការឆ្ងល់អំពីការសន្និដ្ឋានដែលកើតឡើងនោះឡើយ។ ហើយយើងអាចនិយាយបានថាឯកសារនេះត្រូវបានគេកែប្រែ ឬក៏យ៉ាងណានោះ។ ខ្ញុំមិនដឹងថាឯកសារហ្នឹងមកពីណានោះទេ។ ខ្ញុំមិនគិតថាឯកសារនេះត្រូវបានគេកែប្រែផ្លាស់ប្តូរនោះឡើយ។ ដូច្នេះតាមការទាយស្មានរបស់ខ្ញុំ គឺថា ការសន្និដ្ឋានរបស់ខ្ញុំ គឺថា ឯកសារនេះវាមានយថាភាព ដែលត្រូវបានរក្សាទុក។ ខ្ញុំមិនមែននិយាយថា លោកទាយស្មាននោះទេ។ ហើយបន្ទាប់មកលោកនិយាយថា សន្និដ្ឋាន។ ថាតើការសន្និដ្ឋានរបស់លោកនេះ ជាការទាយស្មាន ឬមួយក៏យ៉ាងម៉េចដែរ? ខ្ញុំគ្រាន់តែចង់ឲ្យលោកបញ្ជាក់ ថាតើការសន្និដ្ឋានរបស់លោកនេះជាការទាយស្មានយ៉ាងម៉េចដែរ?

[០៩:៣៤:២១]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំបាននិយាយរួចទៅហើយថា ខ្ញុំមិនមែនមានន័យថា ការស្មាន ឬការសន្និដ្ឋានទេ ខ្ញុំបានបញ្ជាក់នៅពេលនោះរួចអស់ទៅហើយ។

**ស៖** ខ្ញុំមិនច្បាស់ ថាតើលោកឆ្លើយនេះចង់មានន័យយ៉ាងម៉េចដែរ? តើលោកចង់និយាយថាសេចក្តីសន្និដ្ឋានរបស់លោកជាការទាយស្មាន ឬមួយក៏វាជាបញ្ហានៃការនិយាយស្តីរបស់លោក? ហើយខ្ញុំសូមទោសផង ប្រសិនបើលោកតុលាការមានបញ្ហាអ្វី។ ប៉ុន្តែអានេះគឺជាការដែលខ្ញុំត្រូវដេញដោល។

**ឆ៖** ហើយខ្ញុំសូមទោស ប្រសិនបើខ្ញុំនិយាយមិនច្បាស់ ព្រោះថាខ្ញុំមិនមានអារម្មណ៍រីករាយជាមួយនឹងបញ្ហាទាំងអស់នេះទេ។ ព្រោះថាលោកហាក់ដូចជាដាក់សម្ពាធមកលើខ្ញុំ។ កិច្ចដំណើរការនីតិ

វិធី គឺថាឯកសារ ឬក៏សេចក្ដីប្រកាសហ្នឹង គឺមានមូលដ្ឋាននៃការសន្និដ្ឋានរបស់ខ្ញុំ។ ខ្ញុំមិនមែននិយាយថា ខ្ញុំចោទប្រកាន់ ឬក៏ខ្ញុំអ្វីនោះឡើយ។ ខ្ញុំប្រើប្រាស់ពាក្យ "ទាយ" គឺនៅពេលដែលខ្ញុំនិយាយ នៅពេលដែលគេនិយាយ ខ្ញុំប្រើពាក្យ "ទាយ" ក៏ប៉ុន្តែនៅពេលដែលគេសរសេរ ខ្ញុំប្រើពាក្យ "សន្និដ្ឋាន"។ ដូច្នេះអ្វីដែលខ្ញុំនិយាយពីពេលមុន គឺថាខ្ញុំចង់និយាយថា ខ្ញុំសន្និដ្ឋាន គឺមិនមែនទាយនោះទេ។

**សៈ** ប្រហែលជាខ្ញុំត្រូវពន្យល់បញ្ជាក់បន្ថែមទៀត ព្រោះថាកំណត់ត្រា ឬក៏ប្រតិចារឹកគឺគេនិយាយអ៊ីចឹង។ ដូច្នេះយើងមិនមានសិទ្ធិ ឬក៏យើងមិនអាចមានឱកាសណាមួយដើម្បីធ្វើការទាយ ឬក៏ស្មានកាត់យល់ទៅប្រតិចារឹកនោះឡើយ។ ដូច្នេះអានេះគឺជាអ្វីដែលខ្ញុំយល់ឃើញ។

[០៩:៣៦:០០]

បន្ទាប់មកទៀតនៅទំព័រទី៣០ គេសួរ -- អ៎ ចៅក្រម ខាតរាយច៌ បានសួរសំណួរទៅលោក ហើយសំណួរនេះ គឺនៅក្រោមម៉ោង ១០:១៣:៥១ គឺជាឯកសារដដែល ដែលរាយការណ៍អំពី -- រាយការណ៍ទៅមន្ទីរ៨៧០ ហើយក៏និយាយអំពីផែនការដើម្បីផលិតបីតោនក្នុងមួយហិកតា។ ហើយបន្ទាប់សំណួរបានចោទសួរថា៖ "នៅក្នុងការស្រាវជ្រាវរបស់លោក ថាតើលោកមានមើលឃើញ ថាតើគោលនយោបាយនេះត្រូវបានគេអនុវត្តនៅក្នុងសម័យនោះដែរឬទេ?" ហើយបន្ទាប់មកទៀតគឺសួរថា៖ "រហូតទៅដល់ចុង -- រហូតទៅដល់ឆ្នាំមួយពាន់ប្រាំបួនរយ -- រហូតទៅដល់ពាក់កណ្ដាលឆ្នាំ១៩៦៧ តើមានការអនុវត្តផែនការនេះដែរឬទេ?" ហើយចម្លើយរបស់លោកគឺមាននៅទំព័រ៣១ គឺដប់ -- ម៉ោង ១០:១៥ ហើយលោកបានឆ្លើយថា៖ "ជាទូទៅ គឺ ប៉ុល ពត គឺនៅក្នុងសៀវភៅដែលថា ប៉ុល ពត ធ្វើផែនការសម្រាប់អនាគតហ្នឹង គឺថាមានតែមនុស្សមួយក្រុមនៅក្នុងគណៈកម្មការនោះទេ ដែលធ្វើការសម្រេច ហើយវាជាការដឹកនាំដែលមានលក្ខណៈជាសមូហភាព ហើយការដឹកនាំនេះវាមានលក្ខណៈហាក់ដូចជាការរួមគ្នា។" ហើយលោកបានរៀបរាប់បន្តទៅទៀត ហើយលោកបាននិយាយថា៖ គឺថា -- គឺនៅម៉ោង ១០:១៦:៤៩ "ហើយខ្ញុំបានប្រមូលផ្ដុំពីដីកាដំណោះស្រាយ ដែលខ្ញុំបានអាន ហើយនៅក្នុងដីកាដំណោះស្រាយនោះ គឺខ្ញុំទទួលបានព័ត៌មានដែលបង្ហាញថា វាជាសេចក្ដីសម្រេចរបស់គណៈមជ្ឈិម។" អ្វីដែលខ្ញុំចង់ឲ្យលោកធ្វើ គឺថាចង់ឲ្យលោកធ្វើការបកស្រាយ ថាតើការដឹកនាំជាលក្ខណៈសមូហភាពហ្នឹងយ៉ាងម៉េចដែរ? ហើយបន្ទាប់មកលោកនិយាយថា គោលនយោបាយមួយចំនួនដែលលោកបានពិភាក្សានោះ គឺថាព័ត៌មានមួយចំនួនគឺលោកបានទទួលពីដីកាដំណោះស្រាយ។ ប្រសិនបើខ្ញុំមិនយល់ច្រឡំទេ តើបែបនេះមែនដែរឬទេ?

[០៩:៣៨:៤៩]

**ឆៈ** ខ្ញុំមិនគិតថា ដូច្នេះទេ។ អ្វីដែលខ្ញុំចង់និយាយនៅពេលនោះ គឺថាឯកសារដែលខ្ញុំយោង គឺនៅក្នុងសៀវភៅដែលថា ប៉ុល ពត ធ្វើការផែនការអំពី គឺនិយាយអំពីការប្រមូលផ្ដុំនៅពីជនបទ។ ប៉ុន្តែខ្ញុំមិនមែនបានន័យថា ខ្ញុំដកស្រង់ពីជើងទំព័រណាមួយនោះឡើយ។ នេះគឺជាឯកសារដែលខ្ញុំចង់និយាយយោង។ ខ្ញុំគិតថា ចំពោះការដឹកនាំជាលក្ខណៈសមូហភាព គឺខ្ញុំបាននិយាយច្រើនដងរួចមកហើយ។ ប៉ុន្តែសៀវភៅបានរៀបរាប់ថា ការដឹកនាំជាលក្ខណៈសមូហភាព គឺត្រូវបានគេធ្វើនៅក្នុងសម័យនោះ។ ទោះបីយ៉ាងណាក៏ដោយ យើងអាចនិយាយថា ប៉ុល ពត គឺជាមេ ព្រោះថា ប៉ុល ពត ជាលេខារបស់គណៈមជ្ឈិម។ ដូច្នេះហើយអាចថាមានគំនិតអរិជ្ឈមានណាមួយ ដែលកើតឡើងចេញពីខាងគណៈកម្មការ។

**សៈ** ប៉ុន្តែខ្ញុំគិតថា ការពន្យល់នេះវាដូចជាមានបញ្ហា។ ប្រសិនបើយើងមើលបន្តទៅទៀត គឺលោកនិយាយអំពីចំណុចនេះ ដែលថាខ្ញុំបានប្រមូលព័ត៌មានពីដីកាដំណោះស្រាយដែលខ្ញុំបានអាន ហើយជារបាយការណ៍ប្រចាំសប្ដាហ៍ ជារបាយការណ៍ដែលត្រូវប្រគល់ទៅឲ្យគណៈមជ្ឈិម។ កាលពីម្សិលមិញលោកបាននិយាយថា លោកមិនមានលទ្ធភាពចូលទៅមើលព័ត៌មានបន្ថែម ដែលមាននៅក្នុងជើងទំព័រក្រៅពីដីកាដំណោះស្រាយ ឬក៏ក្រៅពីឯកសារដែលគេផ្ដល់មកឲ្យលោក តាមរយៈអង្គជំនុំជម្រះសាលាដំបូង។ លោកនិយាយថា លោកអានដីកាដំណោះស្រាយនៅពេលដែលលោកបានមកដល់ទីក្រុងភ្នំពេញ។ ដូច្នេះប្រសិនបើខ្ញុំមើលទៅឃ្លាមួយនេះ ខ្ញុំអាចសន្និដ្ឋានបានថា តាមចម្លើយរបស់លោកនៅក្នុង -- គឺថាដំណោះស្រាយហ្នឹងជួយលោក ដល់ការធ្វើការសម្រេច។ ប៉ុន្តែលោកបាននិយាយថា លោកធ្វើការសិក្សាស្រាវជ្រាវអស់រយៈពេលរាប់សិបឆ្នាំ ដោយផ្អែកទៅលើព័ត៌មានបឋម។ តើយ៉ាងម៉េចដែរអំពីបញ្ហានេះ?

[០៩:៤១:០៣]

**ឆៈ** គឺថាអ្វីដែលខ្ញុំចង់និយាយ គឺថាវាជាការគួរឲ្យចាប់អារម្មណ៍មួយ ដែលឯកសារនេះដែលមាន។ ខ្ញុំមិននិយាយអ្វីឲ្យច្រើនជាងនេះទេ ព្រោះថា ខ្ញុំបាន -- ខ្ញុំគួរតែសិក្សាទៅលើគ្រប់ចំណុចទាំងអស់ទៅលើដីកាដំណោះស្រាយ ប៉ុន្តែខ្ញុំមិនមានពេល ខ្ញុំមិនមានលទ្ធភាព ខ្ញុំមិនមានលទ្ធភាពធ្វើបែបនេះទេ។ ព្រោះថាឯកសារទាំងអស់នេះ គឺវាមានបញ្ហារបស់វា ហើយខ្ញុំទទួលយកទៅលើការប្រើប្រាស់ពាក្យរបស់ខ្ញុំ ដែលខ្ញុំបានឆ្លើយពីកាលមុននៅក្នុងតុលាការ។

**សះ** សូមអរគុណលោកសាស្ត្រាចារ្យ ឆេនដ័ល័រ ចំពោះចម្លើយរបស់លោក ព្រោះថាអានេះ គឺជាអ្វីដែលយើងបានស្តាប់ឮ។ យើងធ្វើការជំទាស់ទៅលើដីកាដំណោះស្រាយ ទៅលើអ្វីដែលបានដកស្រង់នៅក្នុងពេលនោះ ហើយយើងបានធ្វើសំណើ ដោយថាដីកាដំណោះស្រាយមានបញ្ហា ហើយខ្ញុំចង់ដឹងថា តើតាមការប្រុងប្រយ័ត្នរបស់លោក ថាតើលោកមានលទ្ធភាពចូលទៅក្នុងឯកសារទាំងអស់នោះដែរឬទេ? ថាតើលោកបានអានបែបនោះដែរឬទេ? ប៉ុន្តែអ្វីដែលខ្ញុំអាចនិយាយគឺថា លោកពឹងផ្អែកទៅលើអត្ថបទ ហើយលោកបានបង្កើតអត្ថបទហ្នឹងដោយខ្លួនឯង ដើម្បីគាំទ្រទៅលើអង្គហេតុដែលលោកបានដកស្រង់ ហើយអង្គហេតុហ្នឹងគឺមាននៅក្នុងដីកាដំណោះស្រាយ ដែលរៀបចំឡើងដោយព្រះរាជ-អាជ្ញា។

[០៩:៤២:៣២]

ហើយបន្ទាប់មកទៀត លោកបញ្ជាក់ជាមួយនឹងសហចៅក្រមស៊ើបអង្កេត ប៉ុន្តែតើលោកមានការប្រុងប្រយ័ត្នដែរឬទេ? មានការប្រុងប្រយ័ត្នដែរទេ នៅពេលនោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន មិនត្រឹមតែ មេធាវីគាត់បញ្ជាក់ អំពីគំនិតរបស់គាត់នោះទេ ប៉ុន្តែមេធាវីហ្នឹងបានសួរសំណួរដែលលោកអ្នកជំនាញគាត់បានឆ្លើយពីរបីដងរួចមកហើយ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមបន្តទៅសំណួរបន្តទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមមេធាវីរៀបចំនូវសំណួរជាក់លាក់ ដើម្បីអ្នកជំនាញមានលទ្ធភាពស្តាប់យល់នូវសំណួរ និងបំណងនៃការសួររបស់លោក ដើម្បីអាចឆ្លើយតបបាន ចៀសវាងប្រើប្រាស់នូវលទ្ធភាព នៃការធ្វើសេចក្តីការណ៍ ដូចអម្បាញ់មិញនេះ ជាការងារមួយដែលមិនគប្បីទេ។ គប្បីប្រើវិធីសាស្ត្រនៃការរៀបតាំងសំណួរឲ្យបានត្រឹមត្រូវ។

[០៩:៤៣:៤៩]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវនេះ យើងសូមបន្តទៅលើផ្នែកមួយទៀត នៃសក្ខីកម្មរបស់លោកនៅទំព័រ៣៦។ ហើយសំណួរដែលបានសួរ គឺប្រហែលជាម៉ោង ១០:២៦:០៧ គេបានសួរលោកថា "តើ នួន ជា មានការទទួលខុសត្រូវជាក់លាក់ណាមួយដែរឬទេ? ព្រោះថា គាត់មានការទទួលខុសត្រូវមួយចំនួននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា?" នេះគឺជាសំណួរដែលគេសួរលោក ហើយលោកឆ្លើយថា "ខ្ញុំគិតថាគាត់បញ្ជូនទៅ ប៉ុល ពត ដែលជាលេខា។ គាត់បានឆ្លើយថា ប៉ុល ពត មានសេចក្តីសម្រេចចុងក្រោយសឹងតែគ្រប់ករណីទាំងអស់ នៅក្នុងការធ្វើការសម្រេច ដែលការសម្រេចហ្នឹងជាការសម្រេចរួម។ ប៉ុន្តែតាមឯកសារ ឬក៏តាមអ្វីដែលខ្ញុំដឹងគឺថា -- អ្វីដែលខ្ញុំបានអានក្នុងពេលថ្មីៗនេះ ខ្ញុំគិតថា ឯកសារដែលបង្ហាញនៅក្នុងដីកាដំណោះស្រាយផងដែរនោះ បានបង្ហាញថាគាត់ស្ថិតនៅលើថ្នាក់កំពូល ហើយគាត់ចូលរួមនៅក្នុងសកម្មភាពប្រចាំថ្ងៃក្នុងការធ្វើនយោបាយ ក៏ដូចជាសកម្មភាពរបស់ប្រទេសកម្ពុជា។ ឥឡូវនេះ យើងពិនិត្យមើលទៅលើចម្លើយរបស់លោក លោកនិយាយថា៖ "ប៉ុល ពត ជាអ្នកសម្រេចចុងក្រោយសឹងតែគ្រប់ករណីទាំងអស់នៅក្នុងការសម្រេចចិត្ត"។ តើលោកចង់មានន័យយ៉ាងម៉េចដែរ នៅគ្រប់ -- សឹងតែគ្រប់ពេលនៅក្នុងសេចក្តីសម្រេចទាំងអស់នេះ? តើការសម្រេចចិត្តហ្នឹងប្រភេទណាដែរ? ឬក៏ការសម្រេចចិត្តអំពីអ្វីដែរ?

[០៩:៤៥:៤១]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំគិតថា ខ្ញុំនិយាយពាក្យ "សឹងតែគ្រប់ពេល" ព្រោះខ្ញុំមិនអាចនិយាយពេល "គ្រប់ពេលទាំងអស់" ដែលថាគាត់ធ្វើការសម្រេចចិត្ត។ ខ្ញុំមានភស្តុតាងច្រើនទាក់ទងទៅនឹងសកម្មភាពរបស់ នួន ជា ហើយខ្ញុំគិតថាព័ត៌មានទាំងអស់នោះភាគច្រើនជាព័ត៌មានដែលមានលក្ខណៈឯកសារសាធារណៈ ហើយគាត់បានចូលរួមនៅក្នុងសកម្មភាពរបស់បក្សកុម្មុយនីស្ត ក៏ដូចជានៅក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយគាត់ស្ថិតនៅក្រុមមេដឹកនាំ។ ដូច្នេះ អ្វីដែលខ្ញុំបានអានក្នុងពេលថ្មីៗនេះ ខ្ញុំមិនមែនចង់និយាយទៅលើដីកាដំណោះស្រាយដែលខ្ញុំបានដកស្រង់នោះទេ។

[០៩:៤៦:១៧]

វាគ្រាន់តែតែជាឃ្លាមួយនៅក្នុងអ្វីដែលខ្ញុំចង់និយាយ ឬក៏ថាខ្ញុំនឹកឃើញ ខ្ញុំថានៅក្នុងសក្ខីកម្មរបស់ខ្ញុំ។ ខ្ញុំអាចនិយាយនៅពេលក្រោយ ដើម្បីឲ្យមានការបញ្ជាក់ ដើម្បីឲ្យលោកយល់ ប៉ុន្តែខ្ញុំ -- នៅពេល -- ខ្ញុំអាចនឹងត្រឡប់ទៅទំព័រចុងក្រោយនៃសៀវភៅរបស់ខ្ញុំ ហើយខ្ញុំអាចនិយាយ ហើយឬក៏ថាយប់នេះ ខ្ញុំទៅអូតែលរបស់ខ្ញុំ ហើយនិងបកស្រាយប្រាប់លោក។ ដូច្នេះហើយអ្វីដែលខ្ញុំចង់និយាយគឺខ្ញុំដកស្រង់ចេញពីឯកសារជាសាធារណៈ មិនមែនជាចម្លើយ ឬជាសក្ខីកម្មរបស់សាក្សី អ្នកជំនាញណាមួយឡើយ។

**ស៖** លោកសាស្ត្រាចារ្យ ខ្ញុំចង់និយាយពី ប៉ុល ពត មិនមែន នួន ជា ទេ ខ្ញុំគិតថាខ្ញុំសួរសំណួរច្បាស់។ លោកនិយាយថា ប៉ុល ពត មាន -- ជាអ្នកសម្រេចចិត្តចុងក្រោយ ព្រោះថានៅក្នុងសក្ខីកម្មរបស់លោក លោកនិយាយអំពីការសម្រេចចិត្តជាសមូហភាព ប៉ុន្តែលោកក៏ទទួលស្គាល់ផងដែរថា ប៉ុល ពត ជាអ្នកធ្វើការសម្រេចចុងក្រោយ គឺថាគាត់ជាអ្នកសម្រេចទៅលើអ្វីដែលត្រូវធ្វើ។ ហើយសំណួររបស់ខ្ញុំដែលចង់សួរលោកគឺថា តើសក្ខីកម្មរបស់លោកដែលនិយាយថា ប៉ុល ពត មិនមែនជាអ្នកទីមួយ ប៉ុន្តែគាត់នៅក្នុងលំដាប់ទីមួយ តើគាត់ជាអ្នកធ្វើការសម្រេចចិត្ត ហើយអ្នកដទៃទៀតយ៉ាងម៉េចដែរ? តើអ្នកដទៃទៀតគាត់មានសិទ្ធិយ៉ាងម៉េចដែរ?

[០៩:៤៧:៤៩]

**ឆ៖** នេះជាសំណួរដ៏ល្អហើយស្មុគស្មាញទៀត។ ខ្ញុំបានឆ្លើយសំណួរនេះច្រើនដងរួចមកហើយ ការដឹកនាំដែលមានលក្ខណៈសមូហភាព គឺជាការដឹកនាំនៅក្នុងប្រទេសកុម្មុយនីស្ត គឺលេខាបក្សមានការសម្រេចចុងក្រោយ គ្មាននរណាម្នាក់មានសិទ្ធិលើសលេខាបក្សនោះឡើយ។ គឺថាជាលេខារបស់គណៈមជ្ឈិម គឺមានសិទ្ធិសម្រេចចុងក្រោយបែបនេះ។ សេចក្តីសម្រេចដែលត្រូវបានធ្វើ គឺសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា គឺធ្វើឡើងនៅក្នុងការពិភាក្សារបស់គណៈកម្មាធិការ។ ខ្ញុំលើកឧទាហរណ៍តូចមួយ ដែលថាក្នុងករណីទាំងអស់មានការពិភាក្សារួមគ្នា បន្ទាប់គឺធ្វើការប្រកាសជាចុងក្រោយដោយលេខាបក្ស។ ហើយនេះគឺជាសេចក្តីប្រកាសដែលមានអានុភាពចងកាតព្វកិច្ចទាំងអស់គ្នា។ គាត់មិនមែនជាអ្នកដែលមានតែមួយនោះទេ ប៉ុន្តែគាត់នៅក្នុងលំដាប់ទីមួយ។ ដូច្នេះហើយឯកសារនេះវាមាននៅក្នុងប្រវត្តិរូប ឬក៏នៅក្នុងឯកសារផ្សេងៗទៀត។ គឺថា នួន ជា ក៏បានទទួលស្គាល់ផងដែរថា ប៉ុល ពត នៅក្នុងក្រុមរួមគ្នា នៅក្នុងក្រុមសមូហភាព។

[០៩:៤៨:៥៥]

**សៈ** ខ្ញុំមិនមែនចង់ពន្យល់លោក ឬក៏ចង់ឲ្យលោកនិយាយដូចខ្ញុំទេ ប៉ុន្តែខ្ញុំចង់និយាយថាសិទ្ធិអំណាចរបស់ ប៉ុល ពត និងតួនាទីរបស់ ប៉ុល ពត គឺថាគាត់មិនអាចធ្វើការសម្រេចចិត្តដោយខ្លួនឯង ហើយអនុវត្តដែលថា ជាលក្ខណៈនៃការសម្រេចជាសមូហភាព តើលោកចង់និយាយបែបនេះមែនទេ?

**ឆៈ** បាទ <ដោយសារយើងអត់មានកំណត់ហេតុនៃការប្រជុំគណៈអចិន្ត្រៃយ៍ប្រហែល ៣០០ប្រជុំនោះ ខ្ញុំពិបាកក្នុងការឆ្លើយសំណួរនេះឲ្យបានច្បាស់លាស់។> ប៉ុន្តែខ្ញុំមិនដែលឃើញភស្តុតាងណាមួយ<ពីនរណាម្នាក់ ដែលបង្ហាញថា ប៉ុល ពត ពេលខ្លះ ធ្វើការដឹកនាំជាសមូហភាព គ្រាន់តែជាស្តង់ដារជារូបភាព តែបែរជាធ្វើការសម្រេចចិត្តមួយចំនួនដោយឯកឯងនោះទេ។> <>នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ <>មិនមានភស្តុតាងណាមួយបង្ហាញថា ប៉ុល ពត ធ្វើការសម្រេចដោយខ្លួនឯងនោះឡើយ។ <មិនមានភស្តុតាងណាមួយដែលបង្ហាញគណៈអចិន្ត្រៃយ៍ភាគច្រើនបំផុត មិនធ្វើការជាផ្លូងមួយនោះទេ។ ខ្ញុំនិយាយាថា “ភាគច្រើនបំផុត” ព្រោះសមាជិកមួយចំនួនត្រូវគេយកទៅវាយចោលហើយ ប៉ុន្តែមិនមានភស្តុតាងណាមួយបញ្ជាក់> ថា មានការ<ខ្វែងគំនិតគ្នា>ណាមួយជាសាធារណៈដែល ប៉ុល ពត ជំទាស់ជាមួយ<អ្នក>ដទៃ ហើយគាត់ធ្វើការសម្រេចដោយ<ឯកឯងនោះឡើយ។ បរិយាកាសពេលនោះ គឺសមូហភាព។ គាត់មានសិទ្ធិអំណាចមែន ប៉ុន្តែ ខ្ញុំមិនមានភស្តុតាងណាអាចយកមកបញ្ជាក់បានថា គាត់ប្រើសិទ្ធិអំណាចតែម្នាក់ឯង ហើយជំទាស់ទៅនឹងសមាជិកគណៈដឹកនាំរបស់គាត់ទេ។ ហើយខ្ញុំក៏ យល់ឃើញដែរថា ប្រសិនបើមានការខ្វែងគំនិតគ្នាបែបនោះកើតឡើងមែន នោះប្រាកដជាមានព្រឹត្តិការណ៍ធ្ងន់ធ្ងរកើតឡើងនៅក្នុងគណៈដឹកនាំរបស់គាត់មិនខាន ប៉ុន្តែមិនមែនភស្តុតាងអ្វីបញ្ជាក់ទេ គ្រាន់តែជាការសន្និដ្ឋានមួយប៉ុណ្ណោះ។>

**សៈ** លោកនិយាយថា ប្រហែលជាមានការប្រជុំជាង៣០០ ក្នុងពេលកន្លងមក តើមែនទេ? តើលោកមានឯកសារ ឬក៏មានភស្តុតាងណាមួយដែលបង្ហាញថា កិច្ចប្រជុំទាំងអស់នេះ ពិតជាកើតឡើងដូចដែលគេបានរៀបចំកាលវិភាគ ឬក៏រៀបចំកម្មវិធីនេះ ឬមួយក៏លោកគ្រាន់តែលើកយកមកនិយាយតែប៉ុណ្ណោះទេ?

[០៩:៥១:០១]

**ឆៈ** ខ្ញុំមិនមែនព្យាយាមនិយាយអ្វីនោះឡើយ គឺថាឯកសារទាំងអស់នេះ ខ្ញុំមិនដឹងថាតើកិច្ចប្រជុំហ្នឹងកើតឡើងនៅពេលណា--

**សៈ** ធ្វើម៉េចយើងដឹងថា មានការបង្កើតប្រសិនបើយើងអត់នៅទីនោះ--

**ឆ៖** សូមលោកឲ្យខ្ញុំនិយាយឲ្យចប់សិន នេះជាពេលរបស់ខ្ញុំ។ ឯកសារដែលយើងបានទទួលហ្នឹង គឺឯកសារដែលបានបញ្ជាក់ថា កិច្ចប្រជុំនេះធ្វើឡើងជារៀងរាល់សប្ដាហ៍ ហើយយើងមានឯកសារបញ្ជាក់នេះ។ ដូច្នេះឯកសារការប្រជុំនេះគឺធ្វើឡើងរៀងរាល់អាទិត្យ ហើយជារៀងរាល់ឆ្នាំ ដូច្នេះហើយយើងមានការប្រជុំរបស់គណៈមជ្ឈិម។ ទោះបីយ៉ាងណាក៏ដោយ វាជាការសន្និដ្ឋាន ប៉ុន្តែការសន្និដ្ឋានទាំងអស់នេះវាៗផ្អែកទៅលើភស្តុតាងនៃឯកសារ ដែលយើងទទួលបានពីអ្នកស៊ើបអង្កេត គឺថាមានតែកិច្ចប្រជុំរបស់គណៈមជ្ឈិមទេ ដែលបានធ្វើឡើង ហើយចំពោះគណៈអចិន្ត្រៃយ៍គឺអត់មាននោះទេ។

[០៩:៥១:៥៨]

**ស៖** លោកបានឆ្លើយថា សមាជិកទាំងអស់បានចូលរួមគឺ សមាជិកគណៈអចិន្ត្រៃយ៍ចូលរួមទាំងអស់គ្រប់កិច្ចប្រជុំ។ ជាពិសេស គឺកិច្ចប្រជុំមួយដែលយើងមិនបានដឹង លោកសន្មតផ្អែកទៅលើចម្លើយរបស់លោកថា កើតមានឡើង--

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សំណួរនេះ គឺបង្ហាញថា គឺថាលោកសាស្ត្រាចារ្យមិនបានផ្ដល់សក្ខីកម្មទេ ប៉ុន្តែគាត់បានឆ្លើយដោយប្រុងប្រយ័ត្ន ហើយគាត់មិននិយាយថា កិច្ចប្រជុំទាំងអស់របស់គណៈអចិន្ត្រៃយ៍ ត្រូវចូលរួមដោយសមាជិកទាំងអស់ទេ។ គាត់បានឆ្លើយទៅតាមអ្វី តាមឃើញ តាមការស្រាវជ្រាវរបស់គាត់ទេ។

**លោក ម៉ៃខល កាណាវាស៖**

នេះមិនជាសំណួររបស់ខ្ញុំសួរអ៊ីចឹងទេ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តើលោកឆ្លើយក្នុងចម្លើយរបស់លោកថា សមាជិករបស់គណៈអចិន្ត្រៃយ៍ទាំងអស់ចូលរួមកិច្ចប្រជុំទាំងអស់ដែរឬទេ?

[០៩:៥៣:០៥]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** អត់ទេ។ មិនមែនជាការឆ្លើយច្បាស់ទេនៅក្នុងសំណួររបស់លោក លោកបានស្នើថា តើមានអ្វីកើតឡើងនៅ -- តើលោកដឹងម៉េចដែលលោកមិនដឹងអំពីការប្រជុំសោះ -- លោកដឹង ខ្ញុំដឹងថាអ្នក

ណាចូលរួម ថាតើភស្តុតាងដែលយើងមាននោះគឺគណៈអចិន្ត្រៃយ៍ជាក្រុមមនុស្សមួយក្រុមតូចប្រហែលសមាជិកទាំងអស់ ឬក៏ទាំងអស់ចូលរួមកិច្ចប្រជុំតាមជាការងាររបស់គេ ជាការងារសំខាន់។ ប៉ុន្តែដែលលោកនិយាយថា ទាំងអស់ចូលរួមកិច្ចប្រជុំទាំងអស់ ខ្ញុំមិនមានហេតុផលអីត្រូវប្រាប់ទេ។ ឆ្លើយទេ។

**ស៖** នេះហើយជាចំណុចដែលខ្ញុំចង់ដឹង យើងចង់ដឹងថាតើអ្វីជាការដឹងរបស់លោកទាក់ទងទៅនឹងសេចក្តីសន្និដ្ឋានរបស់លោក គឺថាតើអ្វីជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋាន? តើលោកដឹងថាសមាជិកទាំងអស់នៃគណៈអចិន្ត្រៃយ៍បានចូលរួមកិច្ចប្រជុំ ឬក៏ការពិភាក្សាមួយចំនួនដែលកំណត់ឡើងមុនឬក៏កំណត់ឡើងដោយ ប៉ុល ពត ហ្នឹងដែរឬទេ?

[០៩:៥៤:២០]

**ឆ៖** ខ្ញុំត្រូវមើលឯកសារទាំង១៥នោះ ពេលខ្លះមានៗអ្នកខ្លះអវត្តមាន ប៉ុន្តែពេលខ្លះគឺថាសមាជិកពេញអង្គនោះចូលរួមទាំងអស់។ ខ្ញុំទាល់តែមានឯកសារ។

**ស៖** ក្រៅពីឯកសារ១៥ហ្នឹង ខ្ញុំមិនចង់សួរឲ្យលោកផ្អែកលើឯកសារដើម្បីផ្តល់ព័ត៌មានដែលលោកមិនមានភស្តុតាងទេ។ តើលោកបានត្រៀមខ្លួនដើម្បីឆ្លើយថា ប៉ុល ពត ដាក់បញ្ចូល ឬក៏ទទូចឲ្យសមាជិកទាំងអស់នៃគណៈអចិន្ត្រៃយ៍ គ្រប់ប្រធានបទទាំងអស់ដែលគាត់ពិភាក្សាឲ្យចូលរួមនៅកម្រិតប្រជុំថ្នាក់ខ្ពស់ហ្នឹងដែរឬទេ?

[០៩:៥៥:០០]

**ឆ៖** ខ្ញុំមិនអាចឆ្លើយបែបនោះបានទេ។ ខ្ញុំភ្ញាក់ផ្អើលដែលខ្ញុំចង់ឲ្យផ្តល់សក្ខីកម្មដែលខ្ញុំគ្មានភស្តុតាង។ នេះហើយ លោកជាលោកបដិសេធវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវរបស់ខ្ញុំ។ តើលោកឲ្យខ្ញុំឆ្លើយអ្វីដែលខ្ញុំគ្មានភស្តុតាងដែរឬអត់ទេ?

**ស៖** អត់ទេ។ ខ្ញុំគ្រាន់តែចង់ឲ្យលោកឆ្លើយទៅតាមការយល់ដឹងពីការស្រាវជ្រាវសិក្សារបស់លោកតែប៉ុណ្ណោះ។ ខ្ញុំសូមចូលទៅរកចំណុចមួយទៀត ចម្លើយមួយទៀតដែលលោកឆ្លើយ "ខ្ញុំព្យាយាមឆ្លើយមួយផ្នែកមួយ។ ខ្ញុំបានអានថ្មីៗនេះនៅក្នុងឯកសារមួយចំនួន"។ តើឯកសារអ្វីដែលលោកអានថ្មីៗបំផុតនេះ? ហើយលោកនិយាយថា "អ្វីៗនៅក្នុងឯកសារនោះបង្ហាញថា គឺនៅក្នុងដីកាដំណោះស្រាយ"។ ឥឡូវនេះ យើងមានពីរ គឺថាឯកសារមួយចំនួនដែលលោកអានថ្មីៗបំផុត ដែលខ្ញុំសួរលោកពីលោកហេដឌ័រ ហ្នឹងឬទេ ឬក៏អ្វីដែលបានដឹងពីលោក ហេដឌ័រ ទាក់ទងថ្មីៗនេះ ដែលជាព័ត៌មាន ឬក៏លោកហេដឌ័រ ឲ្យលោកនូវឯកសារមួយចំនួន។ ហើយផ្អែកទៅលើសក្ខីកម្មរបស់លោក គឺថាដើម្បីគោល

បំណងនៃការសិក្សាស្រាវជ្រាវរបស់លោក គឺថាផ្នែកមួយទៀត ដែលលោកថា ដីកាដំណោះស្រាយ -- ដែលលោកថា មិនមានឯកសារដែលទាក់ទងទៅនឹងដីកាដំណោះស្រាយ ឬក៏ដែលបានផ្ដល់ឲ្យលោកទេ។ តើៗលោកផ្អែកទៅលើអត្ថបទនៃដីកាដំណោះស្រាយ ឬក៏អ្វីដែលលោកនិយាយពីឯកសារហៅថា *ម៉េតធីវៀល* ហ្នឹង ថាតើលោកធ្វើផ្អែកលើអ្វី ផ្អែកលើការប្រុងប្រយ័ត្ន យកចិត្តទុកដាក់របស់លោកក្នុងឋានៈជាអ្នកជំនាញនោះ?

[០៩:៥៦:៥០]

**ឆ៖** នេះជាសំណួរល្អណាស់ សូមអភ័យទោស ខ្ញុំមិនបានយកកំណត់ហេតុទាំងអស់មកទេ។ ខ្ញុំមិនគិតមុនថាយកឯកសារនោះមកជាមួយ ហើយសំណួរបែបនេះទេ។ បើសិនជាឲ្យលេខយោងទាំងអស់មកមុន គឺខ្ញុំអាចឆ្លើយបាន។ ដូច្នេះ ខ្ញុំមិនបានអាចឆ្លើយសំណួរនេះបានទេ។

**សះ** មិនអាចឆ្លើយនូវចំណុចពេល ពេលក្រោយទេ គឺថា ហើយតុលាការបានជម្រាបលោក ហើយឲ្យលោកតាមដាន តើលោកមិនបានធ្វើដូច្នោះ គឺលោកបានដំណឹង១០ថ្ងៃមុន មុនមកដល់ ហើយលោកបាននិយាយថា តាំងពីលោកមកដល់ ហើយលោកបានជំរុញ ហើយបានមើលការ ពិនិត្យមើលដីកាដំណោះស្រាយ។ ដូច្នេះមិនមានអ្វីអាចនឹងរារាំងមិនឲ្យលោកធ្វើបញ្ជី ដើម្បីពិនិត្យឯកសារទាំងអស់នោះ តាមការណែនាំរបស់តុលាការទេ។ តើត្រូវអីចឹងឬទេ?

[០៩:៥៧:៤៧]

**ឆ៖** តាមការអានរបស់ខ្ញុំនោះ ខ្ញុំអាចនឹងផ្ដល់ឯកសារជូនលោកមុនពេលថ្ងៃស្អែក ខ្ញុំអាចអាននៅអូតែលរបស់ខ្ញុំ គឺថាអាចនឹង គឺជាការងារ ជាទម្លាប់ដូចដែលខ្ញុំសិក្សាស្រាវជ្រាវមុនសរសេរសៀវភៅនោះឯង។

**សះ** នៅក្នុងទំព័រនោះ គឺនៅក្រោមម៉ោង ១០:២៨:២៧ នោះ គេសួរលោកថា “តាមការសិក្សាស្រាវជ្រាវ តើលោកអាចនិយាយបានទេ គឺថានយោបាយសំខាន់ៗ ត្រូវឆ្លងគណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍ដែរឬទេ?” ចម្លើយរបស់លោកនោះ គឺថា ដូចទំព័រ២៧ នៅចំពីខាងលើ ១០:២៩:០៤ នេះជាម៉ោង “ខ្ញុំមិនអាចអះអាងទៅរកការសិក្សារបស់ទេ ខ្ញុំគឺថាមិនអាចធ្វើការសិក្សាអ្វីពីមុនទេតាំងពីចុងឆ្នាំ១៩៩០មក” ប៉ុន្តែភស្តុតាងដែលកើតក្នុងពេលនោះ គឺបង្ហាញអំពីចម្លើយជាវិជ្ជមានទៅនឹងសំណួររបស់លោក។ ហើយសំណួររបស់ខ្ញុំទៅលោកអ្នកជំនាញនោះគឺថា លោកមិនបានធ្វើការស្រាវជ្រាវទេ ប៉ុន្តែលោកនិយាយថា “ភស្តុតាងបានចេញមក ក្រោយពីពេលនោះមក តាំងពីពេលនោះមក”។ តើលោក

យោងទៅរកដីកាដំណោះស្រាយដែលលោកបានអាន ហើយឯកសារដែលបានដកស្រង់ដែលលោកបានពិនិត្យមើល ឬក៏លោកមើលទៅរកការសិក្សា ឬក៏សៀវភៅកម្រិតបណ្ឌិតសភារបស់អ្នកប្រាជ្ញ ឬបញ្ញវន្តផ្សេងទៀតដែលលោកយល់ថា អ្នកដែលយល់ដឹងពីបញ្ហានេះ?

[០៩:៥៩:៣២]

**ឆ៖** នេះគឺ ខ្ញុំបានមើលរួមគ្នាទាំងអស់ ដូចដែលលោកបានលើកអំមិញហ្នឹង។

**ស៖** អ៊ីចឹង តើលោកអាចធ្វើបញ្ជីបានទេ? តើលោកឆ្លើយទៅចម្លើយខាងដើមវិញ ឬយ៉ាងណា បើខ្ញុំចង់បានបញ្ជីថា លោកផ្អែកលើឯកសារណាខ្លះនោះ?

**ឆ៖** បើលោកចង់បានបញ្ជីដែលខ្ញុំបានអានអំពីកម្ពុជាប្រជាធិបតេយ្យកាលពីឆ្នាំ១៩៩៨ ខ្ញុំអាចនឹងជូននៅថ្ងៃស្អែកបាននោះទេ។ គឺថាខ្ញុំអាចនឹងចំណាយពេលបន្តិច ដើម្បីឆ្លើយ។

[១០:០០:០០]

នៅទំព័រ៣៨ នៅខាងលើម៉ោង ១០:២១:០២ គឺមានសំណួរមួយសួរទៅលោកថា៖ “សូមឲ្យលោកពន្យល់ទំនាក់ទំនងរវាងគណៈមជ្ឈិម ហើយនិងគណៈអចិន្ត្រៃយ៍ អំពីឋានៈ ហើយទំនាក់ទំនងទៅវិញទៅមក ហើយនិយាយដោយសង្ខេបអំពីការងារ ដែលគេចាត់តាំងឲ្យគណៈកម្មការនីមួយៗនោះ?” លោកបានឆ្លើយថា៖ “ខ្ញុំត្រូវបញ្ជាក់ថាអ្វីៗដែលខ្ញុំមិនបានសិក្សាជាលម្អិតនោះទេ។ ខ្ញុំមិនចង់ឆ្លើយនោះទេ ដរាបតែស្ថាប័នពីរនេះវាមានតួនាទីត្រួតគ្នា ការបែងចែកឲ្យដាច់ពីគ្នានោះ ខ្ញុំមិនបានត្រៀមខ្លួននឹងឆ្លើយថ្ងៃនេះទេ ឬខ្ញុំនឹងឆ្លើយតបនៅពេលក្រោយ ពេលត្រឡប់មកវិញ ប្រសិនបើលោកចង់បានចម្លើយ។ ប៉ុន្តែខ្ញុំមិនបានត្រៀមខ្លួន មិនអាចផ្តល់ចម្លើយដែលមានលក្ខណៈស្រួចស្រាល់នៅពេលនេះទេ”។ ខ្ញុំអានចេញពីប្រតិចារឹកផ្លូវការរបស់តុលាការ ជាចម្លើយរបស់លោកកាលពីមុនបាទ។

[១០:០១:២៨]

ឥឡូវនេះ តាមចម្លើយរបស់លោក ខ្ញុំមើលឃើញថា លោកប្រាប់តុលាការថា នៅក្នុងការងារជាប្រវត្តិសាស្ត្ររបស់លោក លោកផ្តោតអារម្មណ៍ចំណុចមួយ គឺថាប្រវត្តិសាស្ត្រនៅក្នុងសម័យកាលនោះគឺវាទូលំទូលាយណាស់ ហើយវាមានភាពស្មុគស្មាញ ហើយវាមានប្រធានបទច្រើន។ តើត្រឹមត្រូវដែរឬទេចម្លើយរបស់លោកនោះ លោកមិនដែលសិក្សាជាលម្អិតទេ ឬក៏ឲ្យបានពិស្តារអំពីទំនាក់ទំនងរវាងគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមទេ។ ដូច្នេះហើយ ខ្ញុំបាន -- ដូច្នោះហើយបានលោកបានរក្សាសិទ្ធិក្នុង

ការផ្តល់ចម្លើយនោះ។ តើនេះជាសេចក្តីសង្ខេបត្រឹមត្រូវពីចម្លើយរបស់លោកទេ បើមិនត្រូវសូមលោកកែខ្ញុំផង?

**ឆ៖** បាទ ត្រូវហើយ ខ្ញុំប្រាកដហើយថា ការគាំទ្រគឺថាខ្ញុំមិន -- ខ្ញុំបាននិយាយបន្តិចម្តងៗ។ ខ្ញុំមិនៗមិនមោទនភាពពីការឆ្លើយច្រើនបែបនេះទេ។

**ស៖** នៅពេលដែលលោកនិយាថា លោកត្រៀមខ្លួនឆ្លើយនូវចំណុចមួយនៅពេលក្រោយនោះ តើខ្ញុំ -- សូមលោកពន្យល់ខ្ញុំ តើខ្ញុំសន្មតថាលោកចង់និយាយថា ខ្ញុំអាច -- លោកទៅមើលឯកសារផ្សេងទៀត ឬក៏អាចមើលឯកសារណាផ្សេង ហើយមកផ្តល់ទស្សនៈដែលផ្អែកលើឯកសារផ្សេងៗ។ តើលោកចង់និយាយអ៊ីចឹងឬ ពេលដែលលោកថាឆ្លើយពេលក្រោយនោះ?

[១០:០២:៥៩]

**ឆ៖** ខ្ញុំអាចនឹងផ្តល់ទស្សនៈដែលមានព័ត៌មានច្រើនទៀតនៅពេលមានសំណើធ្វើដូច្នោះ ខ្ញុំនឹងអាចអានធ្វើនេះ ប៉ុន្តែឥឡូវនេះខ្ញុំមិនបានត្រៀមខ្លួនឆ្លើយនេះទេ។

**ស៖** ខ្ញុំមិនរិះគន់លោកទេ ប៉ុន្តែគ្រប់គ្រាន់ដែរទេ ដែលលោកអាចនិយាយថាឯកសារប្រភេទនោះ -- គឺថាឯកសារ -- បើថាលោកត្រូវពិនិត្យមើលឯកសារតាមដែលគេសុំ ដើម្បីឆ្លើយនូវសំណួរដែលស្រួចស្រាល់នោះ គឺនេះជាអ្វីដែលលោកមិនបានគិតទេ។ តើនេះជាការងារជាបញ្ញវន្ត ជាអ្នកប្រវត្តិវិទូដែរទេ គឺថាលោកត្រូវតែផ្អែកទៅលើឯកសារប្រភពចម្បង ធ្វើការវិភាគ បន្ទាប់មកបានអាចធ្វើសេចក្តីសន្និដ្ឋាន ឬក៏ជាសេចក្តីសន្មតអ្វីមួយនោះ?

**ឆ៖** ខ្ញុំមិនច្បាស់ថាតើសំណួរហ្នឹងត្រូវតែឆ្លើយបែបនោះឬទេ ប៉ុន្តែការងារដែលធ្វើពីរ ឬបីថ្ងៃក្នុងការផ្តល់សក្ខីកម្មនោះ គឺថាផ្អែកទៅលើប្រភពដែលមាន គឺថានេះគឺជាលទ្ធភាពដែលល្អបំផុត ដែលខ្ញុំអាចឆ្លើយបាន។

[១០:០៤:១២]

**ស៖** នេះហើយផ្អែកទៅលើអ្វីដែលអ្នកផ្សេងបានសរសេរ ឬក៏អាក់ -- ព័ត៌មានអ្វីផ្សេងទៀតដែលអាចមាននោះ ទើបលោកអាចឆ្លើយ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** គឺថាតាមពិតហើយ គឺផ្អែកលើសំណេររបស់អ្នកផ្សេង ព្រោះខ្ញុំមិនបានសរសេរពីរឿងហ្នឹង។

**ស៖** ដូច្នេះ ខ្ញុំនឹងផ្អែកទៅលើការវិភាគ។ ដូច្នេះ គឺថាការបើកសៀវភៅដើម្បីធ្វើតេស្ត តើអ៊ីចឹងឬទេ? យើងផ្អែក យើងឲ្យសំណួរ ហើយលោកទៅបើកសៀវភៅមើល ហើយត្រឡប់មកឆ្លើយវិញ។ តើអ៊ីចឹងឬទេ? សូមអភ័យទោស បើសិនជាលោកយល់ថា ខ្ញុំរិះគន់លោកខ្លាំងនោះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន--

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំទាន់អាលទាន់ឆ្លើយ ចាំស្ដាប់សេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាជាមុនសិន។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:០៥:០០]

**លោក អាប់ឌុលឡាក់ ថារីក៖**

នេះជាវិធីនៃការសួរសំណួរ គឺថាជាប្រើវិធីផ្សេង ប៉ុន្តែសួរសំណួរដដែលហ្នឹង គឺពីរ ឬបីដង។

**លោក ម៉ែខល កាណាវាស៖**

ខ្ញុំនឹងបន្តទៅមុខទៀតលោកប្រធាន។ ខ្ញុំសូមដកសំណួរនេះមកវិញបាទ។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** យើងចូលទៅដល់ទំព័រ៤០ នៅក្នុងប្រតិចារឹកតុលាការ នៅខាងក្រោមម៉ោង ១០:៥៤:៣៣ លោកបានទទួលសំណួរមួយ ហើយសំណួរនោះសួរថា នៅបន្ទាប់១៩ “នៅក្នុងក្រុមពិសេសនោះ តើមានសមាជិកណាមួយនៃគណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍ដែរឬទេ?” សំណើ -- ចម្លើយរបស់លោកនោះឆ្លើយថា៖ “បាទ យើងគិតបែប -- គិតដូច្នេះ ប៉ុន្តែមិនមានភស្តុតាងផ្ទាល់អំពីបញ្ហានោះទេ តាមពិតនោះ”។ ឥឡូវនេះតាមចម្លើយរបស់លោកនោះ គឺថាខ្ញុំយល់ថា លោកបានធ្វើការស្មានផ្អែកលើការចេះដឹងរបស់លោក គឺជាសេចក្ដីសន្និដ្ឋានផ្អែកលើការចេះដឹងរបស់លោក។ ហើយតាមពិតលោកមានគុណវុឌ្ឍិដោយហេតុថា លោកមិនមានភស្តុតាងជាក់ស្ដែងដើម្បីគាំទ្រចម្លើយនេះទេ? តើអ៊ីចឹង ឬទេ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប រង់ចាំស្ដាប់អង្គជំនុំជម្រះសម្រេចលើសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាជាមុនសិន។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:០៦:៤១]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមៗឲ្យមេធាវីសួរឲ្យបានជាក់លាក់ ដែលចាប់ឡើងនៅ គឺថាចំចំណុចកណ្ដាលនៃការពិភាក្សាហ្នឹង គឺទាក់ទងទៅនឹងការប្រជុំក្នុងផែនការបួនឆ្នាំ។ សូមមេធាវីផ្ដល់សេចក្ដីផ្ដើមបន្តិចដើម្បីឲ្យសាស្ត្រាចារ្យគាត់តាមដានអំពីបរិបទ ទាក់ទងទៅនឹងបញ្ហាដែលគណៈអចិន្ត្រៃយ៍ ឬគណៈមជ្ឈិមពិភាក្សាក្នុងសម័យកាលនោះ។

**លោក ម៉ៃខល កាណាវាស៖**

សូមអភ័យទោស ខ្ញុំយល់ថា គឺថាសំណួរដែលខ្ញុំដកស្រង់ហ្នឹង គឺថាអាចនឹងឲ្យលោកចាំបាននូវខ្លឹមសារបរិបទនោះហើយ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** អ៊ីចឹងគឺថាអ្វីដែលលោកអាចឆ្លើយបានដែលល្អបំផុត នៅក្នុសំណួរនេះ គឺថាដោយផ្អែកលើថា លោកផ្អែកលើការទាយ ស្មាន ឬទេ ដែលពេលលោកឆ្លើយនៅក្នុងសំណួរនេះនោះ?

[១០:០៧:៣៨]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ហើយខ្ញុំចង់ឲ្យលោកបំភ្លឺអំពីក្រុមដែលជ្រើសរើសហ្នឹង គឺថាតើ *សែលឡិច គ្រុប* ក្រុមពិសេសនៅកន្លែងនេះ លោកចង់សំដៅរកអ្នកណា?

**ស៖** នេះគឺជាសំណួរ ហ្នឹងជាបញ្ហាមួយ។

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

លោកសាស្ត្រាចារ្យចាំ រង់ចាំមានភ្លើង បាទមានភ្លើងសិន ហើយលោកមេធាវីសូមរំលេចនូវសំណួរលោកឲ្យបានជាក់ច្បាស់ ដើម្បីអ្នកដែលទទួលចាំឆ្លើយតបនឹងសំណួររបស់លោកហ្នឹង លុះត្រាតែស្ដាប់សំណួរយល់ ហើយនិងជាក់ច្បាស់។ បើសួរមិនច្បាស់ទេ គឺការឆ្លើយក៏មិនបានត្រឹមត្រូវដែរ។ លោកតំណាងសហព្រះរាជអាជ្ញាបានចង្អុលបង្ហាញ កត់សម្គាល់រួចហើយ អំពីបញ្ហាគប្បីធ្វើរំលេចនូវសំណួរដែលលោកមានប៉ុនប៉ង -- មានបំណងសួរទៅតំណាង -- អ្នកជំនាញនេះ គប្បីធ្វើឲ្យបានច្បាស់

លាស់។ ពីព្រោះបរិបទនៃការតាំងសំណួរ គឺមានការពាក់ព័ន្ធគ្នាច្រើននៅក្នុងបញ្ហានីមួយៗ ដែលដេញដោលតាំងពីដើមទីរហូតដល់ពេលនេះ។

[១០:០៨:៤៨]

**លោក ម៉ែខល កាណាវាស៖**

សូមអភ័យទោសចំពោះបញ្ហានេះលោកប្រធាន។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ផ្នែកនេះបានចាប់ផ្ដើមនៅទំព័រ៣៩ ហើយលោកបានយោងទៅរកអ្វីដែលលោកបានសរសេរ លោកនិយាយអំពីក្រុមពិសេសមួយ ក្រុមដែលបានជ្រើសរើសមួយ។ ចំណងជើងឯកសារហ្នឹងគឺថា "សេចក្ដីពន្យល់បឋមមុននឹងអានផែនការរបស់លេខាបក្ស"។ ហើយលោកបានអានផ្នែកមួយ លោកនិយាយថា ខ្ញុំសូមដកស្រង់នៅទំព័រ៣៩ -- នៅទំព័រ២២។ ដកស្រង់៖ "ក្នុងចន្លោះឆ្នាំ -- ថ្ងៃទី២១-២៣ ខែសីហា ឆ្នាំ១៩៧៦ កិច្ចប្រជុំរបស់គណៈមជ្ឈិមមិនបានបញ្ជាក់ទេ។ ប៉ុន្តែបានបញ្ជាក់ក្រុមសមាជិកមួយចំនួនរបស់បក្សកុម្មុយនីស្តកម្ពុជាដែលប្រជុំនៅភ្នំពេញ។ លេខាបក្ស ប៉ុល ពត និយាយវែងពីផែនការបួនឆ្នាំរបស់បក្ស"។ ដូច្នេះក្រុមពិសេស លោកសាស្ត្រាចារ្យនោះ អ្វីដែលលោកបានសរសេរខ្លួនឯងទេ។

[១០:១០:០០]

ឥឡូវនេះលោកសួរមកខ្ញុំវិញ ហើយនៅបន្ទាត់ទី១៩ ហើយសំណួរសួរលោកថា "នៅក្នុងក្រុមពិសេសនោះ តើមានសមាជិកណាម្នាក់របស់គណៈអចិន្ត្រៃយ៍ដែរឬទេ?" ចម្លើយរបស់លោក "ខ្ញុំគិតថាមានភស្តុតាងច្បាស់ពីបញ្ហាហ្នឹង។ ប៉ុន្តែមិនមានភស្តុតាងច្បាស់ពីរឿងហ្នឹងទេ។" លោកនិយាយ "ខ្ញុំគិតថា" តើខ្ញុំ ឬក៏យើងនេះជាអ្នកណា? ជាអ្នកប្រវត្តិសាស្ត្រជាទូទៅ ឬក៏ៗជាវិធីដែលលោកនិយាយទេពាក្យថា *វី* ឬក៏យើង ឬខ្ញុំ នេះ? ឬក៏សហអ្នកនិពន្ធនៃអត្ថបទនេះ? ពីព្រោះថា សហអ្នកនិពន្ធរបស់លោកក៏ក្នុងចំណោមនេះដែរ តើអ៊ីចឹងឬទេ?

**ឆ៖** គឺថាយើង គឺសរុបទាំងបីហ្នឹង គឺជាមតិស្រុះស្រួលគ្នា ដែលបង្ហាញថា សមាជិកខ្ពស់នៃបក្សនោះឯង។ មិនមានណាម្នាក់ -- បើសិនជាមិនមានអ្នកណាចូលរួមទេ គេមិនអាចប្រជុំបានទេសមាជិកថ្នាក់ខ្ពស់នោះ គឺថាគេមិនអាចអនុវត្តនូវមតិយោបល់របស់លេខាបក្សបានទេ។ ហើយអ្នកដែល

បញ្ជាក់ គឺថា កិច្ចប្រជុំហ្នឹងគឺថា និយាយឡើងដោយ ប៉ុល ពត ឬក៏និយាយថា លេខាបក្ស។ ប៉ុន្តែខ្ញុំមិនបានបញ្ជាក់ឯកសារ។ ពាក្យថា ក្រុមពិសេស ឬក៏ក្រុមដែលជ្រើសរើសនេះ គឺមិនមានកំណត់និយមន័យទេ។

[១០:១១:៣៩]

**ស៖** នៅពីដើមលោកនិយាយថា "ប្រហែលជា" ប្រហែលមានក្រុមជ្រើសរើស ឬក៏ក្រុមពិសេសហ្នឹង។ នេះជាផ្នែកមួយនៃអត្ថបទនេះ គឺថា ពាក្យដែលលោកនិយាយថា "ប្រហែល" នេះនែ៎ តើជាការទាយ ឬក៏ការសន្និតរបស់លោក? ប្រហែលជាលោកថា មិនមែន ប៉ុល ពត ឬក៏អ្នកនៅក្រុមនៅជុំវិញគាត់ តើពាក្យថា "ក្រុមជ្រើសរើស" ហ្នឹង ក្រៅពីក្រុមមនុស្សនៅក្នុងគណៈកម្មាធិការ -- ហើយលោកនិយាយថា "ប្រហែលជាក្រុមជ្រើសរើស គឺជាបានមកប្រជុំនៅភ្នំពេញ" នេះជាការសន្និដ្ឋានដែលលោកបានធ្វើ។ ពីព្រោះគឺថា អាចនឹងមានការប្រកាស ឬក៏មិនមានការប្រកាសពីផែនការបួនឆ្នាំ។ តើខ្ញុំលើកឡើងហ្នឹងត្រូវដែរឬទេ?

**ឆ៖** បាទ ដែលលោកបន្ថែមបែបនេះ គឺជាឯកសារដែលបោះពុម្ពផ្សាយចែកជូនជាសាធារណៈ គេបានពន្យល់ថា អ្វីដែលត្រូវធ្វើនៅក្នុងរយៈពេលពីរបីខែបន្ទាប់ ចំពោះក្រុមធំនោះ។ ពាក្យថា "ក្រុមពិសេស" ឬ "ក្រុមជ្រើសរើស" ហ្នឹង គឺថាខ្ញុំអាច *អ៊ីម៉ាជិន* ខ្ញុំអាចនឹងនឹកថា គឺថា មនុស្សមកពីតំបន់មកពីភូមិភាគ ឬក៏ថា អាចមនុស្សមកពីគណៈ ឬក៏មន្ទីរមួយចំនួន។

[១០:១៣:១០]

ខ្ញុំមិនអាចមិនជឿថាពួកគេមិនចូលរួម នោះគឺថា ពួកគេត្រូវតែមកប្រជុំ ចំពោះមេដឹកនាំជាន់ខ្ពស់។ នេះជាសេចក្តីសន្និដ្ឋានដកស្រង់ចេញមកពីឯកសារ មិនមែនត្រឹមតែឯកសារនោះទេ ដែលរកឃើញនៅឆ្នាំ១៩៧៩ ទេ គឺថាវាមានឯកសារផ្សេងទៀត ដែលបោះពុម្ពផ្សាយចែកជាសាធារណៈនោះដែរ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំបន្តទៅដល់សំណួរមួយទៀត ដែលភាគីសួរទៅលោកនោះនៅទំព័រ ៤១ រហូតដល់ទំព័រ ៤២ គឺនៅខាងលើម៉ោង ១០:៥៨:១៣។ សំណួរហ្នឹងគឺថា នៅទំព័រ -- នៅបន្ទាត់ទី២៣ "នៅក្នុងបរិបទនៃកិច្ចប្រជុំនេះ ពាក្យ "អង្គការ" យោងតែទៅ ប៉ុល ពត ឬក៏អាចមានន័យទូលាយជាងនេះ ហើយដាក់បញ្ចូលសមាជិកបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀតផងដែរឬ?" ឥឡូវនេះខ្ញុំអានផ្នែកដែលពាក់ព័ន្ធ គឺថាចម្លើយទាំងស្រុងរបស់លោក ក្នុងបរិបទនេះ មិនមានការជំទាស់ "នេះជា

សំណួរល្អណាស់ ហើយខ្ញុំពិបាកយល់ឆ្លើយណាស់។ ហើយអ្វីដែលខ្ញុំគិតដំបូងនោះ គឺត្រូវគិតថា នេះជាឯកសារដែល ប៉ុល ពត ហៅខ្លួនឯងថាអង្គការ។ ប៉ុន្តែនៅគំនិតទីពីរ ខ្ញុំយល់ថា ពាក្យក្នុងបរិបទនេះបញ្ជាក់ថា សេចក្តីសម្រេចធ្វើឡើងនៅក្នុងកិច្ចប្រជុំនោះ ដែលធ្វើឡើងដោយសមូហភាព ដោយអង្គការខ្លួនឯង មិនមែនដោយមនុស្សនៅក្នុងប្រជុំនោះទេ។ នោះគឺធ្វើ -- ខ្ញុំយល់ថាវាមានន័យសំខាន់ ដែលគេយោងទៅរក ប៉ុល ពល ថាជាអង្គការហ្នឹង ជាគំនិតមួយដែលសមស្រប។

[១០:១៥:០៧]

ប៉ុន្តែភស្តុតាងជាក់ស្តែង មិនមាននោះទេ ហើយៗ ខ្ញុំមិនបញ្ជាក់ថា ជាសេចក្តីសន្និដ្ឋានសន្នតរបស់ខ្ញុំនោះទេ។ ឥឡូវនេះ ខ្ញុំមើលចម្លើយរបស់លោកគឺថា ទាក់ទងទៅនឹងអង្គការ ដែលយោងទៅរក ប៉ុល ពត នោះ សំដៅ ប៉ុល ពត តែប៉ុណ្ណោះ ឬក៏យោងទៅរក ឬក៏វាមានន័យទូលាយជាងហ្នឹង? តើពាក្យ “អង្គការ” ហ្នឹងសំដៅទៅរកតែ ប៉ុល ពត ច្រើនជាងក្នុងន័យថា ច្រើនជាងមន្ទីរ៨៧០ ឬក៏ ប៉ុល ពត ក្នុងឋានៈមួយចំនួនដែលលោកបានលើកឡើងកាលពីសប្តាហ៍មុននោះ?

[១០:១៥:៥៨]

**ឆ៖** សូមទោស ខ្ញុំមិនមានឯកសារចំពោះមុខទេ ដែលលោកសុំបំភ្លឺបែបនេះ។ តើឃ្លាដែលនិយាយអង្គការ តើ ប៉ុល ពត ជាអ្នកនិយាយ ឬក៏នៅក្នុងចំណងជើងអ្វីមួយ? ខ្ញុំមិនដឹងថា តើប្រធានបទអង្គការហ្នឹងវាក្នុងកន្លែងណា? ចម្លើយរបស់ខ្ញុំគឺថា ទាល់តែមានលក្ខខណ្ឌ ឲ្យបរិបទមុនជាខ្ញុំ។

**ស៖** ហើយយើងមើលទៅទំព័រ៤១ គឺថា អត្ថន័យនៃគណៈអចិន្ត្រៃយ៍នៅ -- បានសួរនៅ -- គឺបានធ្វើឡើងនៅព្រឹកថ្ងៃ១៤ ឧសភា ឆ្នាំ៧៦ គឺថាឯកសារ E3/2221 ហើយក៏បាននិយាយអំពីការកត់ត្រាវត្តមានរបស់ជនជាប់ផងដែរ គឺថានិយាយអំពីព្រំដែនសមុទ្រ ហើយនិងសេចក្តីពន្យល់ និងការណែនាំដោយ ប៉ុល ពត ដោយមានមតិសង្ខេបដោយ អៀង សារី។ ហើយសំណួរ សួរទៅលោក កាលណោះនោះគឺថា “តើពាក្យថា អង្គការហ្នឹងនៅក្នុងឯកសារហ្នឹង យោងទៅរកតែ ប៉ុល ពត ឬក៏វាមានន័យទូលាយជាងហ្នឹង?” ប្រសិនបើខ្ញុំមិន -- បើសិនជាខ្ញុំលើកភស្តុតាងនេះខុស គឺថាសហព្រះរាជអាជ្ញាប្រាកដជាជំទាស់ហើយ។ ដូច្នេះ លោកអាចឆ្លើយបានទេ នៅក្នុងបរិបទនេះ នេះជាសំណួរ។ ឥឡូវសំណួររបស់ខ្ញុំសួរត្រឡប់ទៅលោកវិញថា តើ ប៉ុល ពត តើគេហៅ ប៉ុល ពត ថា “អង្គការ” ឬទេ?

**ឆ៖** វាអាស្រ័យទៅពេលវេលាទីកន្លែងណា ហើយអ្នកណាអ្នកហៅ។ នៅក្នុងក្រុមគឺថា គេហៅបែបនេះ។ នេះជាពាក្យដែលគេប្រើដើម្បី -- ចំពោះប្រជាជន និងដើម្បីកុំឲ្យដឹងថា អ្នកណាជាមេ

ជាក់លាក់ គឺឲ្យគ្រាន់តែដឹងថា "អង្គការ"។ អ៊ីចឹងហើយជាមេដឹកនាំសមូហភាព ដែលដឹកនាំដោយ ប៉ុល ពត ហើយគេហៅថាជា "អង្គការ" ជាឯកសារសម្ងាត់។ ហើយសមាជិកគឺថា ខ្ញុំមិនគិតថា សមាជិកផ្សេងទៀតដែលថា ដាក់ ប៉ុល ពត ជាអង្គការជំនួសអ្នកផ្សេងនោះទេ។

[១០:១៨:២២]

**ស៖** ឥឡូវយើងទុកឯកសារនេះមួយឡែកសិន។ ឥឡូវ ខ្ញុំចង់ឲ្យពិភាក្សាតែលើពាក្យនេះទេ ពីព្រោះថា សហព្រះរាជអាជ្ញាសួរលោក អំពីមន្ទីរ៨៧០ អ្នកណាធ្វើការនៅទីនោះ? អំពីបរិបទនៃសំណួរហ្នឹង ខ្ញុំយល់ថា លោកបានផ្តល់ការពន្យល់។ ហើយនៅពេលមួយនោះ នៅពេលដែលលោកឆ្លើយនោះ លោកនិយាយថា "ប៉ុល ពត ក៏គេហៅថា "អង្គការ" ដែរ គេហៅថា "៨៧០" ដែរ ប៉ុល ពត នោះ"។ ខ្ញុំៗមិនចាំច្បាស់ទេគឺថា លោកនិយាយថា មន្ទីរ៨៧០ ឬក៏ ៨៧០ ជា ប៉ុល ពត នោះទេ ប៉ុន្តែខ្ញុំចាំថា លោកនិយាយបែបហ្នឹង។ អ៊ីចឹងសួរថា តើផ្អែកលើបរិបទហ្នឹង តើ ប៉ុល ពត ហ្នឹងគេចាត់ទុកថា ជា "អង្គការ" គេហៅថា ជា "អង្គការ" ដែរឬទេ?

**ឆ៖** ខ្ញុំមិនចង់ឲ្យលោកច្រឡំទេ។ នេះគឺជាលេខកូដមន្ទីរ៨៧០ នោះគឺថានៅក្រៅពីក្បាលម៉ាស៊ីន គេហៅ ប៉ុល ពត ថាជា "អង្គការ" ហ្នឹងហើយ។ ប៉ុន្តែចំពោះប្រទេស ប្រជាជននៅតាមជនបទហ្នឹង គឺថា ដូចក្នុងខ្ញុំឆ្លើយខាងដើម។ ហើយប្រជាជនយល់ថា "អង្គការ" នោះគឺជាមនុស្ស ប៉ុន្តែគេមិនដឹងថា ដឹកនាំដោយមេដឹកនាំសមូហភាពទេ ប៉ុន្តែឈ្មោះបែបនេះ គឺមិន -- ស្រពេចស្រពិលមិនបង្ហាញឲ្យច្បាស់។ ខ្ញុំមិនមាន -- គឺនៅក្នុងក្រុមគឺថា អៀង សារី ខៀវ សំផន គេមិនដឹងថា ពួកគាត់ហៅ ប៉ុល ពត ថា ជាអង្គការ ដែរឬទេ?

[១០:២០:១០]

ប៉ុន្តែដូចដែលយើងនិយាយខាងដើម ជាឈ្មោះនៃសេចក្តីសម្រេចសមូហភាពដែលគេនិយាយ ដែលថាយើងទាំងអស់ហ្នឹងជាអង្គការ មិនមែនពួកគាត់តែម្នាក់ឯងទេ។

**ស៖** នេះហើយជាចម្លើយរបស់លោក ខ្ញុំចង់បានហ្នឹង គឺថា គេបានស្នើឡើងជាសមូហភាព ហើយអង្គការបានអនុម័ត។ តើសេចក្តីសម្រេចដែលធ្វើឡើងនៅថ្នាក់កំពូល ហើយថ្នាក់ក្រោមត្រូវតែធ្វើតាមទេ ដូចជាគណៈអចិន្ត្រៃយ៍ជាដើម? ហើយ ឬក៏លោកមិនត្រៀមនឹងឆ្លើយអ្វីឲ្យលើសពីហ្នឹង តើអ៊ីចឹងឬទេ?

[១០:២០:៤៧]

**ឆ៖** ទេ ខ្ញុំមិន -- បាទ ត្រូវហើយលោកនិយាយអ៊ីចឹងត្រូវ។

**ស៖** ម្យ៉ាងទៀតនៅគណៈអចិន្ត្រៃយ៍គឺថាអាចនឹងប្រជុំពិភាក្សាពីរឿង កុយ ធួន ហើយបន្ទាប់មកគឺគេបញ្ជូនទៅថ្នាក់លើ ទៅអង្គការនោះ។ ហើយដូច្នេះយើងអាចនឹងបោសសម្អាតគាត់ដូចជា វន វ៉េត ដូចគ្នា គេអាចអង្គុយ ដែល វន វ៉េត នៅនោះ គឺគេបោះឆ្នោតហើយបន្ទាប់ ប៉ុល ពត ជាអ្នកធ្វើសេចក្តីសម្រេច។ តើនេះជាវិធីដែលគេធ្វើការ ដើម្បីលោកទទួលស្គាល់ថាចម្លើយលោក លោកផ្អែកលើចំណុចហ្នឹងទេ ថ្ងៃនេះនោះ?

**លោក អាប់ឌុលឡាក់ ថារីក៖**

គឺសូមជំទាស់ទៅនឹងការប្រើពាក្យ មិនដឹងថាបកប្រែទៅជាខ្មែរថាម៉េចទេ ពាក្យដែលលោកប្រើមេធាវីប្រើហ្នឹងគឺថាមិនសមស្របថានឹងយកពាក្យហ្នឹងមកឲ្យអ្នកជំនាញឆ្លើយ។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ហើយខ្ញុំនិយាយពាក្យថា កុយ ធួន ហើយគេត្រូវសម្រេចកម្មេចគាត់ គឺថាពាក្យហ្នឹងគឺថាប្រើជាទូទៅ តើលោកចង់និយាយថា គណៈអចិន្ត្រៃយ៍ សមាជិកទាំងអស់គឺបានជួបគ្នាដោយរាប់ទាំងអ្នកដែល -- ទីបំផុតហ្នឹងត្រូវចាប់ដែរ ហើយពិភាក្សាហើយបញ្ជូនទៅឲ្យ ប៉ុល ពត សម្រេច តើអ៊ីចឹងទេ? តើនេះជាអ្វីដែលខ្ញុំយល់អំពីចម្លើយរបស់លោកដែរឬទេ? ជាសេចក្តីសន្និដ្ឋានរបស់លោក តើលោកចង់ផ្តល់លទ្ធភាពណាមួយទៀតថាក្រុមនៅក្នុងក្រុមហ្នឹង អាចនឹងធ្វើសេចក្តីសម្រេចនៅក្នុងពេលណាមួយដែរ?

[១០:២២:៣២]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ទាក់ទងទៅនឹងអ្នកប្រវត្តិសាស្ត្រហ្នឹង គឺថាលោកជំរុញឲ្យខ្ញុំថាឲ្យឆ្លើយពីកិច្ចប្រជុំដែលយើងមិនដឹងថាមានមិនមាន។ ខ្ញុំមិនអាចដើរផ្លូវហ្នឹងបានទេ ហើយយើងមានកិច្ចប្រជុំដែលយើងមិនដឹងថាមានសេចក្តីសម្រេចគឺថាអាច -- ដូចដែលលោកនិយាយនោះគឺថាភស្តុតាងនេះយើងមិនមានពីរឿងប្រជុំនោះទេ ភស្តុតាងដែលយើងមាននោះគឺថា ប៉ុល ពត មិនដែលសម្រេចផ្ទុយពីប្រជុំនោះទេ យើងមិនមានគំនិតហ្នឹងទេ។ អ្វីដែលលោកដាក់មកខ្ញុំនៅថ្ងៃនេះ គឺឲ្យខ្ញុំឆ្លើយហ្នឹងគឺថា នេះជាអ្វីដែលយើងអាចប៉ុន្តែបើឲ្យសរសេរខ្ញុំមិនអាចសរសេរបែបនេះបានទេ។

**សៈ** សូមទោសនេះជាចំណុចដែលខ្ញុំចង់បាន លោកអះអាងថាមិនមែនជាវិធីដែល ប៉ុល ពត ធ្វើទេ ប៉ុន្តែក្នុងប្រយោគដដែលហ្នឹងលោកនិយាយថា ប្រហែលថា យើងមិនមានភស្តុតាងទេ ប៉ុន្តែវាកើត អាចកើតមានឡើងអ៊ីចឹង។ អ៊ីចឹង ខ្ញុំឃើញថាលោកមានភស្តុតាងផ្ទុយពីហ្នឹង ឬយ៉ាងម៉េច? ហើយលោក ចង់មាន ឆន្ទៈទៅអ្វីដែលលោកសន្និដ្ឋាន ដែលលោកយល់ថាអ៊ីចឹងត្រូវតែអនុវត្តបែបនេះ ប៉ុន្តែខ្ញុំគិតថាមិន មែនអ៊ីចឹង។ អាហ្នឹងលោកចង់និយាយអ៊ីចឹង ឬយ៉ាងម៉េច?

[១០:២៣:៥២]

**ឆៈ** នេះហើយជារបៀបដែលខ្ញុំសរសេរគឺថា អាចនឹងមានពាក្យថា “អាច” គឺវាអាច ដូចថា “ល្ងាចនេះមានវញ្ញយដី” ប៉ុន្តែវាមិនប្រាកដថាមាននោះទេ។

**សៈ** ឥឡូវនេះ ខ្ញុំនឹងទៅមុនបន្តិចទៀត ខ្ញុំមិនមើលគ្រប់ចំណុចទាំងអស់ដែលខ្ញុំកត់ចម្លើយរបស់ លោកមកដេញដោលនោះទេ។ នៅផ្នែកមួយដែលខ្ញុំចង់ពិនិត្យមើលគឺសំណួរ និងចម្លើយនៅទំព័រ៦៣ នៃ ប្រតិចារឹករបស់តុលាការ ខ្ញុំរកមើលម៉ោង គឺថានៅខាងលើម៉ោង ១១:២៥:២០ គឺសំណួរគេសួរលោក ថា “សូមលោកពន្យល់យើងអំពីតួនាទីរបស់បក្សកម្ពុជាប្រជាធិបតេយ្យ។ ចម្លើយរបស់លោកពេលនោះ គឺជាចម្លើយវែងហើយខ្ញុំអានតែមួយផ្នែកទេ ខ្ញុំអានត្រង់បរិបទមួយដែល -- ចំណុចមួយប្រសិនបើ -- លោកឆ្លើយថា “ប្រសិនបើខ្ញុំអាចធ្វើដូច្នោះបាននោះ។” ហើយនៅខាងក្រោមទៅទៀតនៅទំព័រ -- នៅ បន្ទាត់ទី១២ ហ្នឹងគឺ “តើបក្សដំណើរការដូចម៉េច? នៅពេលលោកនិយាយឃ្លាបែបនោះ យើងនឹងទៅ ភាពជាក់ស្តែងជាជាងនៅក្នុងភាពមួយនៃការអះអាងពីអំណាចដែលបក្សបានប្រកាន់។ ខ្ញុំគិតថា ស្ថាប័ន នយោបាយណាមួយមិនអាចធ្វើការងារដាច់ខាត មិនអាចជំទាស់បាន ហើយភស្តុតាងមិនច្បាស់លាស់ នៅក្នុងកថាខណ្ឌដូចដែលលោកនិយាយនេះបានលើកឡើងនោះទេ។” បាទ នេះជាកំណត់ត្រាដែល ចម្លើយរបស់លោក ដែលពាក់ព័ន្ធ។ បើព្រះរាជអាជ្ញាយល់ថា មិនសមស្របលោកជំទាស់មកខ្ញុំចុះ។

[១០:២៥:៥៨]

ប៉ុន្តែបន្ទាត់នៅខាងក្រោមម៉ោង ១១:៤៦ ហើយនិងទំព័រ៦៤ បន្ទាត់ទី២ “ថាតើនៅពេលដែល យើងសួរទៅដល់ប្រតិបត្តិការហ្នឹង គឺយើងចូលទៅប្រវត្តិសាស្ត្រទាំងមូលរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលខ្ញុំមិនមានការអះអាងគឺថា មានប្រភពអ្វីដែលពិតប្រាកដនោះទេ។ ប៉ុន្តែខ្ញុំគិតថា មនុស្សភាគច្រើន នៅក្នុងសវនាការនេះបានសិក្សាដោយយកចិត្តទុកដាក់ ហើយក៏មានគំនិតថ្មីជានិច្ចជាកាល”។ ពិនិត្យ មើលចម្លើយរបស់លោកបន្តិចពីព្រោះថា ខ្ញុំគិតថា ដូចជាវាមានលក្ខណៈទូលាយ។ គេសួរថា អំពីវិធី

ដែលបក្ស -- អំពីតួនាទីរបស់បក្សនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែលោកចាប់ផ្តើមឆ្លើយ "ខ្ញុំប្រាថ្នាចង់ឱ្យខ្ញុំឆ្លើយហ្នឹងបាន បានន័យថា ខ្ញុំអង្គុហាហ្នឹងគឺថាលោកមិនមានអ្វីនៅក្នុងគំនិតទេ អាមួយជាទ្រឹស្តី អាមួយជាកើតឡើងនៅក្នុងការអនុវត្ត"។ នេះជាអ្វីចម្លើយដែលលោកមិនច្បាស់លាស់ លោកមិនបានត្រៀមឆ្លើយឬ? តាមលទ្ធភាពចម្លើយដែលលោកឆ្លើយក្នុងសំណួរនេះ ហេតុអីក៏អ៊ីចឹង?

[១០:២៧:៣៤]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតបនឹងសំណួរ! ស្តាប់សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា និងការសម្រេចរបស់អង្គជំនុំជម្រះជាមុនសិន។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ចារីក៖**

ឥឡូវនេះយើងមានបញ្ហាទាក់ទងទៅនឹងសំណួរដែលសួរក្រៅពីបរិបទ។ ក្រៅពីនេះបើសិនជាមេធាវីចង់ផ្តល់ឱ្យលោក ឆេនដ័ល័រ នូវប្រតិចារឹកលើក្រដាសឱ្យគាត់បានអាន ឬបង្ហាញលើអេក្រង់ គឺថាមេធាវីគាត់ផ្តោះឡើង ផ្តោះចុះនៅក្នុងអត្ថបទហ្នឹង ចម្លើយនោះ គឺចម្លើយរបស់គាត់គឺបានកម្រិតណាស់ទាក់ទងទៅនឹងការពិភាក្សា ថាតើលក្ខន្តិកៈហ្នឹងគឺឆ្លុះបញ្ចាំងនូវការអនុវត្តដែរ ឬអត់? គាត់ឆ្លើយនៅក្នុងបរិបទនេះទេ ដែលគាត់បានពន្យល់ថា ឯកសារហ្នឹងគឺមិនដែលបានទទួលខ្លឹមសារទេ គឺជាឯកសារទាំងស្រុងដែលថា ចម្លើយរបស់គាត់។ បើសិនជាលោកអានចម្លើយទាំងអស់នេះ ហើយតុលាការបានជួយនៅក្នុងការថា បើយកពាក្យណាចេញពីប្រធានបទប្រាសចាកហ្នឹង គឺថា សួរដេញដោលលោកសាស្ត្រាចារ្យហ្នឹង គឺថាដើម្បីប្រតិចារឹកហ្នឹង គឺថាយើងមានបីភាសាហ្នឹង គឺថា ៤០០ទំព័រជាង។

[១០:២៨:៤៧]

ដូច្នេះ គឺថាគាត់គប្បីតែសាស្ត្រាចារ្យបានអានចម្លើយរបស់គាត់ជា -- ទាំងស្រុងនៅលើក្រដាស ឬក៏លើអេក្រង់មុននឹងគាត់ឆ្លើយនោះបាទ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមឆ្លើយដោយសង្ខេបទៅសហព្រះរាជអាជ្ញា។ យើងមានវិធីពីរហ្នឹងដែលត្រូវដើរ យើងអាចឱ្យសហព្រះរាជអាជ្ញា គឺថានៅក្នុងការសួរផ្ទាល់ទៅលើ -- នោះហើយទុកឱ្យមេធាវីការពារស្ថិតនៅក្នុងប្រព័ន្ធស៊ីវិលឡ ប៉ុន្តែខ្លួនៗប្រើប្រព័ន្ធណាមួយ ខាំមិនឡ។ អាហ្នឹងខ្ញុំថា យើងចំណាយពេលពីរបីថ្ងៃកន្លង

មកនេះ យើងត្រូវធ្វើ ហើយខ្ញុំមិនជំទាស់ទេ អ្វីដែលថាខ្ញុំនឹងជូនទៅឯកសារទៅសាក្សីនូវប្រតិចារឹកទាំងមូលនោះ។ ប៉ុន្តែខ្ញុំយល់ថា -- ហើយយើងបានផ្តល់អត្ថបទនៅលើអេក្រង់រួចហើយ។ ខ្ញុំគិតថា មន្ត្រីសំណុំរឿងរបស់យើងបានធ្វើហើយ បើសិនជាមិនបានទេ សូមអភ័យទោស ហើយខ្ញុំមិនមានចេតនាចង់ឲ្យមានការភ័ន្តច្រឡំនោះទេ។

[១០:២៩:៥៤]

នៅក្នុងបរិបទនេះ ដែលសហព្រះរាជអាជ្ញាលើកថា ខ្ញុំដកពាក្យខុសបរិបទនោះ សំណួរដែលខ្ញុំចង់សួរនេះ គឺថា -- ហើយគឺចម្លើយរបស់គាត់ផ្អែកទៅលើអ្វីជាអង្គហេតុដែលបង្កើតនោះឯង។ នេះហើយជាសំណួររបស់ខ្ញុំ គឺក្នុងបរិបទ។ ដូច្នេះតើតុលាការអនុញ្ញាតឲ្យសាក្សីលោកឆ្លើយដែរឬទេ? បាទសូមអនុញ្ញាត។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣០:៤២]

**ប្រធានអង្គជំនុំ៖**

បាទអម្បាញ់មិញនេះ យើងឃើញថា -- កត់សម្គាល់ឃើញថា មតិយោបល់ដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញា គឺត្រឹមត្រូវហើយ។ ហើយដោយមេធាវីផ្អែកលើថាអ្នកជំនាញបានពិនិត្យមើលឯកសារនៅលើអេក្រង់កុំព្យូទ័រ ដែលបង្ហាញដោយជំនួយការរបស់គាត់ ប៉ុន្តែឯកសារនេះគឺពិបាកតាមដានដោយសារម្តងជាភាសាអង់គ្លេស ហើយម្តងជាភាសាខ្មែរ ម្តងជាភាសាអង់គ្លេស ហើយលោកមេធាវីផ្អែកលើជាភាសាអង់គ្លេស ដើម្បីរៀបចំសំណួរផ្សេងៗ។ ដូច្នេះដើម្បីឲ្យតទៅមុខនេះឲ្យបានច្បាស់លាស់ សូមឲ្យលោកផ្តល់នូវឯកសារដែលលោកមានបំណងក្នុងការសួរដេញដោលអ្នកជំនាញហ្នឹងជាក្រដាសជូនទៅអ្នកជំនាញ ដើម្បីឲ្យអ្នកជំនាញពិនិត្យទីមួយ។ ទីពីរ គឺបរិបទជាក់លាក់ដែលមានការពាក់ព័ន្ធសូមយោងចង្អុលបង្ហាញឲ្យបានច្បាស់លាស់ ហើយប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ ហើយនិងជាក់ច្បាស់ ដើម្បីឲ្យអ្នកជំនាញហ្នឹងយល់អំពីគោលបំណងនៃការតាំងសំណួរ ដើម្បីមានលទ្ធភាពក្នុងការឆ្លើយតបបានត្រឹមត្រូវ ចៀសវាងច្បិចយកចំណុចបន្តិចបន្តួច ឬក៏ចំណុចដែលមិនពេញលេញយកមកតាំងសំណួរដេញដោលចំពោះអ្នកជំនាញ ធ្វើឲ្យមានការភាំង មិនអាចចងចាំបានទេ។ ភាគីពាក់ព័ន្ធទាំងអស់យើងយល់ថា បរិបទនៃការសួរដេញដោលអ្នកជំនាញប៉ុន្មានថ្ងៃកន្លងមកនេះ ចាំមិនអស់ទេ។ សូម្បីតែគ្រប់គ្រងសំណួរច្រំដែលនេះ គឺយើងគ្រប់គ្រងមិនបានផង។

[១០:៣២:២៥]

ដូច្នេះសូមមានការចាប់អារម្មណ៍នៅក្នុងអំឡុងពេលនេះ សូមផ្តល់ឯកសារជាក្រដាសជូនលោកសាស្ត្រាចារ្យ ដើម្បីពិនិត្យ ហើយជាបន្តទៅទៀត ពេលដែលចូលមកវិញ គឺសូមឲ្យរៀបចំនូវការ -- នូវសំណួរសមស្របដោយផ្អែកលើមូលដ្ឋាននៃបន្ទាត់ ឬក៏កថាខណ្ឌដែលពាក់ព័ន្ធ ដើម្បីរៀបចំសំណួរ ដើម្បីសាស្ត្រាចារ្យលោកបានមើល ហើយនិងបានឆ្លើយតបត្រឹមត្រូវ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាយើងនឹងបន្តក្រោយពីឈប់សម្រាក ហើយប្រហែលជាឥឡូវយើងដល់ពេលឈប់សម្រាក ឬមួយក៏យ៉ាងម៉េចដែរ? ហើយខ្ញុំសង្ឃឹមថា ខ្ញុំនឹងបន្តរហូតដល់ពេលម៉ោងដប់មួយ ហើយប្រហែលជាត្រូវការពេលបួនប្រាំនាទីបន្ថែម ហើយខ្ញុំនឹងផ្តល់ឯកសារជាក្រដាសជូនដល់លោកអ្នកជំនាញ ហើយខ្ញុំសូមទោសដែលថាមិនមានបង្ហាញឯកសារ ឬក៏មានបង្ហាញមិនច្បាស់លាស់នៅលើអេក្រង់ ហើយប៉ុន្តែឥឡូវយើងគួរតែឈប់សម្រាកសិន ឬមួយក៏ -- ហើយក្នុងពេលដែលឈប់សម្រាកនេះ ខ្ញុំនឹងធ្វើការរៀបចំនូវការសួរដេញដោលរបស់ខ្ញុំ ហើយខ្ញុំនឹងរៀបចំវាឲ្យបានល្អប្រសើរកុំឲ្យមានការជាន់។

[១០:៣៣:៥១]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីទំនងត្រូវការពេលវេលាប៉ុន្មានទៀត ក្រុមការពារក្តីរបស់លោកក្នុងការតាំងសំណួរចំពោះអ្នកជំនាញ?

**លោក ម៉ៃខល កាណាវាស៖**

នេះជាសំណួរដ៏ល្អលោកប្រធាន។ ខ្ញុំគិតថា យើងប្រហែលជាចាប់ផ្តើមយឺតប្រហែល១៥នាទីនៅព្រឹកនេះ ហើយខ្ញុំរំពឹងថាតាមការគណនារបស់ខ្ញុំ គឺការបែងចែកពេលពីរថ្ងៃកន្លះមកខាងមេធាវីការពារក្តីនោះ គឺខ្ញុំប្រហែលជាត្រូវការពេលវេលា -- តាមការគណនា គឺខ្ញុំសូមពេលប្រហែលរហូតដល់ម៉ោងដប់ពីរ និងប្រាំពីរនាទី គឺយឺតប្រាំពីរនាទីមុន -- អ៎! ក្រោយពេលបាយ។

ដូច្នេះក្រោយពីឈប់សម្រាក យើងនិងពិភាក្សា ហើយខ្ញុំគិតថាប្រសិនបើខ្ញុំមានពេលវេលាកន្លះម៉ោងបន្ថែមនៅពេលរសៀលទៀត ប្រហែលជាល្អ។ ដូច្នេះ ខ្ញុំគិតថាយ៉ាងច្រើនបំផុតត្រឹម៣០នាទីនៅពេលរសៀលនេះទៀត គឺគ្រប់គ្រាន់ណាស់ទៅហើយ។

[១០:៣៥:០០]

បើតាមដែលខ្ញុំប្រាប់ តាមគេប្រាប់ ខ្ញុំមានពេលរហូតដល់ម៉ោងពីរសាមសិបប្រាំនៅពេលរសៀល ដូច្នេះខ្ញុំសូមត្រឹមតែ៣០នាទីក្រោយពេលបាយ។ ដូច្នេះ តាមការគណនារបស់ខ្ញុំ ដែលអង្គជំនុំជម្រះឲ្យពេលពីរថ្ងៃកន្លះហ្នឹង គឺប្រហែលជាបែបនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ចុះក្រុមមេធាវីខៀវ សំផន វិញ តើត្រូវ -- ទំនងជាប្រើប្រាស់ពេលវេលាប៉ុន្មានដែរ?

**លោក អាកទ្ធរ វែកគែន៖**

បាទ លោកប្រធាន បើតាមការគណនាបែបគណិតវិទ្យា ដែលសហភាតាខ្ញុំបានលើកឡើងអម្បាញ់មិញ គឺថាយើងត្រូវការពេលដល់ -- គឺយើងមានសិទ្ធិប្រើដល់ថ្ងៃស្អែកពេលថ្ងៃត្រង់ ដើម្បីសួរសំណួរទៅលោកសាស្ត្រាចារ្យ ឆេនដ៍ល័រ។ ក៏ប៉ុន្តែ បើសិនជាអង្គជំនុំជម្រះឲ្យយើងប្រើពេលវេលាទាំងអស់នេះឲ្យអស់នោះ ខ្ញុំមិនដឹងទេ។ ព្រោះថាយើងវិវត្តន៍ទៅតាមសំណួរដែលសហភាតាយើងចោទសួរនេះ។ អ៊ីចឹង ហើយជាទូទៅ ខ្ញុំព្យាយាមកុំឲ្យចោទសំណួរដដែលៗ ហើយដោយអាស្រ័យទៅតាមសំណួរដែលគេកំពុងចោទនេះ។ អ៊ីចឹង ធ្វើយ៉ាងណាឲ្យបានប្រសើរអស់ពីលទ្ធភាព។

ក៏ប៉ុន្តែទោះបីជាយ៉ាងណាក្តី តាមផ្នែកបច្ចេកទេស គឺយើងបានគ្រោងធ្វើថារហូតដល់ពេលស្អែកថ្ងៃត្រង់។ សូមអរគុណលោកប្រធាន។

[១០:៣៦:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មូលហេតុដែលអង្គជំនុំជម្រះចង់ដឹងនូវពេលវេលាដូច្នេះ ពីព្រោះព្រឹកមិញលោកភាគីទាំងអស់ និងសាធារណជនបានជ្រាបហើយ យើងបានបម្រុងទុកនូវសាក្សី ដើម្បីបន្តកិច្ចដំណើរការនីតិវិធីនៅក្នុងចុងសប្តាហ៍នេះ ហើយដើម្បីរៀបចំនូវកិច្ចដំណើរការស្តាប់សក្ខីកម្មសាក្សីបន្តឲ្យមានប្រសិទ្ធភាព។ នេះគឺជាការ -- មូលហេតុនៃការចង់ដឹងអំពីពេលវេលានៃកិច្ចដំណើរការពិភាក្សាដេញដោលនេះ។ ប្រសិនបើអាចលឿនមុនគ្រោងទុកនេះ អង្គជំនុំជម្រះនឹងចាត់វិធានការសមស្រប ដើម្បីស្តាប់បន្ត ដោយការស្តាប់សក្ខីកម្មសាក្សី ដែលបានបម្រុងទុក។

[១០:៣៧:២០]

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកដល់អ្នកជំនាញ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១០:៤៨ នាទី ដល់ម៉ោង ១១:០២ នាទី)*

[១១:០២:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក អៀង សារី បន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់បញ្ហាមួយចំនួន។ ទីមួយ គឺការតាំងសំណួរឆាប់រហ័សពេករបស់លោកមេធាវី ម៉ៃខល កាណាវាស សូមឲ្យលោកមេធាវីធ្វើឲ្យមានការឃ្លាតគ្នាបន្តិចរវាងការឆ្លើយរបស់លោកសាស្ត្រាចារ្យ ហើយនិងសំណួរថ្មីដែលលោកនឹងតាំងសំណួរ។ ហើយបញ្ហានេះដើម្បីសម្រួលឲ្យកាន់តែល្អនោះ ទំនងជារាល់ការតាំងសំណួរនីមួយៗ លោកគប្បីផ្តាច់នូវមីក្រូហ្វូនរបស់លោកសិនទៅ ដើម្បីជាបង្កស្ថានភាពមួយឲ្យមានការឃ្លាតគ្នាបន្តិច។ បើពុំដូច្នោះទេ គឺអ្នកបកប្រែ បកប្រែមិនទាន់ទេ វាបាត់នូវខ្លឹមសារនៃកិច្ចពិភាក្សាដេញដោល។ ហើយបញ្ហាទីពីរ ដោយសារ -- បើសិនជាបានផ្តល់នូវឯកសារជាភាសាអង់គ្លេសទៅជូនលោក សាស្ត្រាចារ្យហើយនោះ សូមឲ្យជំនួយការបង្ហាញនូវឯកសារជាក្រដាស -- ជាឯកសារជាភាសាខ្មែរ នៅលើអេក្រង់កុំព្យូទ័រនៅក្នុងអំឡុងពេលនៃការពិភាក្សាដេញដោល។

អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅមេធាវីការពារក្តីលោក អៀង សារី បន្តការតាំងសំណួរដេញដោលចំពោះសាក្សី -- ចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

[១១:០៤:៣២]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមបញ្ជាក់ថា អ្វីដែលខ្ញុំបានប្រគល់ជូនទៅលោកសាស្ត្រាចារ្យ ឆេនដ៍ល័រ គឺយើងបានប្រគល់នូវប្រតិចារឹកមួយផ្នែកដែលមានពីទំព័រ៦១, ៦២ គឺផ្នែកដែលយើង -- អ្វីដែលយើងបានពិភាក្សាពីព្រឹកនេះ គឺខ្ញុំមិនបានប្រគល់ជូនគាត់ទេ ដើម្បីកុំឲ្យខាតពេល។ ដូច្នេះ គាត់ពិនិត្យមើលទៅលើប្រតិចារឹក ឬក៏ទៅលើចំណុចណាមួយនៅក្នុងប្រតិចារឹកប្រសិនបើ លោកសាស្ត្រាចារ្យចង់មើល។

មុននឹងយើងឈប់សម្រាក គឺយើងបានពិភាក្សាពីចំណុចមួយ គឺត្រង់ចំណុចដែល -- ខ្ញុំចង់ឲ្យលោកសាស្ត្រាចារ្យមើលទំព័រ៦៣។ ទំព័រ៦៣ នៃប្រតិចារឹក គឺលោកនឹងឃើញនូវត្រង់ចំណុច មួយនៅខាងលើពេលវេលា ១១:៥៤ គឺនៅជួរដែលគេសួរថា "តើលោកអាចពន្យល់អំពីតួនាទីរបស់ បក្សកុម្មុយនីស្តកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?" ហើយនៅពេលនោះ គឺមានការជំទាស់ពីព្រះរាជអាជ្ញា។ ហើយសួរថាតើនៅក្នុងបរិបទណាមួយដែលគេសួរ ឬក៏និយាយពីចំណុចទាំង អស់នេះ ហើយលោកអាចឃើញនូវទំព័រមុន។ ហើយផ្នែកដែលខ្ញុំអាននេះ គឺចាប់ផ្តើមនៅត្រង់ចំណុចដែលមានជួរទីបួន គឺផ្នែកទីមួយនៃប្រយោគដែលលោកនិយាយថា៖ "ខ្ញុំគិតថា -- ខ្ញុំប្រហែលជាមិនអាច" ហើយសំណួរនោះលោកនិយាយថា៖ "បក្សគឺដំណើរការដោយ--" និយាយថា លោក ប្រើប្រាប់ ពាក្យត្រឹម -- "នៅក្នុងពាក្យជាក់ស្តែងមិនមែនជាពាក្យ ដែលមិនជាក់ស្តែងនោះឡើយ"។ ដូច្នេះ នេះជាអ្វីដែលខ្ញុំចាប់អារម្មណ៍។ គឺខ្ញុំចង់និយាយអំពីការអនុវត្តជាក់ស្តែង ឬការអនុវត្តដែលធ្វើឡើងពិតប្រាកដនោះ តើយ៉ាងម៉េចដែរ?

[១១:០៧:០៥]

**លោក ឆេរីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំមិនប្រាកដថាតើនេះជាសំណួរ ឬមួយក៏យ៉ាងម៉េចនោះទេ។

**ស៖** ឥឡូវនេះខ្ញុំសូមនិយាយឲ្យច្បាស់អំពីសំណួរនេះ គឺទាក់ទងទៅនឹងដំណើរការនីតិវិធី។ ស្របទៅតាមអ្វីដែលខ្ញុំបានលើកឡើងពីមុនមកនេះ តើលោកយល់ឃើញយ៉ាងម៉េចដែរ? ថាតើអ្វីៗដែលបានកើតឡើង ឬក៏ការដំណើរការប្រតិបត្តិនៅក្នុងឆ្នាំ៧៥ ដល់៧៩ នោះ តើលោកមានទ្រឹស្តីនៅក្នុងឯកសារ ឬក៏ភស្តុតាងណាមួយនៃលក្ខន្តិកៈដែរឬទេ? ហើយថាតើទ្រឹស្តីហ្នឹងវាផ្ទុះបញ្ចាំងពីការអនុវត្តជាក់ស្តែងអំពីឋានៈក្រោមយ៉ាងម៉េចដែរ? គឺសូមលោកឆ្លើយដោយផ្អែកទៅតាមការស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្ររបស់លោក។ សូមអញ្ជើញ!

[១១:០៨:០៧]

**ឆ៖** ជាទូទៅគឺតែងតែមាននូវគម្លាតអំពីការលើកឡើង អំពីលក្ខន្តិកៈរបស់បក្សកុម្មុយនីស្ត ធៀបជាមួយនឹងការអនុវត្តជាក់ស្ដែង។ យ៉ាងណាក៏ដោយខ្ញុំពិនិត្យមើលទៅលើឯកសារនៃការសម្ភាស ដែល - - ទូទៅការសម្ភាសបង្ហាញថា មានគម្លាតរវាងលក្ខន្តិកៈ និងការអនុវត្តជាក់ស្ដែង។ ដូច្នេះអានេះគឺជាវាមានគម្លាតគ្នារវាងអ្វីដែលបានធ្វើ និងអ្វីដែលបានទទួល។

**ស៖** បន្តពីចំណុចមុន គឺនៅទំព័រទី៦៤ គឺចម្លើយរបស់លោក លោកបានឆ្លើយថា "ពិតហើយ" ចម្លើយរបស់លោក គឺនិយាយអំពីការប្រតិបត្តិ។ ប្រសិនបើយើងនិយាយអំពីការប្រតិបត្តិ គឺយើងត្រូវមើលអំពីប្រវត្តិសាស្ត្រជារួមរបស់បក្សកុម្មុយនីស្តកម្ពុជា។ ប៉ុន្តែ ខ្ញុំមិនមានការអះអាងឲ្យជាក់ស្ដែងណាមួយអំពីសិទ្ធិអំណាចនោះឡើយ ដែលថាគ្មានអ្នកម្នាក់នៅក្នុងកន្លែងនេះអាចសិក្សាឲ្យបានច្បាស់ ហើយអាចស្វែងរកនូវគំនិតថ្មី។ ដោយផ្អែកទៅលើចម្លើយនេះ ប្រសិនបើយើងធៀបជាមួយនឹងចម្លើយរបស់លោកដែលឆ្លើយពីមុនមក គឺថាដោយសារតែមានគម្លាតបែបនេះហើយ គឺគម្លាតពីទ្រឹស្តី ធៀបជាមួយនឹងការអនុវត្តជាក់ស្ដែងនោះ អ្វីដែលយើងបានដឹង គឺផ្អែកទៅលើគម្លាតដែលមានបង្ហាញនៅក្នុងភស្តុតាងជាក់ស្ដែង។ ដោយសារហេតុនេះហើយឬ ទើបលោកនិយាយថាវាមាននូវហេតុការណ៍ ឬក៏មាននូវការវិវត្តន៍ ប្រែប្រួលនៅក្នុងការណ៍ទាំងអស់នេះ?

[១១:០៩:៥៦]

**ឆ៖** ពិតហើយ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំនឹងបន្តទៅមុខពីរបីទំព័រ គឺបន្តទៅ ទំព័រ៧៩ គឺមានចម្លើយជាច្រើនដែលលោកត្រូវឆ្លើយដោយធៀបទៅនឹងទំព័រ៧៦ វិញ។ នៅពេលដែលគេសួរអំពីមាត្រា៣ និងមាត្រា៦ នៃឯកសារដែលបានលើកមកពិភាក្សា។ គឺលក្ខន្តិកៈបក្ស ហើយនៅក្នុងបរិបទនោះ ខ្ញុំ -- ឥឡូវនេះ ខ្ញុំសូមផ្ដល់ឱកាសឲ្យលោកអានសិន ប៉ុន្តែខ្ញុំចង់ផ្ដោតឲ្យលោកចាប់អារម្មណ៍ទៅលើចំណុចនេះ ហើយនិងសូមសួរមតិយោបល់របស់លោក។

នៅទំព័រទី៧៩ គឺក្រោមម៉ោង ១៣:០៧:៤៥ គឺនិយាយថា "ថាតើការ -- ទាំងអស់នេះវាឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្ដែងរបស់កម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ឬមួយក៏យ៉ាងណា?" ហើយលោកឆ្លើយថា "ខ្ញុំមិនអាចឆ្លើយឲ្យបានច្បាស់លាស់ទេអំពីបញ្ហាទាំងអស់នេះ"។ ហើយឆ្លងកាត់រយៈពេលកន្លងមកនេះគឺលោកបាននិយាយ។ ហើយនៅជួរទី១៤ គឺលោកនិយាយថា "គ្មាន -- ខ្ញុំគិតថា

មិនមានចម្លើយណាមួយជាប្រព័ន្ធនោះឡើយ”។ ហើយចុះក្រោមបន្តិចទៀតនោះ គឺនៅក្រោមពេល ១៣:៣៩ គឺលោកនិយាយថា “ក្រុមមេដឹកនាំ គឺក្រុមអ្នកដឹកនាំដែលមានលក្ខណៈជាសមូហភាព ហើយក្រុមនេះ -- ហើយខ្ញុំពិបាកអានណាស់មើលទៅឯកសារនេះ។ ដោយសារតែវាផ្ទុះបញ្ចាំងពីការអនុវត្តជាក់ស្តែង ដូច្នេះវាពិបាកក្នុងឆ្លើយ”។

[១១:១២:១៥]

ទៅតាមការអានរបស់ខ្ញុំ ទៅតាមការស្តាប់សក្ខីកម្មរបស់ខ្ញុំ អ្វីដែលចង់និយាយគឺថា លោកមិនទទួលបានព័ត៌មានគ្រប់គ្រាន់ដោយសារខ្វះឯកសារ ខ្វះភស្តុតាង ឬក៏ដោយខ្វះនូវប្រភពព័ត៌មាន ពីអ្នកដទៃគឺប្រភពព័ត៌មានចម្បង លោកមិនអាចផ្តល់នូវមតិយោបល់ទាក់ទងទៅនឹងការអនុវត្តធៀបជាមួយនឹងទ្រឹស្តី ជាពិសេសចំពោះមាត្រា៣ និងមាត្រា៦ ដែលបានលើកឡើងនៅក្នុងសំណួរនេះ។ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំទាន់អាលឆ្លើយតប មានការជំទាស់តំណាងសហព្រះរាជអាជ្ញា។

សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកសាស្ត្រាចារ្យ ខ្ញុំចង់និយាយដូចគ្នានឹងអ្វីដែលលោកបាននិយាយអ៊ីចឹង គឺខ្ញុំងើបឈរនេះ គឺខ្ញុំចង់និយាយបែបនេះ។ យើងព្យាយាមទប់ទល់មិនប្រឆាំងទៅនឹងការលើកសំណួរនាំមុខ ប៉ុន្តែយ៉ាងណាក៏ដោយ ក៏មេធាវីមិនត្រូវធ្វើនូវបែបនេះដែរ។ ហើយដូច្នេះអានេះគឺជាអ្វីដែលខ្ញុំធ្វើការជំទាស់ ហើយអ្វីដែលមេធាវីការពារក្តីត្រូវធ្វើ គឺធ្វើការពិនិត្យទៅលើសក្ខីកម្ម ហើយខ្ញុំគិតថាវិធីសាស្ត្រក្នុងការសួរបែបនេះ អាចអនុញ្ញាតឲ្យធ្វើនៅតុលាការផ្សេង តែមិនអនុញ្ញាតឲ្យធ្វើនៅតុលាការនេះទេ។

[១១:១៣:៥២]

**លោក ម៉ៃខល កាណាវាស៖**

នេះ ខ្ញុំសូមឆ្លើយតបទៅលើអ្វីដែលព្រះរាជអាជ្ញាលើកឡើង។ ខ្ញុំកំពុងតែប្រើប្រាស់ពាក្យសម្តីរបស់អ្នកជំនាញ ហើយខ្ញុំព្យាយាមសុំឲ្យអ្នកជំនាញបញ្ជាក់ទៅលើចំណុចមួយចំនួន។ ដូច្នេះ ឥឡូវនេះ ខ្ញុំនឹងនិយាយសាជាថ្មី។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** នៅពេលដែលលោកនិយាយថា "ថាតើការណ៍ទាំងអស់នេះ ផ្ទុះបញ្ចាំងការអនុវត្តជាក់ស្តែងនៅប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏អត់នោះ?" លោកនិយាយថា "ខ្ញុំមិនអាចឆ្លើយតបបានទេ ព្រោះខ្ញុំមិនមានគំនិត ព្រោះថាអ្វីៗ -- ខ្ញុំមិនអាចបញ្ជាក់ថាតើត្រូវ -- ថាតើមានការគោរពនូវគ្រប់ឋានៈដែរឬអត់នោះទេ"។ ដូច្នេះ អ្វីដែលខ្ញុំចង់សួរ ថាតើលោកនៅតែប្រកាន់ជំហរបែបនេះ ឬក៏លោកនៅតែគាំទ្រការឆ្លើយបែបនេះ ឬយ៉ាងណា?

[១១:១៤:៤៣]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** គឺការពិតហើយ ខ្ញុំនៅគាំទ្រនូវអ្វីដែលខ្ញុំនិយាយ ហើយខ្ញុំគិតថា គ្មាននរណាម្នាក់អាចបញ្ជាក់ឲ្យបានច្បាស់អំពីការ ដំណើរការនៅគ្រប់ពេល នៅគ្រប់ឆ្នាំ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ។ ដូច្នេះហើយ ខ្ញុំមិនប្រាកដថា ខ្ញុំអាចនឹងរៀបរាប់ ឬក៏អាចសរសេរឲ្យបានលម្អិតទៅលើប្រវត្តិនៃប្រទេសកម្ពុជានៅពេលនោះឡើយ។ ប៉ុន្តែយ៉ាងក៏ដោយ វាមាននៅគម្លាតរវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជានៅពេលនោះ។ ប៉ុន្តែយ៉ាងណាក៏ដោយការឃ្លាតគ្នានេះ គឺមានបញ្ជាក់យ៉ាងច្បាស់។

[១១:១៥:២២]

**ស៖** លោកមិនចាំបាច់ការពារខ្លួនខ្លាំងដល់ថ្នាក់នេះទេ លោកគ្រាន់តែបង្ហាញអំពីសំណួរ ឬក៏ឆ្លើយទៅសំណួរទាំងអស់នេះទៅ។ ខ្ញុំមិនមានការតឹងតែងជាមួយលោកនោះទេ លោកសាស្ត្រាចារ្យ។ តាមចម្លើយរបស់លោក គឺដូចដែលលោកបាននិយាយអ៊ីចឹងនៅគ្រប់កម្រិត និងនៅគ្រប់ឆ្នាំតាមផ្នែកនេះ គឺលោកចង់និយាយថា អ្វីៗមានការប្រែប្រួលទៅតាមពេលវេលា តើមែនដែរឬទេ? ថាតើខ្ញុំបកស្រាយបែបនេះ ត្រឹមត្រូវដែរឬទេ? តើលោកចង់និយាយថា អ្វីដែលកើតឡើងនៅ ៧៥ គឺវាអាចមានលក្ខណៈខុសនៅក្នុងឆ្នាំ៧៦, ៧៧ ឬក៏ ៧៨ ព្រោះថា ដោយសារតែលក្ខណៈនៃសំណួរវាមានលក្ខណៈទូលំទូលាយ លោកមិនបានផ្តល់នូវចម្លើយដែលលម្អិត តើមែនដែរឬទេ?

**ឆ៖** ប្រសិនបើខ្ញុំមើលទៅមានលក្ខណៈដូចជាការពារខ្លួនខ្លាំង ខ្ញុំសូមទោស ប៉ុន្តែខ្ញុំមិនមែនចង់ធ្វើបែបនេះទេ។ ឥឡូវនេះ ខ្ញុំសូមនិយាយ -- ហើយខ្ញុំសូមនិយាយដដែលៗឡើងវិញថា គឺវាមានបដិវត្តន៍នៅក្នុងរបប ក៏ដូចជាបដិវត្តន៍នៅក្នុងរបបទាំងមូលតែម្តង។ ហើយវាមានដំណាក់កាលផ្សេងៗ

គ្នា ឧទាហរណ៍ដូចជា ៧៥ ដល់ខែមេសា ៧៦ គឺមានការបោសសម្អាត ហើយមានការចូលរបស់វៀតណាម ហើយនិងមានព័ត៌មានផ្សេងៗបន្តទៅទៀត មានការផ្លាស់ប្តូរពីខ្លាំងមួយទៅខ្លាំងមួយទៀត ហើយដូច្នេះហើយគឺមានការប្រែប្រួលពីពេលមួយទៅពេលមួយ ពីរយៈពេលមួយទៅរយៈពេលមួយ។

[១១:១៧:០៤]

**ស៖** គោលដៅដែលយើងចង់បាន គឺចង់ឱ្យមានការបញ្ជាក់លម្អិតបែបនេះ។ ហើយខ្ញុំសូមសន្និដ្ឋានថា តាមចម្លើយរបស់លោក គឺថាការប្រែប្រួលនោះគឺវាធ្វើឡើងនៅគ្រប់កម្រិតទាំងអស់។ បានន័យថា ចាប់ពីថ្នាក់ក្រោមរហូតដល់ថ្នាក់កំពូល តើមែនទេ? បានន័យថា ផ្អែកទៅលើចម្លើយដែលលោកចង់ -- ដែលលោកបានឆ្លើយនេះ?

**ឆ៖** ខ្ញុំមិនបាននិយាយថា គ្រប់កម្រិតនោះទេ គ្រាន់តែថាមានការធ្វើបដិវត្តន៍ មានការប្រែប្រួលប៉ុណ្ណោះឯង។ ប៉ុន្តែមិនមែនបានន័យថា គ្រប់កម្រិត គ្រប់លំដាប់ថ្នាក់នោះទេ។

[១១:១៧:៤៥]

**ស៖** ខ្ញុំមិនមែននិយាយអំពីបុគ្គលទេ ខ្ញុំនិយាយអំពីស្ថាប័នផងដែរ។ ដូច្នេះ ខ្ញុំចង់និយាយទាំងបុគ្គលនិងស្ថាប័ន ថាតើមានការប្រែប្រួល មានការផ្លាស់ប្តូរដែលលោកអាចប្រមើលមើលឃើញថាមាននៅក្នុងឆ្នាំ៧៥ មានការផ្លាស់ប្តូរ មានការប្រែប្រួលខ្លាំងនៅក្នុងឆ្នាំ៧៦, ៧៧ និង៧៨។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំគិតថា ខ្ញុំនឹងផ្តល់នូវចម្លើយដូចគ្នា គឺថាអ៊ីចឹងមែន។

**ស៖** ខ្ញុំគិតថា ខ្ញុំគួរតែផ្អាកនិយាយបន្តិចដើម្បីឱ្យអ្នកបកប្រែស្រួល។ នៅទំព័រ៩២ ខ្ញុំសូមលើកនៅចំណុចកណ្តាលនៃសំណួរគឺនៅទំព័រទី៩១ គេចោទសួរលោកថា -- សំណួរនៅជួរទី១៣ នៃទំព័រ៩១ នៅក្រោមម៉ោង ១៤:០៦:៤០ គឺនិយាយអំពីមាត្រា២៣ និយាយអំពីគណៈមជ្ឈិម ហើយសំណួរបានបន្តរហូតមកដល់ទំព័របន្ទាប់គឺទំព័រ៩២ នៅជួរទីបី។ ហើយសួរលោកថា "តើលោកអាចផ្តល់មតិ ថាតើនៅក្នុងការអនុវត្តជាក់ស្តែងគណៈ -- តើការអនុវត្តជាក់ស្តែងគឺវាដូចគ្នានឹងការចែងនៅក្នុងមាត្រា២៣ នេះដែរឬក៏យ៉ាងណា?" ហើយលោកនិយាយថា "ការអនុវត្តជាក់ស្តែងគឺថា -- នៅជួរទីប្រាំបី ទំព័រ៩២ លោកនិយាយថា "បាទ ខ្ញុំគិតថា ខ្ញុំមិនមានលទ្ធភាពឆ្លើយសំណួរនេះឱ្យបានអស់នោះទេ។ នេះជាសំណួរដ៏ល្អ ប៉ុន្តែមិនមែនជាអ្វីដែលខ្ញុំបានសិក្សាឱ្យបានលម្អិតនោះទេ។ ខ្ញុំគិតថា វិធានក្រិត្យក្រមទាំងអស់នេះត្រូវបានគេអនុវត្តតាម។ ប៉ុន្តែមិនមែនមានន័យថា ការអនុវត្តនៅកម្រិតអង្គការនោះទេ។ ខ្ញុំគិតថា

ដូចដែលមានចែងនៅក្នុងដីកាដំណោះស្រាយដែលបានរៀបរាប់ដូច្នេះដែរ។ គឺថា ខ្ញុំទើបតែបានដឹងអំពីឯកសារដីកាដំណោះស្រាយ និងពីអង្គការទាំងអស់នេះ អំពីការរៀបចំ អំពីការដំណើរការទៅដោយល្អនោះ”។

[១១:២០:៤២]

ដូច្នេះ ឥឡូវយើងពិនិត្យមើលទៅចម្លើយរបស់លោក។ លោកបានប្រាប់យើងជាដំបូង ដោយលោកនិយាយថា លោកមិនមានលទ្ធភាពឆ្លើយទៅនឹងសំណួរទាំងអស់នេះ ទាំងការពិតជាក់ស្ដែង ដែលថាមាត្រា២៣ ត្រូវបានអនុវត្ត ដូចដែលមានចែងដែរឬក៏អត់នោះ។ ថាតើខ្ញុំបកស្រាយបែបនេះ ជាការបកស្រាយត្រឹមត្រូវទៅលើចម្លើយរបស់លោកដែរឬក៏យ៉ាងណា? លោកសាស្ត្រាចារ្យសូមចាំមួយភ្លែត។

[១១:២១:១៥]

**ឆ៖** បាទ គឺអ៊ីចឹងមែន។

**ស៖** បន្ទាប់មកលោកសាស្ត្រាចារ្យបានបញ្ជាក់អំពីចម្លើយរបស់លោក អានេះ គឺជាផ្នែកដែលខ្ញុំចង់លើកឡើង ខ្ញុំគិតថាវាមិនសំខាន់ណាស់ណាទេ។ ប៉ុន្តែខ្ញុំត្រូវតែលើកឡើង ហើយគិតថាមិនមែនជាកំហុសរបស់លោកទេ ប៉ុន្តែលោកនិយាយថា “ខ្ញុំគិតថាដូចដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយគឺជាឯកសារដែលខ្ញុំទើបដែលបានដឹង ទើបតែបានមើល”។ ឥឡូវនេះ ខ្ញុំសូមសួរលោកថា ថាតើលោកដឹងដែរឬទេ ថាដីកាដំណោះស្រាយហ្នឹងវាមានលក្ខណៈប្រហាក់ប្រហែលទៅនឹងអ្វីដែលយើងបានគិតថាលោកបានដឹង គឺថាដីកាដំណោះស្រាយហ្នឹង គឺដូចដីកាបញ្ជូនរឿងទៅជំនុំជម្រះ តើមែនដែរឬទេ? តើលោកដឹងដែរឬទេ? បើសិនជាលោកមិនដឹងទេ វាអត់បញ្ហាអ្វីទេ។

[១១:២២:១០]

**ឆ៖** ខ្ញុំសូមឆ្លើយថា ពិតហើយ។

**ស៖** នៅពេលដែលលោកនិយាយថា ដូចដែលមានចែងនៅក្នុងដីកាដំណោះស្រាយ។ នេះគឺជាផ្នែកមួយនៃចម្លើយរបស់លោក ថាតើលោកពឹងផ្អែកទៅលើអ្វីដែលលោកនិយាយហ្នឹងដោយផ្អែកទៅលើដីកាដំណោះស្រាយ តើម៉េចដែរឬទេ? គឺបានន័យថា លោកពឹងផ្អែកទៅលើដីកាដំណោះស្រាយហ្នឹងដោយផ្ទាល់តែម្ដង?

**ឆ៖** ពិតហើយ គឺថាខ្ញុំផ្អែកទៅលើផ្នែកមួយចំនួននៅក្នុងដីកាដំណោះស្រាយ។

**ស៖** សូមអរគុណ។ ដូច្នេះហើយ គឺខ្ញុំត្រូវលើកសំណួរឲ្យបានប្រុងប្រយ័ត្នបន្តិច។ នៅពេលដែលលោកនិយាយថា នៅក្នុងឯកសារដែលខ្ញុំទើបតែអាននៅក្នុងពេលថ្មីៗនេះ គឺនិយាយអំពីអង្គការ គឺលោកនិយាយបែបនេះ។ ដូច្នេះខ្ញុំសូមទោស ប្រសិនបើខ្ញុំសួរដដែលៗ ឬក៏ខ្ញុំសួរដេញខ្លាំងពេកនោះ។ ដូច្នេះចង់ដឹងថា តើលោកចង់មានន័យបែបណានៅពេលដែលលោកនិយាយថា ឯកសារដែលលោកទើបតែបានដឹង ទើបតែបានស្គាល់។ ឧទាហរណ៍ ថាតើជាឯកសារបេក្ខជនទាំងពីររូបដែលត្រូវធ្វើការជំនុំជម្រះ ឬមួយក៏ឯកសារណាផ្សេងទៀត។ ថាតើឯកសារណាមួយដែលលោកចង់និយាយ? ថាតើឯកសារចម្បង ឬក៏ប្រភពព័ត៌មានចម្បងដែលលោកមិនដែលដឹង ប៉ុន្តែលោកថាទើបតែឃើញ ឬក៏ទើបតែនឹងទទួលបានព័ត៌មានទាំងអស់នោះ គឺឯកសារដែលផ្តល់ឲ្យដោយអង្គជំនុំជម្រះសាលាដំបូង ឬមួយក៏យ៉ាងណាដែរ?

**ឆ៖** គឺទាំងអស់ហ្នឹង គឺឯកសារទាំងអស់ គឺឯកសារដែលផ្តល់ដោយសាលាដំបូង និងដីកាដំណោះស្រាយ។ នេះគឺជាអ្វីដែលខ្ញុំបានធ្វើ។ ប៉ុន្តែបើសិនជាលោកមើលទៅបន្តទៅទៀត គឺខ្ញុំនិយាយថា ខ្ញុំមិនចង់ឆ្លើយសំណួរនេះទេ ព្រោះថាឯកសារដែលខ្ញុំពឹងផ្អែក គឺឯកសារចម្បង គឺព័ត៌មានចម្បងដែលខ្ញុំបានធ្វើ។ ប៉ុន្តែយ៉ាងណាក៏ដោយ អានេះគឺជាសេចក្តីសន្និដ្ឋានដែលខ្ញុំធ្វើឡើង គឺនៅពេលដែលខ្ញុំឈប់សរសេរឯកសារពីកម្ពុជាប្រជាធិបតេយ្យ គឺខ្ញុំមានឯកសារជាច្រើនដែលនិយាយអំពីអង្គការ និយាយអំពីសិទ្ធិអំណាច ឬក៏ការប្រតិបត្តិរបស់អង្គការនៅក្នុងប្រទេសកម្ពុជា។

ដូច្នេះហើយ ដោយសារតែមានឯកសារថ្មីៗ ទើបខ្ញុំត្រូវអានឯកសារទាំងអស់នោះឡើងវិញ ដើម្បីឲ្យខ្ញុំដឹង។

[១១:២៤:៥៨]

**ស៖** សូមអរគុណ។ ប្រសិនបើយើងមើលទៅទំព័រ៩៥ និង៩៦ គឺម៉ោង ១៤:២៥ គឺចម្លើយដែលលោកផ្តល់ឲ្យនៅទំព័រ៩៦ គឺមិនច្បាស់លាស់។ ចម្លើយរបស់លោក គឺមិនច្បាស់លាស់។ ពីព្រោះថាដោយសារលោកមិនបានបើកមីក្រូហ្វូន ដូច្នេះហើយគឺយើងទទួលបានចម្លើយដែលមិនគ្រប់គ្រាន់។ ដូច្នេះឥឡូវនេះ ខ្ញុំសូមផ្តល់ឱកាសជូនលោក ដើម្បីជម្រាបនូវចម្លើយទៅលើសំណួរទាំងអស់នេះ។ សំណួរថាតើលោកមានភស្តុតាងណាមួយ ដែលថាមាន -- ថាតើមានការអនុវត្តហ្នឹង គឺគណៈកម្មាធិការមានសិទ្ធិយ៉ាងម៉េចដែរ? ហើយអ្វីដែលយើងទទួលបាន "ខ្ញុំមិនធ្វើការសិក្សាជាចម្បងទៅលើបញ្ហានេះទេ។ តាម

ការយល់ឃើញរបស់ខ្ញុំ គឺវាខុសពីគ្នានេះ"។ ដូច្នេះ ខ្ញុំផ្តល់ឱកាសជូនលោក ដើម្បីធ្វើការផ្តល់ចម្លើយនូវកំណត់ត្រា ថាតើចម្លើយរបស់លោកយ៉ាងម៉េចដែរ? ថាតើដូចនេះ ឬក៏ខុសគ្នានេះដែរ?

[១១:២៦:១៨]

**ឆ៖** ចម្លើយរបស់ខ្ញុំគឺនិយាយដូចគ្នានេះដែរ បើតាមដែលខ្ញុំចាំ គឺនៅក្នុងសក្ខីកម្មរបស់ខ្ញុំ គឺថាខ្ញុំបានឆ្លើយថា ខ្ញុំមិនសិក្សាឲ្យបានជាចម្បងនោះទេ ព្រោះវាមិនមែនជាផ្នែកនៃការសិក្សារបស់ខ្ញុំ។

**ស៖** គឺការពិត ខ្ញុំគ្រាន់តែចង់ឲ្យមានការបញ្ជាក់ឲ្យបានច្បាស់ទៅលើចម្លើយទាំងអស់នេះ។ ប្រហែលជានៅពេលក្រោយមកទេ យើងត្រូវការពឹកផ្អែកទៅលើសក្ខីកម្មនេះ។ ដូច្នេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់ច្បាស់ទៅលើសក្ខីកម្មរបស់លោក ហើយខ្ញុំសូមអរគុណលោកចំពោះការបញ្ជាក់។

ឥឡូវនេះ ខ្ញុំសូមឲ្យលោកចាប់អារម្មណ៍ទៅលើចំណុចមួយទៀត នៃសក្ខីកម្មរបស់លោក។ គឺយើងមើលទៅលើទំព័រ១០៩ គឺនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២។ លោកបានផ្តល់ -- គេឲ្យលោកមើលទៅលើឃ្លាមួយចំនួននៅក្នុងសៀវភៅ ដែលមានចំណងជើងថា "សំឡេងមកពីមន្ទីរស-២១" គឺលោកមើលទៅជួរទី១៧ គឺមានការដកស្រង់មួយ ដែលបន្តមកជួរ២៥ គឺនៅលើម៉ោង ១៥:១៩:០២។ ឃ្លានេះ គឺនិយាយថា --ប្រយោគនេះមានរយៈពេលខ្លី "គឺគ្មានឯកសារណាដែលមួយភ្ជាប់ ប៉ុល ពត និង អៀង សារី ទៅនឹងសេចក្តីសម្រេចដើម្បីកម្ទេចមនុស្សនៅស-២១"។ បានន័យថា មិនមានការសម្រេច ឬក៏មិនមានទំនាក់ទំនងណាមួយ ដើម្បីភ្ជាប់មន្ទីរស-២១ ទៅនឹងមន្ទីរបក្សនោះឡើយ -- មន្ទីរមជ្ឈិមនោះឡើយ។ ដូច្នេះហើយ គឺមិនមានឯកសារណាមួយបញ្ជាក់បែបនេះឡើយ។ នេះគឺជាអ្វីដែលលោកដកស្រង់ពីអត្ថបទរបស់លោក។

[១១:២៨:១៦]

ប្រសិនបើយើងមើលទៅទំព័របន្ទាប់ទៀត គឺទំព័រ១១១ គឺនៅលើ -- គឺនៅត្រង់ម៉ោង ១៥:២១:២០:៤០ (ស៊ីក) នៅជួរទី១២ លោកបាននិយាយថា គឺជាចម្លើយបន្តរបស់លោក។ ដូច្នេះ បើសិនខ្ញុំនិយាយខុស លោកអាចកែខ្ញុំបាន។ ខ្ញុំចង់ធ្វើការកែប្រែបន្តិចទៅនឹងឃ្លា -- អត្ថបទដែលដកស្រង់អម្បាញ់មិញនេះ។ ដូចដែលយើងបានដឹងអំពីករណីជំនុំជម្រះ ឌុច។ ឌុច ខ្លួនគាត់ផ្ទាល់ធ្វើការទំនាក់ទំនងជាមួយមនុស្សទាំងអស់នេះ។ គឺគាត់ធ្វើទំនាក់ទំនងជាមួយ សុន សេន ហើយនៅពេលគាត់ -- ពេលខ្លះជាមួយ នួន ជា។

[១១:២៩:១៨]

ដូច្នេះ ទំនាក់ទំនងជាមួយនឹងបុគ្គលទាំងអស់នេះ នៅខាងមជ្ឈិម គឺមិនត្រូវបានកំណត់ ហើយនៅពេលដែលខ្ញុំសរសេរសៀវភៅនោះ។ ខ្ញុំគឺមានការ -- គឺធ្វើនៅកំហុសមួយ។ ដូច្នេះ ខ្ញុំចង់និយាយថា គឺគាត់ដឹងអំពីបក្ស មជ្ឈិមបក្ស គាត់ដឹងអំពី នួន ជា ហើយនិង សុន សេន នៅក្នុងមជ្ឈិមបក្ស។ ហើយខ្ញុំ -- ហើយគាត់រាយការណ៍ទៅអ្នកទាំងពីរ។ ដូច្នេះ ការនិយាយថា ខ្ញុំរាយការណ៍ទៅមជ្ឈិមបក្សហ្នឹង គឺជាការសម្អាស។ ប៉ុន្តែតាមដែលយើងដឹង គឺតាមដែលយើងទទួលបានពីសក្ខីកម្ម គឺគាត់ឃើញតែមនុស្សម្នាក់ ឬពីរនាក់តែប៉ុណ្ណោះ។

ដូច្នេះ តាមចម្លើយដែលលោកឆ្លើយនេះគឺវាហាក់ដូចជាបង្ហាញថា តាមដែលលោក -- គឺលោកបានអាននូវសក្ខីកម្មរបស់លោក គឺលោករៀបចំនូវឃ្លាទាំងអស់នេះ ដើម្បីទទួលស្គាល់ថាលោកត្រូវការឲ្យមានការកែប្រែនូវកំណត់ត្រាដែលលោកបានសរសេរ ថាតើខ្ញុំនិយាយបែបនេះត្រឹមត្រូវដែរឬទេ?

[១១:៣០:៣៥]

**ប្រធានអង្គជំនុំ៖**

លោកសាស្ត្រាចារ្យកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំគិតថានេះគឺ មានបញ្ហាដែលយើងមិនលើកយកអត្ថបទទាំងមូលមកនិយាយ យើងយកតែមួយចំណុចៗ។ ដូច្នេះហើយតាមដែលខ្ញុំដឹងអ្វីដែលលោកសាស្ត្រាចារ្យចង់កែនៅថ្ងៃនោះ គឺចង់និយាយអំពីអ្វីដែលមេធាវីការពារក្តីគាត់អត់បានលើកយកមកនិយាយនៅពេលនេះ។ គឺគាត់និយាយអំពីការរាយការណ៍នៅមន្ទីរស-២១ ទៅគណៈមជ្ឈិម។ ដូច្នេះ នេះគឺជាការកែប្រែទៅលើបញ្ហានោះទេ។ ដូច្នេះយើងមិនគួរឲ្យមានការយល់ខុសធ្វើឲ្យលោកសាស្ត្រាចារ្យមានការយល់ខុសនោះឡើយ។

[១១:៣១:១៩]

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ខ្ញុំសូមកោតសរសើរចំពោះការបំភ្លឺនេះ ហើយគឺបង្ហាញច្បាស់នៅក្នុងឯកសារនេះហើយអ្នកជំនាញមានអត្ថបទនេះហើយ។ នេះជាផ្នែកមួយនៃសំណួររបស់ខ្ញុំ ដោយសារថាគាត់សរសេរខុសក្នុងសៀវភៅរបស់គាត់អំពីដំណើរការរាយការណ៍។ ឥឡូវនេះ យើងដឹងហើយថាគាត់បានស្តាប់សវនាការ ឌុច ហើយគាត់កែខ្លួនឯង។ តើករណីបែបនេះទេលោកសាស្ត្រាចារ្យ ឆេនដ័ល័រ?

**លោក ដេវីដ ឆេនដ័ល័រ៖**

**ផះ** ខ្ញុំមិនគិតអ៊ីចឹងទេ មានទំនាក់ទំនងទៅនឹងមជ្ឈិម គឺគាត់ទាក់ទងទៅនឹង សុន សេន ហើយ សុន សេន នៅក្នុងមជ្ឈិម។ នេះការកែតម្រូវពាក្យនោះគឺថាពាក្យថាមជ្ឈិមហ្នឹង គឺថាហៅរួម គាត់មិនទាក់ទងទៅគណៈមជ្ឈិមទាំងមូលទេ គាត់ទាក់ទងតែ សុន សេន ទេ គឺថាយើងពឹងផ្អែកទៅលើភស្តុតាង ៗ ខ្ញុំនិយាយទេគឺថា ឯកសាររាប់រយដែល ឌុច បញ្ជូនទៅ សុន សេន។ សុន សេន នៅក្នុងគណៈមជ្ឈិម ហើយឯកសារ សុន សេន ហើយក៏បញ្ជូនទៅ -- ហើយមនុស្សផ្សេងទៀតនៅក្នុងគណៈមជ្ឈិម។ សូមខ្ញុំចប់សិន។ ឥឡូវខ្សែបណ្ដោយនៅក្នុងបក្សនោះ គឺថានៅក្នុងសមាជិក ជាសមាជិកសំខាន់ៗនៃមជ្ឈិមបក្ស សុន សេន និយាយថា សុន សេន ជាមនុស្សទីបី។ ឌុច និយាយថាខ្ញុំទាក់ទងជាមួយគណៈមជ្ឈិម គឺគាត់មានន័យអ៊ីចឹង។ គាត់ថាមិនទាក់ទងទាំងអស់ទេ ប៉ុន្តែទាក់ទងមួយក្នុងចំណោមហ្នឹង។ ដូច្នេះហើយគឺថាវាន័យអ៊ីចឹង។

[១១:៣២:៤៨]

**សះ** នេះហើយចង់ឲ្យ -- ចំណុចដែលខ្ញុំចង់ឲ្យលោកពន្យល់គឺលោកមិនបាច់ការពារខ្លួនទេ មិនជាបញ្ហាអ្វីទេ។ អានេះហើយជាចំណុចដែលខ្ញុំព្យាយាមចង់ឲ្យលោកបំភ្លឺនោះ។ ដូច្នេះ នៅពេលដែលនិយាយថាមជ្ឈិមបក្ស យ៉ាងហោចណាស់ភស្តុតាងដែលលោកបានឃើញគឺ សុន សេន គឺជាសមាជិកសំខាន់។ នេះហើយជាចំណុចដែលលោកបានរៀបចំថានឹងឆ្លើយអ៊ីចឹង ឬយ៉ាងណា? ប៉ុន្តែលោកមិនចង់និយាយថាក្នុងគ្រប់ករណីទាំងអស់ថា គាត់រាយការណ៍ទៅសមាជិកទាំងអស់ដែលមិនបានបញ្ជាក់ឈ្មោះ។

**ផះ** ដូចគ្នានេះដែរ យើងមិនមានឯកសារ យើងមិនដឹងថា សុន សេន ធ្វើអ្វីជាមួយឯកសារដែលគាត់បានទទួលទេ ហើយយើងមិនមានការពិភាក្សានៅក្នុងកិច្ចប្រជុំបក្សដែលថាអាចនឹងមានឯកសារលើកឡើងពីបញ្ហាមួយចំនួន។ យើងមិនដឹងថាឯកសារហ្នឹងមានជោគវាសនាម៉េចទេ ហើយខ្ញុំឲ្យកែតម្រូវ ប្រសិនថាអាចនឹងកែតម្រូវពាក្យពេចន៍បន្តិច។ ទំនាក់ទំនងទៅនឹងមជ្ឈិមបក្ស គឺជាទំនាក់ទំនងទៅមជ្ឈិមនេះគឺជាភស្តុតាង។ នេះជាទំនាក់ទំនងជាមួយ សុន សេន ជាសមាជិកដ៏សំខាន់នៃមជ្ឈិមបក្ស។ ខ្ញុំហាក់ដូចជាធ្វើឲ្យលោកច្រឡំ ក៏ប៉ុន្តែខ្ញុំមិនប្រកួតប្រជែងជាមួយលោកទេ ប៉ុន្តែសំណួរនេះហាក់ដូចជាសំណួរច្រំដែលហើយ ធ្វើឲ្យខ្ញុំនិយាយអ្វី ដែលខុសពីអ្វីដែលខ្ញុំនិយាយកន្លែងនេះ ដោយខ្ញុំមិនសូវមានអារម្មណ៍ស្រួលទេក្នុងការឆ្លើយបែបនេះ។

[១១:៣៤:២៥]

**សះ** ដើម្បីកត់ត្រាត្រឹមត្រូវ--

**ប្រធានអង្គជំនុំ៖**

មេធាវីគប្បីធ្វើឱ្យមានឃ្លាតបន្តិច នូវការដែលនិយាយរបស់លោក ខ្ញុំបានរំពឹកច្រើនដងហើយ ធ្វើឱ្យការបកប្រែមានបញ្ហាប្រឈម ហើយរឿងនេះដដែលៗទេ។ យើងបានឱ្យវិធីសាស្ត្រក្នុងការកាត់ផ្តាច់នៅពេលដែលតាំងសំណួររួចជាមធ្យោបាយមួយដែលសមស្របបំផុតនៅក្នុងការធ្វើឱ្យដកឃ្លាវវាង ចម្លើយរបស់អ្នកជំនាញ ហើយនិងការតាំងសំណួររបស់លោក។ ទីពីរ គឺពីរបីដងហើយដែលលោកបាននិយាយកាត់ផ្តាច់នូវការឆ្លើយតបរបស់អ្នកជំនាញ លោកមេធាវីមិនគប្បីធ្វើដូច្នេះទេ។

[១១:៣៥:១០]

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ដោយស្មោះត្រង់នោះ ខ្ញុំចង់ឱ្យលោកបញ្ជាក់យោបល់ដើម្បីបំភ្លឺចំណុចតែប៉ុណ្ណោះទេ។ ប៉ុន្តែប្រសិនបើលោកអ្នកជំនាញគិតថា ខ្ញុំមានការសម្តីដូចជាបំពានលើសបន្តិច ហើយលោកការពារខ្លួននោះ នេះៗហើយជាចំណុចដែលខ្ញុំយល់ទៅទំនងជាតុលាការ ឬក៏ភាគីយល់ថាខ្ញុំធ្វើបែបនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

លោក កាណាវាស វិធីដែលលោកសួរសំណួរនេះ យើងយល់ឃើញថា ដូចជាលោកធ្វើសេចក្តីសន្និដ្ឋាន ដូចជាជំរុញឱ្យអ្នកជំនាញឆ្លើយឱ្យដូចដែលលោកចង់បាន ឱ្យរឹងមាំ។ ដូច្នេះសូមលោកកុំចោទប្រកាន់ទៅសាក្សី ឬក៏អ្នកជំនាញណា គឺថាកុំឱ្យប្រើពាក្យថាគាត់ជាមនុស្សដែលថា *អាគ្រេសស៊ិន* ដែលថាបំពានក្នុងគំនិតណាមួយនោះ។

[១១:៣៦:១៨]

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ខ្ញុំសូមឱ្យលោកពិនិត្យមើលចំណុចមួយ ហើយដែលបំភ្លឺពីចម្លើយរបស់ ឌុច ហើយខ្ញុំសូមអរគុណចំពោះភាពស្មោះត្រង់ ហើយនិងឆន្ទៈក្នុងការកែតម្រូវដើម្បីកំណត់ត្រាតុលាការ ហើយដែលលោកបានពន្យល់បន្ថែមថ្ងៃនេះ។ សូមលោកមើលចម្លើយរបស់លោកក្នុងសក្ខីកម្មពីមុននៃថ្ងៃទី០៦ សីហា ឆ្នាំ២០០៩។ ហើយនេះមិនមែនជាការប្រកួតប្រជែងជាមួយអ្វីដែលលោកបាននិយាយទេ នៅក្នុង

តុលាការនោះ ដែលតាមពិតដែលនាំឲ្យយើងឃើញក្នុងផ្នែកនៃសក្ខីកម្មមួយថ្ងៃនេះ គឺដើម្បីកំណត់ត្រា តុលាការនោះទេ ហើយខ្ញុំ -- D288/4.59.1។ នេះប្រតិចារឹករឿងក្តី ឌុច ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ បន្ទាត់ទី២០ នៃប្រតិចារឹកនោះ។ ប្រតិចារឹក បន្ទាត់២០ ទំព័រ៥៨ នៃភាសាប្រតិចារឹកអង់គ្លេសនោះ លោកបាននិយាយថា “ស-២១ គឺស្ថិតនៅក្នុងរបៀបវារៈនៃមេដឹកនាំជាន់ខ្ពស់ ប៉ុន្តែស្ថិតនៅក្នុងរបៀបវារៈខ្ពស់បំផុតទាក់ទងទៅនឹងទិដ្ឋភាពអំពីអ្វីដែលកើតឡើងនៅក្នុងប្រទេសនាសម័យកាលនោះ”។

[១១:៣៧:៥០]

បើលោកមិនមានច្បាប់លើក្រដាសទេ ខ្ញុំនឹងផ្តល់ជូនបាទ។ បើលោកមានហើយមិនថ្វីទេ។ លោកបានឆ្លើយថា “បាទ ជាទូទៅខ្ញុំនិយាយថា ខ្ញុំមានន័យថា ប្រាកដហើយមេដឹកនាំកំពូលមានការចាប់អារម្មណ៍ខ្លាំងនឹងចម្លើយសារភាពកម្មាភិបាលថ្នាក់ខ្ពស់ៗដូច កុយ ធួន, វន វ៉េត ហើយនិងមនុស្សមួយចំនួនទៀតដែលមកពីបណ្តាញនៅក្នុងឆ្នាំ១៩៧៦ និង៧៧ ហើយខ្ញុំគិតថា ចម្លើយសារភាពទាំងអស់នេះខ្ញុំគ្រាន់តែស្មានទេ។ យើងមិនមានគន្លងនៃឯកសារដែលចម្លើយសារភាពនេះមិនត្រូវអានត្រឹមតែ សុន សេន តែប៉ុណ្ណោះទេ ហើយក៏អ្នកផ្សេងទៀតក៏បានអានដែរនៅថ្នាក់លើនោះ”។ នេះគឺជា -- ខ្ញុំចង់ឲ្យលោកពិនិត្យមើលចម្លើយនេះជាមួយខ្ញុំ កាលណាយើងពិនិត្យមើលសក្ខីកម្មរបស់ ឌុច ហើយនិងសក្ខីកម្មរបស់លោក យើងនឹងមានរូបភាពទាំងស្រុង ចម្លើយទាំងស្រុងមួយទៅនឹងចម្លើយដែលបានសួរ។ តើត្រឹមត្រូវ តើលោកយល់ដូចខ្ញុំអ៊ីចឹងទេ?

[១១:៣៩:០៤]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** បាទ។

**ស៖** សូមអរគុណ។ ខ្ញុំសូមអនុញ្ញាតចូលទៅដល់ចំណុចមួយទៀត បាទទំព័រមួយទៀត គឺទំព័រ ១១៩ នៅខាងក្រោម ម៉ោង ១៥:៤០:០០។ នេះចំណុចមួយដែលខ្ញុំចង់ឲ្យលោកបំភ្លឺ ហើយមានសំណួរសួរទៅលោក “ខ្ញុំមិនចង់សួរសំណួរមួយថ្មីទៀតទេ ដែលខ្ញុំគិតថាជាសំណួរចុងក្រោយហើយនោះ ហើយបន្ទាប់តទៅទៀត នៅពេលដែលលោកនិយាយថា ប្រធានមន្ទីរ៨៧០ លោកបានបង្ហាញខាងដើមនោះនៅក្នុងថា ៨៧០ លោកនិយាយថា គឺជាៗអាសយដ្ឋាន ឬក៏លេខកូដ ឬក៏យោងទៅរកមនុស្សមួយចំនួន ឬក៏ស្ថាប័នមួយចំនួន ដែលសំដៅរកមជ្ឈិមបក្ស?” សូមកែខ្ញុំ បើខ្ញុំខុស។ “នៅពេលដែលនិយាយថា ប្រធានមន្ទីរ៨៧០ សូមលោករៀបរាប់ពីតួនាទី មុខងារអ្វីខ្លះ តាមដែលលោកយល់នោះ?” នេះជាសំណួរ

ដែលគេសួរទៅលោក។ ហើយខ្ញុំគិតថា លោកបានមានហើយ ចម្លើយរបស់លោកនោះគឺ "អ្វីដែលខ្ញុំយល់អំពីបញ្ហានេះច្បាស់នោះ ខ្ញុំត្រូវតែទទួលស្គាល់ថា តាមដីកាដំណោះស្រាយ។ នេះមិនមែនជាអ្វីដែលខ្ញុំបានស្រាវជ្រាវពីមុនមកទេ។ ប៉ុន្តែខ្ញុំយល់ថា មន្ទីរ៨៧០ ជាឈ្មោះកូដរបស់ ប៉ុល ពត"។

[១១:៤១:០៥]

បន្ទាប់មកលោកនិយាយតទៅទៀត យ៉ាងហោចណាស់នៅក្នុងផ្នែកដែលដកស្រង់នេះ ចម្លើយរបស់លោកបង្ហាញថា លោកយល់ថា ៨៧០ ហ្នឹងគឺមានន័យថា ប៉ុល ពត ក្នុងចំណោមពាក្យផ្សេងៗទៀតនោះ។ នេះគឺចេញមកពីអ្វីដែលលោកអាន ហើយនិងបានបំភ្លឺក្រោយពីអានដីកាដំណោះស្រាយ។ តើអ៊ីចឹងឬទេ?

[១១:៤១:៣៣]

**ឆ៖** មិនមែនអ៊ីចឹងទេ។ ខ្ញុំយល់ហើយ ដែលលោកចង់ដឹង ក៏ប៉ុន្តែនេះមិនមែនជាចម្លើយល្អទេ មិនមែនជាចម្លើយដែលច្បាស់។ ខ្ញុំសូមទោសចំពោះរឿងនេះ។ ខ្ញុំបានដឹងនៅពេលដែលខ្ញុំបានឆ្លើយជាច្រើនដងនូវចំណែកនេះ គឺដោយមិនបានយោងទៅដីកាដំណោះស្រាយ គឺថាមន្ទីរ៨៧០ គឺថាសំដៅ ប៉ុល ពត គឺផ្អែកលើការសិក្សារបស់ខ្ញុំ អ្វីដែលខ្ញុំដឹងគឺថា -- ហើយនៅក្នុងឯកសារផ្សេងទៀតក៏បានបញ្ជាក់គឺថាមិនមែនតែដីកាដំណោះស្រាយទេ គឺថា ៨៧០។ ខ្ញុំដឹងអំពីមន្ទីរនេះ ដែលខ្ញុំសិក្សាក្នុងឯកសារកាលពីខ្ញុំសរសេរសៀវភៅ ស-២១ នោះ។ អ្វីដែលមន្ទីរហ្នឹងធ្វើការអ្វី ខ្ញុំមិនបានដឹងច្បាស់ថា ធ្វើអីតួនាទីអ្វីនោះទេ។ ខ្ញុំគ្រាន់ -- ខ្ញុំដឹងព័ត៌មានមួយចំនួននៅក្នុងដីកាដំណោះស្រាយអំពីមន្ទីរ៨៧០ នេះគឺជា -- អាចជាអាសយដ្ឋានផ្ញើសំបុត្រ។បើការពង្រីកបន្ថែមអំពីមន្ទីរដ៏សំខាន់នេះ ជារដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យ យើងមិនដឹងច្រើនប៉ុន្មាននោះទេ។

[១១:៤២:៤១]

**ស៖** ឥឡូវនេះយើងចូលទៅដល់ថ្ងៃមួយទៀត គឺថ្ងៃ១៩ កក្កដា ឆ្នាំ២០១២។ ខ្ញុំមិនដឹងថាបានផ្តល់ជូនលោកដែរឬទេ ឯកសារនេះនោះ។ យើងមានឯកសារមួយច្បាប់នេះជូនទៅលោក ដើម្បីពិនិត្យ។

**លោក ម៉ៃខល កាណាវាស៖**

សូមអនុញ្ញាតតុលាការប្រគល់ជូនលោកអ្នកជំនាញ ហើយសូមអភ័យទោសដែលថា យើង--

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវី យកទៅជូនអ្នកជំនាញពិនិត្យ មុននឹងឆ្លើយនឹងសំណួរ។ សូមទុកពេលវេលាសមស្របសម្រាប់អ្នកជំនាញពិនិត្យឯកសារ។

[១១:៤៣:២៩]

**លោក ម៉ែខល កាណាវាស៖**

បាទ លោកប្រធាន នេះជាប្រតិចារឹកនៃសក្ខីកម្មនៅថ្ងៃទី១៩ ខែកក្កដា។ ដូចដែលខ្ញុំបានអនុវត្តដូចប្រតិចារឹកខាងដើម ហើយខ្ញុំនឹងអនុវត្តវិធីដដែល ហើយខ្ញុំមិនគិតថា ខ្ញុំយោងទៅរកសេចក្ដីដកស្រង់ច្រើនពេកទេ។ ដូច្នេះខ្ញុំសង្ឃឹមថា ខ្ញុំអាចចប់មុនពិសាអាហារថ្ងៃត្រង់ថ្ងៃនេះ។ ក្នុងការពិនិត្យលើប្រតិចារឹកនេះ គឺទំព័រ៣០។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** សូមឱ្យលោកអ្នកជំនាញមើលទំព័រផ្សេងៗទៀត ទំព័រ៣០ នៅខាងលើម៉ោង ១០:០០:៣៤ មានសំណួរមួយជូនទៅលោក ឱ្យលោកផ្ដោតអារម្មណ៍ទៅលើចំណុចមួយ នៅឆ្នាំ១៩៦៦ និង១៩៦៧ បន្ទាប់មកទៀត សំណួរមួយដ៏វែងដែលគេសួរទៅលោក នៅទំព័របន្ទាប់ ទំព័រ៣១ គឺបន្ទាត់១៧។ សួរថា "ហេតុអីបានជាលោកចាត់ទុកថា យុទ្ធសាស្ត្ររបស់បក្ស គឺថាមេដឹកនាំបានសម្រេចថា យុទ្ធសាស្ត្ររបស់បក្សត្រូវតែប្ដូរបែបនេះ?" ដោយសារ លោកបានឆ្លើយថា "ខ្ញុំគិតថា" នៅទំព័រ៣១។ បន្ទាប់ទៅទៀតទំព័រ៣២ លោកនិយាយថា "ខ្ញុំយល់ ខ្ញុំគិតថា"។ នៅបន្ទាប់ទី៧ ក៏អ៊ីចឹង គឺ"ខ្ញុំយល់ថា" ហើយបន្ទាប់មកទៀតនៅបន្ទាប់១៤ លោកនិយាយថា "យើងមិនដឹងពិតប្រាកដថាគេធ្វើអ្វីនោះទេ។ ប៉ុន្តែដោយជាក់ស្ដែងខ្ញុំយល់ឃើញថា ពួកគេធ្វើ គឺធ្វើផែនការ រៀបចំនយោបាយនៅពេលដែលគេឡើងកាន់អំណាចដែលគេថាគេលាក់កំបាំងពីនយោបាយរបស់សម្ដេច សីហនុ ដែលពីខាងដើម។ នេះជារយៈពេលនៃការធ្វើគោលនយោបាយ ការបញ្ចូលផែនការដែលជាសម័យដែលគេបង្កើននូវអំណាចរបស់គេ"។

អ៊ីចឹង គឺថានេះជាចំណុចសំខាន់ដែលខ្ញុំលើកឡើង គឺមិនយកទាំងស្រុងទេ គឺសំណួរគឺទាក់ទងទៅនឹងបញ្ហាដែលខ្ញុំលើកឡើងនេះ បន្ទាប់ពីលោកពិនិត្យមើល។

លោកប្រធានបានជូនដំណឹងមកខ្ញុំថា ឱ្យលោកមានពេលគ្រប់គ្រាន់ដើម្បីពិនិត្យមើល ហើយសូមលោកពិនិត្យឯកសារ ពេលលោកចប់ លោកប្រាប់ខ្ញុំផង ដើម្បីខ្ញុំសួរ។

*(អ្នកជំនាញពិនិត្យមើលឯកសារ)*

[១១:៤៦:៤៦]

**ឆ៖** បាទ សូមលោកសួរចុះ!

**ស៖** ខ្ញុំចង់សួរលោកដូចតទៅនេះ តាមសក្ខីកម្មរបស់លោក គឺថាលោកប្រាប់ថា លោកមិនបាននៅទីនោះទេ គឺថាជាក់ស្តែងគឺអ៊ីចឹងមែន។ ប៉ុន្តែនៅកន្លែងនេះ ក៏លោកបានកំណត់ប្រភេទមួយច្បាស់លាស់ណាស់នៅក្នុងចម្លើយដ៏ច្បាស់ ដ៏ជាក់លាក់ ថានេះជាការធ្វើផែនការគោលនយោបាយ។ ជាសម័យកាលដែលគេធ្វើគោលនយោបាយ។ ហាក់ដូចជាលោកបាននៅហ្នឹង ឬក៏ដែលថាអ្នកទាំងហ្នឹងគឺមិនមែនធ្វើរឿងនេះទេ។ តើលោកជឿជាក់ដូចម្តេច ថាគេធ្វើផែនការសម្រាប់អនាគតនោះ? បើខ្ញុំមិនច្រឡំទេ គឺថាគេរៀបចំផែនការនៅអនាគតអំពី ដែលថាគេនឹងធ្វើការងារនៅពេលអនាគត។

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប ចាំស្តាប់សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាជាមុនសិន។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១១:៤៧:៥៤]

**លោក អាប់ឌុលឡាក់ ចារីក៖**

គឺថា ខ្ញុំយល់ថា នេះចំណុចសំខាន់នៅក្នុងការរៀបចំពាក្យដែលអ្នកជំនាញនិយាយ។ តាមពិតគាត់និយាយថា "ជាក់ស្តែងអ្វីដែលខ្ញុំយល់ អ្វីដែលគេធ្វើនោះ គឺថាគេបានធ្វើផែនការនយោបាយ"។ ដូច្នេះសូមឲ្យមេធាវីសួរសំណួរឲ្យត្រឹមត្រូវ កុំឲ្យលោកប្រើពាក្យថា អ្នកជំនាញគាត់និយាយថា "គាត់ដឹងជាក់ស្តែង" នោះ គឺថា ប៉ុន្តែអ្វីដែលគាត់ឆ្លើយហ្នឹង គាត់យល់បែបនោះទេបាទ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមអរគុណចំពោះការបំភ្លឺនេះលោកប្រធាន។ ប៉ុន្តែអ្វីដែលធ្វើឲ្យខ្ញុំភ័ន្តច្រឡំនោះ គឺថាអាចនឹងធ្វើឲ្យអង្គជំនុំជម្រះច្រឡំដែរនោះ ចម្លើយបន្តទៅនិយាយថា "នេះជាសម័យកាលនៃការធ្វើគោលនយោបាយនៃការរួបរួមកម្លាំង ហើយដើម្បីគេបង្កើនកម្លាំង"។ នេះហើយជាសេចក្តីថ្លែងការណ៍ដែលប្រកាសយ៉ាងច្បាស់ ដែលថាតាមពិត ប៉ុន្តែពីដំបូងគាត់ៗថាគាត់គិត ឬគាត់យល់។ ប៉ុន្តែចង់ឲ្យឱកាសដល់អ្នកជំនាញដើម្បីបំភ្លឺចំណុចឲ្យច្បាស់ជូនតុលាការ។ ប៉ុន្តែពីមុននោះ គឺថាគាត់ -- "ខ្ញុំគិតថា ហើយគាត់យល់ថា" គាត់ប្រើពាក្យអ៊ីចឹង។

[១១:៤៩:១៣]

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ដូច្នេះដើម្បីឲ្យខ្ញុំរៀបឃ្លាឡើងវិញ ដើម្បីសួរនោះ តើនេះគ្រាន់តែជាការសន្មតរបស់លោក ឬ អ្នកជំនាញ ដែលថានេះជាសម័យកាលធ្វើផែនការនយោបាយនៅក្នុងការងារផ្សេងៗទៀត?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** តាមពិតហើយនៅក្នុងវិសាលភាពហ្នឹង។ ខ្ញុំគិតថា យើងត្រឡប់ទៅអ្វីដែលខ្ញុំបានសរសេរនៅក្នុងសៀវភៅពីរក្បាលរបស់ខ្ញុំហ្នឹង គឺសម័យបន្ទាប់ពី ប៉ុល ពត ទស្សនកិច្ចសម្ងាត់ទៅចិន ទៅវៀតណាមនោះ គឺជាសម័យកាលដែលគាត់សម្រេចនឹងប្តូរបក្សទៅបក្សកុម្មុយនីស្តកម្ពុជា ហើយបានគឺថា គឺគេនិយាយ គឺថា "បក្សកុម្មុយនីស្តកម្ពុជា គឺអាចមានស្មើលំដាប់ទៅនឹងបក្សកុម្មុយនីស្តចិន និងបក្សពលករវៀតណាម។ នៅក្នុងឆ្នាំ១៩៦៧ ពួកគេទៅរតនគិរី មកពីភូមិបូព៌ាដែលនៅពីមុន នៅតាមបណ្តោយព្រំដែន ហើយត្រឡប់មកទៅមេដឹកនាំរបស់គេហ្នឹងក៏ផ្លាស់ប្តូរទីតាំង ទៅក្បែរកងទ័ពវៀត-ណាមទៅមូលដ្ឋានទ័ពវៀតណាម គឺដែលថាមន្ទីរ១០០របស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង គឺនៅត្រង់ហ្នឹង។

[១១:៥០:២៨]

បើខ្ញុំយោងទៅហេតុការណ៍នៅឥណ្ឌូនេស៊ី ខ្ញុំមិនអាចតាមដានទេ ហើយខ្ញុំមិនបានយល់ថាមានឯកសារមួយចំនួនច្រើនដែលខ្ញុំអានពីមន្ទីរស-២១ ខ្ញុំបញ្ជាក់ថា គឺថាមានភាពតានតឹង គឺថាវាមានការប៉ះទង្គិចដ៏ធំទៅប្រទេសជិតខាង។ ប៉ុន្តែយើងមិនដឹងទេ ហើយជាបក្សកុម្មុយនីស្តកម្ពុជាធំ គឺថាវាមានការប៉ះទង្គិចធំមួយ គឺខាងយោធា ដែលរងគ្រោះមួយដល់បក្សកុម្មុយនីស្តកម្ពុជានៅសម័យនោះ។ នេះគឺជាពេលវេលាដែលពួកគេប្រុងប្រយ័ត្នដែលត្រូវសម្រេចលើគោលនយោបាយរបស់គេ។ ការបើកជម្លោះតស៊ូប្រដាប់អាវុធនៅឆ្នាំ១៩៦៨នោះ គឺជាគោលនយោបាយមួយដែលមានការសន្មតមួយចំនួន ប៉ុន្តែខ្ញុំមិនយល់ថា អាហ្នឹងត្រឹមត្រូវទាំងស្រុងទេ ប៉ុន្តែវាមានហេតុការណ៍ហ្នឹង។

[១១:៥១:៣៣]

**ស៖** ខ្ញុំមិនប្រើពាក្យណាមួយគឺថា លោកប្រើពាក្យកំណត់ប្រភេទបែបនេះនេះ។ នេះគឺជាឃ្លាដែលខ្ញុំបានប្រើ។ ខ្ញុំសូមអរគុណ ហើយសូមស្វាគមន៍ចំពោះការបំភ្លឺដែលលោកបានធ្វើឡើងនេះ។ លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ ហើយលោកនិយាយគោលនយោបាយនៅក្នុងបរិបទនេះ នៅក្នុងបញ្ហានយោបាយបច្ចុប្បន្នរបស់តុលាការនេះ គឺថាមានបរិបទផ្សេងៗ។ ដូច្នេះហើយចម្លើយមួយនេះ គឺទាក់ទងទៅនឹង

ទសវត្សរ៍ឆ្នាំ១៩៦០, ៦៦, ៦៧ នេះហើយជាបរិបទដែលលោកនិយាយថានយោបាយនោះជាឧទាហរណ៍។ ហើយសូមអរគុណដែលលោកបានបំភ្លឺនេះ។

[១១:៥២:២២]

ខ្ញុំមានពីរបីចំណុចទៀត ខ្ញុំអាចនឹងបញ្ចប់ប្រតិចារិកនេះ មុននឹងសម្រាក ផ្នែកនៃការសួរអ្នកជំនាញនេះ។ សូមលោកមើលទំព័រ៨៦ នៅខាងលើម៉ោង ១៣:៤០:៤៥ ហើយយើងដឹងថា យើងនិយាយអំពីការងារមួយចំនួន គឺថាសូមអភ័យទោស បើសិនជាព័ត៌មានហ្នឹងវាជាន់គ្នាបន្តិចបន្តួច។ មើលបន្ទាត់ទី២១ លោកអាចមើលខាងលើហ្នឹងបន្តិច មុន ខ្ញុំនឹងអាន ខ្ញុំគិតថាវាមានភាពចាំបាច់ដល់ភាគី គឺថាសុំឱ្យមើលមុននៅខាងក្រោយបរិបទប្រវត្តិសាស្ត្រនៅកន្លែងនោះ។

សំណួរសួរថា "ដោយសង្ខេបនោះ គឺយើងបានពិភាក្សានៅទីនេះអំពីសុន្ទរកថា ដែលនិយាយ -- ដែលបញ្ជូនពីលោកទៅ ប៉ុល ពត។ តើលោកអាចប្រាប់ខ្ញុំបានទេ តើលោកអាចសន្និដ្ឋានថាតើស្ថាប័នណា ឬក៏ក្រុមមនុស្ស ក្រុមណាដែលចេញផែនការនេះ?" ចម្លើយនោះឆ្លើយថា "ខ្ញុំត្រូវតែមើលអត្ថបទសិន។ នៅពេលដែលខ្ញុំនិយាយថា ពេលនោះ ប្រាកដហើយមិនមែនជាឯកសារដែលចេញពី ប៉ុល ពត ផ្ទាល់នោះទេ គឺវាចេញមកពីមេដឹកនាំបក្ស"។

[១១:៥៤:00]

នៅទំព័រ៨៧ "ខ្ញុំគិតថា គឺជាសេចក្តីព្រាងដ៏លម្អិត មានអ្នកសរសេរបានស្នើថាមួយផ្នែកខ្លះ បានអាន -- បានសរសេរដោយ ខៀវ សំផន ប៉ុន្តែខ្ញុំមិននិយាយអ៊ីចឹងទេ គឺសរសេរឡើងដោយនរណាម្នាក់ទេ។ គឺសរសេរឡើងដោយសមូហភាព ដោយប្រាកដ។ ហើយឯកភាពជាសមូហភាព គឺចេញមកពីមេដឹកនាំសមូហភាព ហើយយើងមិនដែលបានហត្ថលេខានៅលើឯកសារកម្ពុជាប្រជាធិបតេយ្យណាមួយទេ មានតែមេដឹកនាំនោះទេដែលអាចពន្យល់ គឺមានតែមេដឹកនាំទេដែលមានសម្តីចុងក្រោយ។ ដូច្នេះគេធ្វើសេចក្តីសម្រេចចេញពីបញ្ញាញាណរបស់ថ្នាក់ដឹកនាំកំពូល វាអាចជាថ្នាក់មជ្ឈិម ឬក៏គណៈអចិន្ត្រៃយ៍នៅពេលខ្លះ ប៉ុន្តែយើងមិនមាន ព័ត៌មានជាក់លាក់នេះទេ"។ ឥឡូវនេះ គឺថាតាមអ្វីដែលលោកឆ្លើយបែបនេះ លោកសាស្ត្រាចារ្យ ឆេនដ័ល័រ ក្នុងន័យដែលលោកបញ្ជាក់រហូតមកដល់ពេលនេះ នៅត្រង់ចម្លើយនេះនោះ តើអ្វីដែលធ្វើឱ្យលោកទុកចិត្តថានេះគឺជាសេចក្តីព្រាងសមូហភាពទាំងមូលនោះ? គឺជាព័ត៌មានដាក់បញ្ចូលជាសមូហភាព ហើយខ្ញុំសន្មតថា លោកនិយាយថា "សមូហភាព" នោះ លោក

និយាយនៅថ្នាក់កំពូល -- ថ្នាក់ខ្ពស់មួយដែលថា មេដឹកនាំគេបានដាក់ផ្នែកនៃសំណេរ ឬគំនិតរបស់គេចូលក្នុងហ្នឹង តើលោកយល់ដូចម្ដេចត្រង់ចំណុចនេះ?

[១១:៥៥:៤៦]

**ឆ៖** បាទ នេះជាសំណួរល្អ។ ខ្ញុំមិនដឹង តាមពិតថាតើ ប៉ុល ពត ម្នាក់ឯងជាអ្នកសរសេរ ប៉ុន្តែអនុវត្តរបស់កម្ពុជាប្រជាធិបតេយ្យបានបង្ហាញយ៉ាងច្បាស់ថា មិនមែនគាត់ មិនមែនតែម្នាក់ឯងអង្គុយសរសេរ -- មិនមែនថា ប៉ុល ពត និយាយត្រូវសរសេរទាំងអស់នោះទេ គឺថា គាត់អាចនឹងជជែកជាមួយអ្នកផ្សេង សួរមតិយោបល់ផ្សេងៗទៀត ហើយជជែកគ្នានៅពេលណាមួយ។ ហើយជាកំហុសមួយនៅក្នុងសំណួរ គឺថាផែនការនេះមិនដែលបានប្រកាសចេញនោះទេ គឺមានការពិភាក្សាមុននឹងការអនុម័តគឺថាដោយលេខាបក្សនោះ ដោយ ប៉ុល ពត នោះ។ គេបានចូលផ្ដល់ជាគំនិតទៅលើគាត់ ប៉ុន្តែរីឯការប្រកាសនោះវាជាឯកសារដែលចេញមកពី -- គឺមិនយកគំរូតាមអ្នកណាផ្សេងទេ វាចេញមកអំពីមជ្ឈិមបក្សឯកសារនេះនោះ។

[១១:៥៦:៥០]

**ស៖** នៅចំណុចមួយផ្សេងទៀត ខ្ញុំនឹងបញ្ចប់ចំណុចនេះដោយចុចយកព័ត៌មានសង្ខេបសំខាន់ៗ។ យើងត្រឡប់ទៅទំព័រ១០៤ នៃប្រតិចារឹក ជាឯកសារដែលបានបង្ហាញលោកនៅឯកសារ ហើយលោកបានពិភាក្សា។ នេះជាឯកសារដែលដកស្រង់ពីកម្មវិធីផ្សាយព័ត៌មានវិទ្យុអន្តរជាតិ គឺឯកសារ E3/270 ហើយគេបានសួរលោកឱ្យលោកបញ្ចេញយោបល់ ហើយនៅទំព័រ១០៦ លោកនិយាយថា លោកមានការសង្ស័យថា តើឯកសារនេះវាឆ្លុះបញ្ចាំងពីភាពការពិតដែរឬអត់? ហើយនៅទំព័រ១៩ ដល់ -- អ៊ំ! នៅបន្ទាត់ទី១៩ ដល់ ២១ នៅទំព័រ១០៦ ហើយខ្ញុំសង្ខេបខ្លឹមសាររបស់សក្ខីកម្មរបស់លោក ហើយកែខ្ញុំបើខ្ញុំសង្ខេបមិនត្រូវ។

[១១:៥៧:៥២]

លោកបង្ហាញថា "នេះគឺជាការប្រើប្រាស់ខាងក្រៅ ជាព័ត៌មានហ្នឹងផ្សាយទៅខាងក្រៅទៅបរទេស"។ ដូច្នេះព័ត៌មាននេះ គេដឹងថាគេនឹងស្ដាប់ថាព័ត៌មាននេះនៅពេលនោះ វាអាចនឹងមានករណីថា គឺគេអាចនឹងកត់សម្គាល់ថាជាព័ត៌មានខុស ឬព័ត៌មានត្រូវ?

**ឆ៖** នេះជាការផ្សាព្វផ្សាយពីមុខមាត់របស់កម្ពុជាប្រជាធិបតេយ្យ។ គេយល់ថា ប្រហែលជាបរទេសបានស្តាប់ ប៉ុន្តែមិនដឹងថា គេតាមដានដូចម្តេចទេខាងក្រៅនោះ។ ប៉ុន្តែប្រជាជនប្រទេសក្រៅៗគេមិនទុកចិត្ត ប៉ុន្តែគេត្រូវផ្សាយឲ្យដឹង។

**ស៖** ថាតើបក្សបានធ្វើអ្វីខ្លះក្នុងករណីនេះ ឧទាហរណ៍ថា នៅពេលដែលគេអាចនឹងមានការប្រជុំដែលអាចនឹងថាជាមហាសន្និបាត ឬក៏កិច្ចប្រជុំរបស់គណៈមជ្ឈិមដែលត្រូវសម្រេចដែលថា ដែលអាចថានឹងត្រូវសម្រេចជាមុន ហើយអាចនឹងសម្រេចជាមុនៗនឹងយកទៅផ្សាយ ឬក៏មិនមានការប្រជុំដើម្បីសម្រេចទេ។ គឺឯកសារ ហ្នឹងដែលបង្ហាញថា គណៈអចិន្ត្រៃយ៍ជាអ្នកសម្រេច ឬក៏គណៈមជ្ឈិមជាអ្នកសម្រេច ឬក៏លោកផ្អែកទៅតាមឯកសារហ្នឹង លោកនិយាយ?

[១១:៥៩:២៧]

**ឆ៖** គឺថាខ្ញុំយល់ស្របជាមួយហ្នឹង ផ្អែកទៅលើភស្តុតាងរបាយការណ៍ទូទៅអំពីការបោះឆ្នោតហ្នឹងគេថា មានប្រជាជន៩៨ភាគរយ ចូលរួមគឺថា អ្វីដែលគេផ្សាយក្នុងវិទ្យុបរទេស កម្មវិធីបរទេសរបស់គេនោះ លើក្រដាសគេផ្សាយអ៊ីចឹង ទូរទស្សន៍ -- វិទ្យុផ្សាយអ៊ីចឹង ក៏ប៉ុន្តែតាមពិតមិនមានការបោះឆ្នោតជាសកលទេ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ លោកប្រធានខ្ញុំឃើញថាម៉ោងដប់ពីរហើយ ខ្ញុំបញ្ចប់ផ្នែកមួយដែលត្រូវលើកមកដេញដោលលោកអ្នកជំនាញ។ សហសេវិករបស់ខ្ញុំ គឺថាអាចមានពេលដល់ម៉ោងពីរម្ភៃប្រាំ ប៉ុន្តែខ្ញុំមិនចំណាយឲ្យលើសពីហ្នឹងទេ។ ហើយខ្ញុំនឹងត្រូវគោរពទៅតាមសេចក្តីសម្រេច ហើយនិងការព្រមព្រៀងរួមរបស់យើងខ្ញុំ ថានឹងប្រើពេលល្ងាចប្រហែលជា២៥នាទី ទៀតបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ សូមអញ្ជើញលោកសាស្ត្រាចារ្យ!

[១២:០០:៣៤]

**លោក ដេវីដ ឆេនដ័ល័រ៖**

គឺថា ជាសំណួរល្អ គឺថាលោក កាណាវាស គឺអាចសួរ គឺថាសក្ខីកម្មអំពីម៉ោងពីរតទៅទៀតតើផ្អែកទៅលើប្រតិចារិកដែរទេ បើថាត្រូវសួរតទៀត ខ្ញុំនឹងយកទៅ បើថាអត់ទេ ខ្ញុំទុកនៅទីនេះ។

**លោក ម៉ៃខល កាណាវាស៖**

សូមលោកសម្រាក។ ខ្ញុំមិនត្រឡប់មកសួរប្រតិចារឹកនេះវិញទេ។ សូមឲ្យលោកសម្រាកពិសាអាហារថ្ងៃត្រង់ដោយបានស្ងប់ចិត្ត ហើយខ្ញុំមិនសួរបញ្ហានេះឡើងវិញទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន!

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ដើម្បីឆ្លើយតបទៅនឹងសំណួររបស់លោក ឆេនដ័ល័រ ពីព្រោះថាទាក់ទងនឹងក្រុមយើងផងដែរ។ យើងចង់ប្រាប់គាត់ជាមុនថា ក្នុងរសៀលនេះ គឺថាក្រុមការពារក្ដីលោក ខៀវ សំផន អាចនឹងត្រឡប់មកចោទសំណួរគាត់ទាក់ទងទៅនឹងការ -- ចម្លើយរបស់គាត់ឡើងវិញខ្លះៗ។ អ៊ីចឹងប្រហែលជាមានសារៈសំខាន់ក្នុងការគាត់យកឯកសារទាំងអស់ហ្នឹងទៅពិគ្រោះមុនបានពីព្រោះថា ជាការប្រសើរសម្រាប់គាត់។

[១២:០២:០២]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ ពិសាអាហារថ្ងៃត្រង់ហើយ។ ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលកន្លែងសម្រាកដល់អ្នកជំនាញនៅបន្ទប់សម្រាកសម្រាប់អ្នកជំនាញនិងសាក្សី ហើយនិងឲ្យអញ្ជើញគាត់មកត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបានកំណត់ គឺម៉ោងមួយសាមសិបនាទី។

បាទ សូមអញ្ជើញលោកមេធាវី!

[១២:០២:៤០]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ កូនក្ដីរបស់ខ្ញុំ នួន ជា សូមអនុញ្ញាតទៅតាមដានសវនាការល្ងាចនេះពីបន្ទប់ខាងក្រោម ហើយខ្ញុំជម្រាបថា គាត់ឈឺខ្នង ឈឺក្បាល ហើយមានបញ្ហាក្នុងការផ្ចង់អារម្មណ៍។ ហើយសូមជម្រាបថា មានបញ្ហាសម្ពាធឈាមដែរព្រឹកនេះ។ ដូច្នេះហើយ លោក នួន ជា សូមអនុញ្ញាត

ទៅតាមដាននូវសវនាការនៅពេលល្ងាចនេះពីបន្ទប់ខាងក្រោម។ ហើយយើងខ្ញុំបានត្រៀមលិខិតបោះបង់សិទ្ធិដើម្បីជូនតុលាការតាមនីតិវិធី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់នូវសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោមសាលសវនាការនេះសម្រាប់អំឡុងពេលកិច្ចដំណើរការសវនាការពេញមួយរសៀលនេះ ដោយមូលហេតុមានបញ្ហាសុខភាព។ ហើយក្រុមមេធាវីការពារក្តីបានសន្យាថា ខ្លួននឹងប្រគល់មកអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំបន្តទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ច ដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ប្រគល់មកអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ។ ហើយបង្គាប់ផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះសម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជាប់ចោទ នួន ជា និងខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោមសាលសវនាការនេះ ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលមានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

ដោយឡែក បង្គាប់ឲ្យនាំខ្លួនលោក ខៀវ សំផន មកកាន់បន្ទប់សវនាការនេះវិញនៅ -- ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ សួស្ដីលោកប្រធាន អស់លោក លោកស្រីទាំងអស់ និងភាគីទាំងអស់នៅក្នុងបន្ទប់សវនាការ និងជុំវិញបន្ទប់សវនាការ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ ខ្ញុំនៅសល់ប្រធានបទមួយចំនួនតូចទៀត ដែលខ្លីៗតែប៉ុណ្ណោះ ចង់សួរទៅកាន់លោក។ ហើយប្រធានបទនេះ គឺមិនរៀបចំតាមលំដាប់លំដោយនោះទេ គ្រាន់តែខ្ញុំចង់បំភ្លឺចំណុចមួយចំនួន។ ចំណុចទីមួយ គឺពាក់ព័ន្ធទៅនឹងសៀវភៅខ្មៅ ដែលលោកបានយកមកសរសេរនៅក្នុងសៀវភៅ “បងធំទី១”។ E3/17 នេះជាលេខឯកសារ។ ហើយខ្ញុំនឹងយោងជាក់លាក់ទំព័រ៤១ នៅក្នុងសៀវភៅរបស់លោក -- ទំព័រ៧១ នៅក្នុងសៀវភៅរបស់លោក គឺសៀវភៅស្ដីអំពីចំណងជើង “បងធំទី១”។ គឺសៀវភៅនេះ បោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៩៩។ ទំព័រ៧១ លេខ ERN គឺ 00392985 ហើយខ្ញុំជឿថាភាសាខ្មែរ 00821734 ទៅដល់ 36។

ខ្ញុំនឹងអានអត្ថបទនេះ ហើយខ្ញុំនឹងសួរសំណួរមួយចំនួន។ លោកបានលើកឡើងថា ជាបឋមមុនពេលដែលខ្ញុំសួរសំណួរនោះ គឺថាតើលោកស្គាល់សៀវភៅខ្មៅ ឬក៏បារាំងហៅថា *“លីវណ័រ”* ដែរឬទេ?

[១៣:៣៤:៣៧]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** បាទ ខ្ញុំស្គាល់។

**ស៖** នៅត្រង់ទំព័រ៧១ លោកបានលើកឡើងថា"សៀវភៅខ្មៅ" គឺនិយាយអំពីប្រវត្តិសាស្ត្រដែលតាមការនឹកស្មានរបស់គេ។ នេះគឺជាប្រយោគមួយ ដែលខ្ញុំចង់សួរបញ្ជាក់។ ខ្ញុំគិតថានេះជាការសន្និដ្ឋានមួយដែលលោកបានធ្វើឡើងផ្អែកតាមប្រវត្តិសាស្ត្រខ្មែរក្រហម ជាពិសេសនូវអ្វីដែលមេដឹកនាំខ្មែរក្រហមបានសរសេរ ដែលបានសរសេរនៅក្នុងសៀវភៅខ្មៅនេះ។ នៅលើនេះគឺបានសរសេរថា សៀវភៅនេះគឺបង្ហាញអំពីការពិតស្តីអំពីប្រវត្តិសាស្ត្រ និងការគិតគូរដែលជាការនឹកស្មានមួយ។

[១៣:៣៦:១១]

**ឆ៖** តើលោកសួរសំណួរ ឬក៏យ៉ាងម៉េច? ខ្ញុំមើលអត្ថបទនេះ ហើយខ្ញុំមិនចាំសំណួរដែលលោកសួរទេ។

**ស៖** នៅក្នុងការបកស្រាយក្នុងសៀវភៅរបស់លោក ផ្អែកតាមបទពិសោធន៍របស់លោកជាប្រវត្តិវិទូ ហើយលោកបានដឹងអំពីហេតុការណ៍អតីតកាល។ នៅពេលដែលលោកអានសៀវភៅខ្មៅនោះលោកបានសន្និដ្ឋានថា សៀវភៅនោះគឺផ្អែកទៅលើការរៀបចំអំពីប្រវត្តិសាស្ត្រ ហើយនិងការគិតទៅតាមអ្វីដែលគេបានប៉ងប្រាថ្នា។ នេះគឺជាការបកស្រាយរបស់លោកទៅលើអត្ថបទនោះ តើលោកបានបកស្រាយអ៊ីចឹងដែរឬទេ ទៅលើខ្លឹមសារនៃសៀវភៅនោះ?

[១៣:៣៦:៥៣]

**ឆ៖** ជាការពិត ប្រយោគនេះគឺពាក់ព័ន្ធទៅនឹងការពិភាក្សារបស់ខ្ញុំទៅលើសៀវភៅដែលខ្ញុំគិតអំពីរយៈកាល ៦៧ និង ៦៨។

**ស៖** លោកអាចនិយាយដូចគ្នាទៅក្នុង -- នៅចំពោះអ្វីដែលបានសរសេរឡើងដោយមេដឹកនាំខ្មែរក្រហម។ ឧទាហរណ៍ថា ទស្សនាវដ្តីទង់បដិវត្ត នៅពេលដែលលោកមើលឯកសារនេះ ឬឯកសារផ្សេងទៀតនោះ យើងអាចយល់ឃើញថា គឺវាជាការផ្សំនូវ -- គឺជាការផ្សំនូវការពិតខ្លះ និងមិនពិតខ្លះនៃប្រវត្តិសាស្ត្រ។ តើនេះជាចំណុចដែលគេបានធ្វើឡើងអ៊ីចឹងដែរឬទេ?

**ឆ៖** ជាការពិត សៀវភៅខ្មៅ និងទង់បដិវត្ត ភាពខុសគ្នានោះគឺថា សៀវភៅខ្មៅគឺវាសម្រាប់ឲ្យអ្នកខាងក្រៅអានតែប៉ុណ្ណោះ។ នៅពេលដែលយើងមើលឃ្លានេះ យើងទាំងអស់គ្នានៅក្នុងបន្ទប់នេះគឺអាចដឹងថាជារឿងរាល់ថ្ងៃ គឺយើងៗនឹងឃើញហើយថាវាជាការលាយឡំគ្នាទៅនឹងការពិតខ្លះ និងមិនពិតខ្លះ។ ដូច្នេះហើយយើងអាចថាសៀវភៅខ្មៅនោះគឺជាសៀវភៅមួយដែលអាចយើងជឿជាក់ទៅលើប្រវត្តិ

សាស្ត្រ វាជាការប្រមូលព័ត៌មានសម្រាប់អ្នកដែលគេចង់ដឹងនោះច្រើននាក់។ ហើយគឺគេនិយាយអំពីប្រវត្តិទំនាក់ទំនងរវាងខ្មែរក្រហម និងវៀតណាមនៅក្នុងហ្នឹង។

[១៣:៣៨:៤៥]

**ស៖** ខ្ញុំសូមអរគុណ។ យើងអាចនិយាយជាលក្ខណៈទូទៅពាក់ព័ន្ធទៅនឹងឯកសារដែលបានបង្កើតឡើងសម្រាប់សមាជិកបក្សផ្ទៃក្នុង។ តើវាជាការយល់របស់លោកដែរឬទេ? ជាពិសេសទៅលើឯកសារបន្ទាប់បន្សំ គឺខាងខ្មែរក្រហមគេមិនបានរៀបចំការសរសេរប្រវត្តិសាស្ត្រថា តើបក្សកុម្មុយនីស្តកម្ពុជានោះបង្កើតឡើងឆ្នាំណា? ហើយហេតុការណ៍អ្វីខ្លះបានកើតឡើងមុនការបែកភ្នំពេញនៅមុនថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥? ដូច្នេះ គេមិនបានលើកឡើងអំពីស្នាដៃ និងសមិទ្ធផលរបស់គេមួយចំនួនដែលមាននៅក្នុងនោះទេ។ នេះជាឧទាហរណ៍មួយចំនួនដែលខ្ញុំចង់បញ្ជាក់នោះ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំឯកភាពជាមួយនឹងចំណុចនេះដែលលោកបានវិភាគ។

[១៣:៣៩:៥៥]

**ស៖** សូមអរគុណ។ យើងអាចចូលទៅដល់ចំណុចប្រធានបទមួយដែលផ្សេងពីនេះបន្តិច គឺប្រធានបទនេះដកចេញពីសៀវភៅបងធំទីមួយដដែល។ កាលពីម្សិលមិញ លោកបាននិយាយជាមួយនឹងខ្ញុំ ពិភាក្សាគ្នាថាតើមានអ្វីកើតឡើងនៅពេលដែលមានការទម្លាក់គ្រាប់បែក ហើយយើងក៏បាននិយាយអំពីការផ្ដល់សក្ខីកម្មរបស់លោក ហើយនៅពេលដែលខ្ញុំចង់សួរលោកពាក់ព័ន្ធទៅនឹងសេចក្ដីផ្ដើមនៅក្នុងសៀវភៅរបស់លោកគឺឯកសារ E3/17។ ជាពិសេសត្រង់ផ្នែកមួយនៅៗក្នុងទំព័រ៧៦។ ខ្ញុំនឹងអានហើយនិងសួរលោក។ លោកបាននិយាយថា "ក្នុងរយៈពេលបួនឆ្នាំក្រោយមក មេដឹកនាំជាន់ខ្ពស់ និង អៀង សារី របស់មេធាវី -- អ៎! មេដឹកនាំមួយចំនួន និង អៀង សារី បានរស់នៅក្នុងទីក្រុងខេត្តក្រចេះមណ្ឌលគិរី ហើយមានការខឹងសម្បាទៅនឹងរដ្ឋាភិបាលនៅទីក្រុងភ្នំពេញ។ ហើយយើងឃើញមានការក្ដោបក្ដាប់នៅក្នុងដៃរបស់ពួកគេមួយចំនួន។ ពួកគេបានដឹកនាំសមាជិកខ្មែរក្រហមនៅពេលនោះ"។

ខ្ញុំចង់ផ្ដោតទៅលើផ្នែកនេះបន្តិច។ ហើយខ្ញុំចង់សួរលោកថាតើលោកអាចបញ្ជាក់បានដែរឬទេ? តើលោកនៅឯកភាព និងរក្សានូវជំហររបស់លោក ដែលលោកបានសរសេរនៅក្នុងសៀវភៅនេះដែរឬទេ?

[១៣:៤១:៤៥]

**ឆ៖** បាទ ខ្ញុំត្រូវតែរក្សាអ្វីដែលខ្ញុំសរសេរនៅក្នុងនេះដដែល។

**ស៖** នៅពេលដែលយើងអានចំណុចនេះគឺវាមានបង្ហាញឲ្យយើងឃើញថា វាអាចមានហេតុការណ៍មួយចំនួនកើតឡើង ជាពិសេសទៅលើការទម្លាក់គ្រាប់បែក។ យើងៗដឹងហើយថា លោកបានលើកឡើងថា ឆ្នាំ៧៣ គឺមានការទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិក។ មុនពេលនោះ ក៏មានការទម្លាក់គ្រាប់បែកនៅតំបន់មួយចំនួនផងដែរ។ លោកឃើញហេតុផលមួយចំនួនដែលលោកបានរកឃើញថាប្រជាជននៅតំបន់នោះ -- បាទ អត់អីទេលោករើសរបស់ រើសឯកសារលោកសិនទៅ។

វាទំនងដែលលោកបានបង្ហាញថា មានហេតុផលមួយចំនួនផ្សេងទៀតដែលប្រជាជននៅតំបន់ទីនោះមានការស្អប់រដ្ឋាភិបាលនៅទីក្រុងភ្នំពេញ ដូចដែលលោកបានសរសេរ។ ដូចជា ការកសាងផ្លូវនិងការបង្កើតចម្ការ ...។ល។ នោះ ហើយគេនិយាយអំ -- លោកបាននិយាយអំពីជីវភាពរបស់អ្នកទាំងអស់នោះមួយចំនួនត្រូវបានរងនូវផលប៉ះពាល់។ តើអ្វីដែលលោកសរសេរនោះ គឺជាការពិតដែរឬទេ?

[១៣:៤៣:១៣]

**ឆ៖** ជាការពិត គឺអ៊ីចឹងមែន។

**ស៖** នេះជាហេតុផលមួយបន្ថែមទៅលើហេតុផលផ្សេងទៀត ដែលប្រជាជននោះអាចចូលរួមជាមួយនឹងបដិវត្តន៍ដោយសារមូលហេតុនេះ។ ហើយពួកគេបានព្យាយាមចូលជាមួយបដិវត្តន៍ដើម្បីប្រឆាំងទៅនឹងរដ្ឋាភិបាលនៅទីក្រុងភ្នំពេញ។ តើអ៊ីចឹងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

លោកអ្នកជំនាញកុំអាលទាន់ឆ្លើយតប ចាំស្តាប់សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាជាមុនសិន។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន គឺប្រសិនបើខ្ញុំសួរសំណួរបែបនោះ មេធាវីការពារក្តីនឹងក្រោកឈរឡើង ហើយឡើងថាមិនមែនជាសំណួរមួយសមរម្យនោះទេ នៅពេលដែលឲ្យខាងសាស្រ្តាចារ្យផ្តល់ជាយោបល់អំពីចិត្តគំនិតរបស់ប្រជាជននៅសម័យនោះៗ។

**លោក ម៉ៃខល កាណាវាស៖**

ប្រសិនបើអនុញ្ញាតលោកប្រធាន គឺយើងប្រើ -- សូមឆ្លើយតបទៅនឹងបច្ចេកទេសវិធីសាស្រ្តរបស់ខាងសហព្រះរាជអាជ្ញា។

[១៣:៤៤:២៧]

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ផ្អែកទៅតាមប្រវត្តិសាស្ត្រ ការស្រាវជ្រាវប្រវត្តិសាស្ត្រ តើលោកអាចផ្តល់ជាយោបល់ដែរឬទេ? តើតំបន់ដែលលោកបានសរសេរនៅក្នុងសៀវភៅរបស់លោកនោះ -- ប្រជាជនដែលរស់នៅទីនោះ គឺងាយនឹងៗខឹងសម្បាទៅនឹងរដ្ឋាភិបាលទីក្រុងភ្នំពេញ? តើលោកអាចឆ្លើយទៅនឹងសំណួរនេះដែរឬទេ? ហើយតើលោក អ្វីដែលលោកសរសេរនោះ គឺជាការទស្សន៍ទាយឬក៏យ៉ាងម៉េច?

[១៣:៤៥:០៤]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** វាជាសំណួរមួយល្អ យើងមានភស្តុតាងជាច្រើន ដែលថាប្រជាជននៅទីនោះគឺបានចូលរួមនឹងចលនាហ្នឹងកាន់តែច្រើននៅពេលនោះ។

**ស៖** សូមអរគុណ។ ប្រសិនបើយើងបន្តចូលទៅដល់ប្រធានបទមួយទៀត គឺពាក់ព័ន្ធទៅនឹងជីវប្រវត្តិ ឬប្រវត្តិរូប។ ខ្ញុំនឹងមិនចូលទៅមើលប្រតិចារឹកនោះទេ ក៏ប៉ុន្តែនៅពេលដែលលោកចង់មើលប្រតិចារឹកនោះ គឺអាចធ្វើទៅបាន។ ហើយលោកក៏អាចដឹងថាចំណុចណាដែរ ដែលខ្ញុំចង់សួរនោះ។ គឺថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ភាគីសួរសំណួរលោកជាច្រើន ពាក់ព័ន្ធទៅនឹងការដែលគេប្រើប្រាស់ប្រវត្តិរូប។ នៅត្រង់ទំព័រ១៥ និង១៦ នៅក្នុងប្រតិចារឹកថ្ងៃទី២០ ខែកក្កដា ២០១២ នោះ ដែលខ្ញុំនឹងសួរម៉ោងដែលកត់ត្រានោះគឺ ០៩:--

[១៣:៤៦:១៣]

**អ្នកបកប្រែ៖**

បាទលោកប្រធាន សូមឲ្យលោកមេធាវីបញ្ជាក់ម៉ោងឡើងវិញ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបញ្ជាក់ឡើងវិញ ព្រោះបកប្រែបកអត់ទាន់ទេ។ ជាពិសេសចំណុចម៉ោង សូមបញ្ជាក់ឲ្យបានច្បាស់។

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** យើងឃើញមានការផ្លាស់ប្តូរយោបល់គ្នានៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ គឺត្រង់ទំព័រ១៥ និង១៦ ម៉ោងនោះគឺ ០៩:៣៥:០៧។ ការនិយាយឆ្លើយឆ្លងគឺមួយទៀត គឺនៅទំព័រ១០៨, ១០៩ ម៉ោងនោះ គឺ ១៥:០៨:០៩។ ខ្ញុំមិនចាប់អារម្មណ៍ចូលលម្អិតទៅអ្វីដែលលោកបាននិយាយនោះទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែចង់បញ្ជាក់ជូនលោកអំពីហេតុការណ៍ ដែលលោកបានលើកឡើងនៅក្នុងនុំង។

[១៣:៤៧:៣០]

អ្វីដែលខ្ញុំចង់លើកឡើងនៅទីនេះជាមួយលោកនុំង គឺចម្លើយរបស់លោកនៅថ្ងៃ០៦ ខែសីហា ឆ្នាំ ២០០៩។ ប្រសិនបើយើងមើលទៅលើប្រតិចារឹកនេះ យើងក៏មានដែរជាឯកសារក្រដាស ហើយប្រសិនបើអាចនោះ អាចបញ្ចាំងនៅលើអេក្រង់ផង។

គឺឯកសារ D288/4.59.1 ប្រតិចារឹកករណី ឌុច ខ្មែរឯកសារ ERN ជាភាសាខ្មែរគឺ 00361492, អង់គ្លេស ERN គឺ 00361370, បារាំង ERN គឺ 00361619 ត្រង់ទំព័រ៣២ ចូលទំព័រ៣៣។ ចាប់ផ្តើមពីជួរ១៥ មានសំណួរសួរមួយសួរទៅកាន់លោក ហើយខ្ញុំគិតថា សំណួរនេះសួរដោយចៅក្រម ខាតវ៉ាយច៍។ "តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលសន្និដ្ឋានថា ប្រវត្តិរូបនៅ -- កម្មាភិបាលនៅស-២១ គឺជាប្រភពព័ត៌មានសម្រាប់របបក្នុងការកំណត់ខ្មាំង? ឬក៏សម្រាប់គោលបំណងអាក្រក់មួយចំនួនរបស់របបនោះ?" លោកបានឆ្លើយនៅពេលនោះក្នុងរឿងក្តី ឌុច ថា "អត់ទេ មិនមែនអ៊ីចឹងទេ។ ខ្ញុំគិតថាមិនមានគោលបំណងអាក្រក់ណាមួយ ដែលគេស្នើបុគ្គលិកស-២១ ឱ្យរៀបចំប្រវត្តិរូបនោះទេ។ នេះគឺជាអ្វីដែលសមាជិកបក្ស ឬក៏យុទ្ធជននោះត្រូវតែធ្វើប្រវត្តិរូបនោះ នេះពីពេលមួយទៅពេលមួយ។ ខ្ញុំគិតថា មិនមែនអ៊ីចឹងទេ។ ខ្ញុំត្រូវលើកឡើងថា វាមិនមែនគោលបំណងដូច្នោះនោះទេ វាជាការអនុវត្តនាពេលនោះតែប៉ុណ្ណោះ ហើយវាជាការអនុវត្តជាសកល។ ប្រជាជននៅពេលនោះ គឺមិនថាអ្វីនោះទេ ប៉ុន្តែប្រហែលជាគេអាចប្រកាន់ នៅពេលដែលសុំឱ្យគេធ្វើប្រវត្តិរូបបែបនេះ។ នេះគឺជាលក្ខណៈជីវិតមួយនៅពេលនោះនៅក្នុងគុក ហើយមន្ទីរផ្សេងទៀតនោះ គឺក៏អាចទំនងជាធ្វើដូច្នោះដែរ ក៏ប៉ុន្តែមិនមានប្រវត្តិរូបណាមួយ ដែលនៅសល់ដូចនៅមន្ទីរស-២១។ តើលោកតាមទាន់នូវអ្វីដែលខ្ញុំអានអម្បាញ់មិញនេះដែរឬទេលោក?

**ធ៖** គឺបាទ ខ្ញុំកំពុងតែតាមដានហើយ គឺខ្ញុំកំពុងមើលអត្ថបទនេះទាំងមូលតែម្តង។

**ស៖** គឺសូមអរគុណ។ តើលោកនៅតែរក្សាពាក្យដែលលោកនិយាយនេះដដែល នៅក្នុងសវនាការ ឌុច ដែរឬទេ? ជាពិសេស គឺតើលោកនៅតែគិតថា វាស្របទៅនឹងអ្វីដែលលោកឆ្លើយនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ដែរឬទេ?

[១៣:៥១:០២]

**ឆ៖** ខ្ញុំគិតថា វាប្រហែលជាដូចគ្នា ហើយសង្ឃឹមថា អ្វីដែលលើកឡើងនៅថ្ងៃ២០ នោះគឺវាអាចស៊ីសង្វាក់គ្នា និងដូចគ្នាទៅនឹងថ្ងៃ៦ ខែសីហា នោះ។

**ស៖** ការដែលសួររឿង ឌុច នោះ គឺពាក់ព័ន្ធទៅនឹង ស-២១ ក៏ប៉ុន្តែអ្វីដែលលោកនិយាយតាមការស្រាវជ្រាវរបស់លោក គឺក៏វាអាចជាការអនុវត្តនៅតាមមន្ទីរផ្សេងទៀត ឬក៏ស្ថាប័នផ្សេងទៀតផងដែរ គឺគេមិនមានគោលបំណងអាក្រក់អ្វីទេ នៅពេលដែលគេឲ្យសរសេរប្រវត្តិរូបនោះ។ តើនេះ ទំនងជាអ្វីដែលលោកចង់បានន័យអ៊ីចឹងមែនដែរឬទេ? តើខ្ញុំសង្ខេបជំហរដែលលោកនិយាយនៅពេលនោះត្រឹមត្រូវដែរឬទេត្រង់ចំណុចនេះ?

**ឆ៖** ជាការពិត។ វាជាការសង្ខេបល្អ។ អ្នកដែលនៅខាងបក្ស អ្នក -- ប្រជាជនថ្មី និងអ្នក១៧ មេសា គឺគេដឹងហើយថា គេគិតថា វាជាបញ្ហាអាក្រក់ដោយសារតែគេមិនធ្លាប់បានឲ្យ អ្នកណាឲ្យ -- គេមិនធ្លាប់ -- នរណាមិនដែលបានឲ្យគេសរសេរប្រវត្តិរូបបែបនេះ។ ដូច្នេះ ហើយប្រជាជនថ្មី គឺយើងដឹងហើយថា បក្សគេប្រើព័ត៌មាន ស្ដីអំពីប្រវត្តិរូបរបស់បុគ្គលទាំងអស់នេះ យកមកធ្វើជាមូលដ្ឋាន។

[១៣:៥២:៤០]

**ស៖** សូមអរគុណ។ នៅថ្ងៃនេះ ខ្ញុំជឿថា លោកបាន -- នៅថ្ងៃនេះលោកបានបញ្ជាក់ថា តាមការយល់របស់លោក សុន សេន គឺជាបងទី៣។ ខ្ញុំមិនមែននិយាយអ៊ីចឹងទេ។ តាមអ្វីដែលលោកឆ្លើយកាលពីព្រឹកមិញ លោកបានបញ្ជាក់ថា សុន សេន នោះគឺគេស្គាល់ថាគាត់ហ្នឹង សមនឹងបងទី៣ ហើយលោកថា គាត់ជាបងទី៣។ តើលោកនៅតែរក្សាជំហរ រក្សាពាក្យនេះដដែលដែរឬទេ?

**ឆ៖** បាទ គឺខ្ញុំនៅតែរក្សាពាក្យ ដែលខ្ញុំនិយាយនេះដដែល។

**ស៖** សូមអរគុណ។ នៅពេលធ្វើសវនាការ ឌុច នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ ខ្មែរ ERN 00361534, អង់គ្លេស ERN គឺ 00361436, បារាំង ERN គឺ 00361689។ លោកបានបញ្ជាក់នៅក្នុងប្រតិចារឹកត្រង់ទំព័រ៩៨ នៃប្រតិចារឹកជួរទី១៥ លោកបានឆ្លើយថា "ខ្ញុំគិតថា នៅនិរតី តាម៉ុក មានស្វ័យភាពជាងមេដឹកនាំនៅភូមិភាគផ្សេងទៀត។ គាត់ជាបុគ្គលមួយមានអំណាចទី៣ នៅក្នុងឋានានុក្រម

ហើយគាត់មិនទទួលបញ្ជាពីនរណាក្រៅតែពី ប៉ុល ពត នោះទេ"។ បន្ទាប់មកលោកនិយាយទៀត ថា -- ដូច្នេះហើយ វាខុសបន្តិច នូវអ្វីដែលលោកនិយាយនៅថ្ងៃនេះ ក៏ប៉ុន្តែវាអាចបញ្ជាក់ថា អ្វីដែលលោកនិយាយនោះគឺអ៊ីចឹងមែន។ តើលោករក្សាពាក្យដដែលថា តាម៉ុក និង សុន សេន នោះគឺវាហាក់ដូចជាទី២, ទី៣ ឬក៏ទី៣, ទី៤ តើលោកនិយាយនេះ គឺលោកត្រឡប់ចុះ ត្រឡប់ឡើងលើបុគ្គលទីប៉ុន្មានៗ នោះ ឬក៏យ៉ាងម៉េច?

[១៣:៥៥:០៦]

**ឆ៖** គឺវាអ៊ីចឹងហើយ គឺវាហាក់ដូចជាមានការខុសគ្នាបន្តិចបន្តួច ដូចអ្វីដែលលោកបានបញ្ជាក់អម្បាញ់មិញនេះ។

**ស៖** សំណួរចុងក្រោយ បាទ មិនមែនសំណួរចុងក្រោយទេ គឺប្រធានបទចុងក្រោយ។ បាទ ខ្ញុំមិនគួរនិយាយថា សំណួរចុងក្រោយទេ ដោយសារថាប្រហែលខ្ញុំអាចសួរសំណួរផ្សេងទៀត។ ខ្ញុំចង់សួរថា នៅពេលដែលខ្ញុំមើលឯកសារសរសេរមួយចំនួនធ្វើឡើងដោយលោក ហើយនៅពេលដែលលោកឆ្លើយជាមួយនឹងមេធាវី នួន ជា នោះគឺលោកទំនងជាបញ្ជាក់ថា យ៉ាងហោចណាស់ នៅទសវត្សរ៍ឆ្នាំ១៩៨០ -- ខ្ញុំមិនយោងទៅលើឯកសារនោះទេ ក៏ប៉ុន្តែខ្ញុំនឹងបង្ហាញនូវអ្វីដែលលោកបាននិយាយ ហើយសួរឱ្យលោកបញ្ជាក់ថា ឯកភាព ឬក៏មិនឯកភាព។ នៅក្នុងទសវត្សរ៍ឆ្នាំ៨០ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺបានធ្វើការចងក្រងនូវចងចាំជាសមូហភាព ដើម្បីមានប្រយោជន៍សម្រាប់គោលបំណងរបស់គេនាពេលអតីតកាល និងពេលបច្ចុប្បន្ន។ ហើយលោកហាក់ដូចជានិយាយបន្ថែមទៀតថា ការចងចាំជាសមូហភាពនោះ វាជាការជារៀបរាប់បង្ហាញនូវភាពជាក់ស្តែងនៅពេលនោះ។

[១៣:៥៦:៤៨]

តើនេះជាអ្វីដែលលោកបានសរសេរ ឬក៏យ៉ាងម៉េច? ឬក៏លោកនៅថ្ងៃនេះ អាចនឹកឃើញដែរឬទេ អាចជម្រាបយើងដែរឬទេ ថាក្នុងនាមលោកជាប្រវត្តិវិទូ ការគិតគូររបស់លោកនោះ គឺលោកគិតយ៉ាងម៉េច និងបានយល់យ៉ាងម៉េចទៅលើអ្វីដែលខ្ញុំបញ្ជាក់អម្បាញ់មិញនេះ?

**ឆ៖** ចំណុចទីពីរ -- ទីមួយ គឺខ្ញុំពិតជាសរសេរអ៊ីចឹងមែន។ ខ្ញុំនៅតែរក្សាអ្វីដែលខ្ញុំសរសេរ។ ខ្ញុំមិនមានតួនាទីឆ្លើយទៅលើអង្គហេតុទេ មិនមែនជាតួនាទីរបស់ខ្ញុំនោះទេ។ ហើយគឺខ្ញុំត្រូវតែមើលឯកសារនោះ ដើម្បីពិភាក្សាលម្អិត។ ខ្ញុំសរសេរមែន។ ហើយគឺថាយើងអាចនិយាយថា វាពាក់ព័ន្ធទៅនឹងហេតុការណ៍ឆ្នាំ៧៩ និង៨០ ដោយផ្ទាល់តែម្តង។

**ស៖** ផ្អែកទៅលើចំណុចនេះ ខ្ញុំសូមសួរសំណួរមួយ ឬក៏ពីរ។ នៅពេលដែលលោកនិយាយអំពីពាក្យថា ការចងចាំជាសមូហភាព ដើម្បីបម្រើកម្មវិធីនយោបាយរបស់គេ។ នោះគឺខ្ញុំចង់សួរសំណួរទៅកាន់លោក មូលហេតុដែលខ្ញុំសួរនោះ គឺថានៅពេលអតីតកាល ថាតើមានបង្កើតជាព័ត៌មានរៀបរាប់ដូច្នោះ ហើយវាអាចប៉ះពាល់ទៅដល់ការចងចាំរបស់ប្រជាជននៅពេលនោះ ពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលកើតឡើងនាពេលអតីតកាល។ យើងដឹងហើយថា ពេលខ្លះទៅ ការចងចាំនេះ វាអាចធ្វើឲ្យមានការប្រឡាក់ប្រឡូសទៅនឹងអ្វីដែលគេចង់ឲ្យគេនិយាយដូច្នោះ។ ខ្ញុំមិនចង់ឲ្យមានការយល់ច្រឡំនោះទេ ក៏ប៉ុន្តែលោកអាចកែតម្រូវខ្ញុំបាន ប្រសិនបើខ្ញុំលើកចំណុចនេះខុស។

[១៣:៥៨:៤៦]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយ! ចាំស្តាប់អង្គជំនុំជម្រះសម្រេចលើសេចក្តីជំទាស់ របស់តំណាងសហព្រះរាជអាជ្ញាជាមុនសិន។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

យើងដឹងបានស្តាប់ឮការជំទាស់របស់មេធាវីការពារក្តី ផ្អែកទៅលើមូលដ្ឋានថា សាស្ត្រាចារ្យគាត់មិនមានគុណសម្បត្តិផ្តល់ចម្លើយទៅលើហេតុការណ៍ ពាក់ព័ន្ធទៅនឹងចិត្តសាស្ត្រប្រជាជន។ ដូច្នេះហើយ យើងខ្ញុំសូមលើកឡើងការជំទាស់ ផ្អែកទៅលើហេតុផលនេះដូចគ្នា ពីខាងមេធាវីការពារក្តី។ ដូច្នេះហើយ យើងដឹងហើយថាលោកសាស្ត្រាចារ្យ គឺគាត់មិនអាចឆ្លើយទៅលើផលប៉ះពាល់ទៅលើចិត្តសាស្ត្រ និងចងចាំរបស់ប្រជាជន នៅក្នុងឆ្នាំ១៩៧៩ នោះទេ។ ហើយខ្ញុំមិនដឹងថា តើការឆ្លើយរបស់ប្រជាជននៅពេលនោះ គិតពិត ឬក៏មិនពិតនោះឡើយ។

[១៣:៥៩:៤០]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន។ ខ្ញុំឯកភាពជាមួយនឹងសហព្រះរាជអាជ្ញា។ លោកសាស្ត្រាចារ្យ ឆេនដ័រ បានបញ្ជាក់ថា គាត់បានសរសេរឃ្លោងឃ្លាហ្នឹង ហើយគាត់នៅតែរក្សាអ្វីដែលគាត់សរសេរដដែល។ ខ្ញុំគ្រាន់តែសួរឲ្យលោកសាស្ត្រាចារ្យបញ្ជាក់បំភ្លឺតែប៉ុណ្ណោះ។ ហើយគឺលោកសាស្ត្រាចារ្យ គាត់អាចធ្វើការផ្តល់ចម្លើយដោយមិនពាក់ព័ន្ធទៅនឹងការ ទាយស្មានលើចិត្តសាស្ត្រ។ ហើយប្រសិនបើគាត់មិនអាចឆ្លើយបាន

នោះ គឺក៏វាមិនអីដែរ។ ខ្ញុំគិតថាអង្គជំនុំជម្រះគាត់ពិតជាចង់ដឹងចំណុចនេះ។ ការជំនុំជម្រះរបស់យើងគឺដើម្បីចង់ឲ្យមានការរៀបរាប់មួយលម្អិតសម្រាប់យើងស្ដាប់ទាំងអស់គ្នា។

[១៤:០០:៣២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០១:០១]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាសមស្រប។ អង្គជំនុំមិនចាំបាច់ស្ដាប់នូវចម្លើយតបរបស់អ្នកជំនាញចំពោះ -- សំណួរចុងក្រោយរបស់មេធាវីការពារក្ដីអន្តរជាតិរបស់លោក អៀង សារី ទេ។

[១៤:០២:០៦]

*(សម្រាករយៈពេលខ្លី)*

[១៤:០២:០៣]

**លោក ម៉ៃខល កាណាវាស៖**

ការជំទាស់មានប្រសិទ្ធភាព លោកមិនបាច់ឆ្លើយសំណួរនេះទេ។ សាស្ត្រាចារ្យ ឆេនដ័ល័រ ក្នុងនាមលោក អៀង សារី ខ្ញុំ និង អាង ឧត្តម សូមអរគុណដែលលោកបានមកផ្ដល់សក្ខីកម្ម សូមជូនពរឲ្យលោកមានសុខភាពល្អ ហើយធ្វើដំណើរដោយសុវត្ថិភាព។ សូមអរគុណលោក លោកស្រីចៅក្រម ភាគីទាំងអស់ ជាពិសេសដែលបានផ្ដល់ឱកាសឲ្យខ្ញុំបានសួរលោកសាស្ត្រាចារ្យ ដេវីដ ឆេនដ័ល័រ។

[១៤:០២:៣៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសាស្ត្រាចារ្យ!

**លោក ដេវីដ ឆេនដ័ល័រ៖**

ខ្ញុំសូមឆ្លើយដោយខ្លី។ ហើយខ្ញុំសូមអរគុណ ដែលបានផ្ដល់ឱកាសឲ្យខ្ញុំ នេះជាបទពិសោធន៍ដ៏គួរឲ្យចាប់អារម្មណ៍ក្នុងការឆ្លើយនៅក្នុងការសួរ និងឆ្លើយ។ ហើយសូមជូនពរឲ្យលោកមានសំណាងល្អដូចខ្ញុំដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះអ្នកជំនាញ ដេវីដ ឆេនដ៏ល័រ។ សូមអញ្ជើញ!

[១៤:០៣:២៥]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ជាបឋមសូមជម្រាបសួរក្រុមប្រឹក្សាជំនុំជម្រះ សូមជម្រាបសួរអង្គសវនាការទាំងមូល និងជម្រាបសួរលោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៏ល័រ ផងដែរ។

ខ្ញុំបាទមានសំណួរមួយចំនួន ដើម្បីជម្រាបសួរលោក ហើយខ្ញុំសង្ឃឹមថាលោកនឹងសហការឆ្លើយចំពោះសំណួររបស់ខ្ញុំបាទ។ ហើយបើសិនជាលោកមានចម្ងល់ស្តាប់មិនច្បាស់ លោកអាចសួរបញ្ជាក់ខ្ញុំសាឡើងវិញ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ជាបឋមខ្ញុំសូមសួរលោកថា តើលោកស្តាប់ជាភាសាអង់គ្លេស ឬជាភាសាខ្មែរ?

**លោក ដេវីដ ឆេនដ៏ល័រ៖**

**ឆ៖** ខ្ញុំស្តាប់ជាភាសាអង់គ្លេសភាគច្រើន ព្រោះថាខ្ញុំមិនអាចបើកឯកសារហ្នឹងទាន់។ ហើយខ្ញុំស្តាប់ជាអង់គ្លេស ដើម្បីឆ្លើយសំណួរនេះ ប៉ុន្តែខ្ញុំបានឮភាសាខ្មែរខ្លះដែរ?

[១៤:០៥:៤៧]

**ស៖** បាទ សូមអរគុណ។ ដោយសារបញ្ហាបកប្រែ ខ្ញុំជឿជាក់ថាការទាក់ទងរវាងពីភាសាខ្មែរមកអង់គ្លេសនេះវាអាចត្រូវធ្វើការចន្លោះ ដូច្នេះលោកអាច -- មើលទៅហាក់ដូចជាមិនទាន់ពេលវេលា។ អ៊ីចឹងខ្ញុំជាទូទៅ ខ្ញុំបង្អង់ដើម្បីរង់ចាំការបកប្រែ អ៊ីចឹង សូមលោកអធ្យាស្រ័យផង។ សំណួរជាបឋមខ្ញុំសុំសួរថា តើការស្រាវជ្រាវរបស់លោកនៅក្នុងសម័យតាំងពីចាប់ផ្តើមការស្រាវជ្រាវទាក់ទងនឹងកម្ពុជាប្រជាធិបតេយ្យមកនោះ តើលោកទៅស្រាវជ្រាវតែម្នាក់ឯង ឬក៏មានជាក្រុមនៃអ្នកស្រាវជ្រាវចូលរួមជាមួយ?

**ឆ៖** ជួនកាលខ្ញុំធ្វើការជាមួយមនុស្សផ្សេងទៀត ប៉ុន្តែភាគច្រើនបំផុតនោះ ខ្ញុំធ្វើការតែម្នាក់ឯង ជួនកាលមានអ្នកបកប្រែ ហើយជួនកាលមានក្រុមអ្នកស្រាវជ្រាវមកពីសាកលវិទ្យាល័យផងដែរ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

**ស៖** បាទ សូមអរគុណ។ ចំពោះពេលដែលលោកធ្វើការតែឯង តើបើប្រៀបធៀបទៅនឹងពេលវេលាដែលលោកធ្វើការ លោកចំណាយពេលក្នុងការសិក្សាស្រាវជ្រាវហ្នឹង ជាភាគច្រើន ឬមួយក៏ភាគតិច តាមអ្វីដែលលោកចាំបាន?

[១៤:០៥:១២]

**ឆ៖** ខ្ញុំមិនប្រាកដថា ខ្ញុំស្ដាប់សំណួរលោកយល់ទេ។ ខ្ញុំបានសរសេរឯកសារ ឬក៏សរសេរលទ្ធផលដោយខ្លួនឯង។ ខ្ញុំមិនច្បាស់ពីសំណួររបស់លោក ខ្ញុំមិនយល់សំណួររបស់លោកបានច្បាស់ទេ។ សូមទោស។

**ស៖** បាទ សូមអរគុណ។ ខ្ញុំនឹងសួរបញ្ជាក់លោកសាឡើងវិញ។ អម្បាញ់មិញនេះ លោកបានឆ្លើយជូនក្រុមប្រឹក្សាជំនុំជម្រះថា ការស្រាវជ្រាវរបស់លោក លោកបានធ្វើការជាក្រុម ឬមួយក៏ជួនកាលលោកធ្វើការតែម្នាក់ឯង ក្នុងការធ្វើការស្រាវជ្រាវនោះ ហើយពេលខ្លះក៏លោកថាមានអ្នកបកប្រែផង។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់សាឡើងវិញថា តើការស្រាវជ្រាវរបស់លោក ដែលធ្វើតែម្នាក់ឯងនោះមាន -- បើប្រៀបធៀបទៅនឹងពេលវេលា តើលោកធ្វើការវាមានជាចំនួនភាគច្រើន ឬមួយក៏ភាគតិចនៃពេលវេលានៃការស្រាវជ្រាវរបស់លោក?

**ឆ៖** គឺថាភាគច្រើន ខ្ញុំធ្វើការតែម្នាក់ឯង ហើយពេលដែលសម្ភាសនៅជំរំខៅអ៊ីដាងឆ្នាំ៨៤ -- ១៩៨៤ នោះគឺ -- ហើយខ្ញុំបានប្រើអ្នកបកប្រែ ប៉ុន្តែខ្ញុំ គឺថាភាសាខ្មែររបស់ខ្ញុំ ខ្ញុំអាចយល់បាន គឺថា ខ្ញុំប្រើអ្នកបកប្រែតែសំណួរពិបាកៗមួយចំនួនតែប៉ុណ្ណោះទេ។ ហើយក្រោយមកខ្ញុំឈប់ប្រើអ្នកបកប្រែ។ នៅក្នុងការសិក្សាជាភាសាបារាំង ខ្ញុំមិនដែលប្រើអ្នកបកប្រែទេ។ ពេលខ្លះខ្ញុំមិនបានសម្ភាសមនុស្សដែលនិយាយភាសាវៀតណាម ឬក៏ថៃទេ។ ភាគច្រើនចំពោះអ្នកដែលផ្ដល់សម្ភាសជាភាសាខ្មែរ ខ្ញុំបានប្រើអ្នកបកប្រែមួយចំនួន ហើយមិនមានអ្នកបកប្រែមួយចំនួនបាទ។

[១៤:០៨:០៦]

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកអញ្ជើញទៅសម្ភាសជាមួយពលរដ្ឋខ្មែរ ហើយលោកមិនមានអ្នកបកប្រែទៅជាមួយ តើលោកមានបញ្ហាអ្វីខ្លះក្នុងការទំនាក់ទំនងជាមួយអ្នកដែលលោកត្រូវសម្ភាសនោះទេ?

**ឆ៖** បាទ ពិតហើយ ខ្ញុំគិតថា ការសម្ភាសផ្ទាល់មុខគ្នានេះជាមួយខ្មែរ ជាពិសេសមានអ្នកម្នាក់ដែលអាចជួយគឺថា ខ្ញុំសួរជាភាសាខ្មែរ ហើយឲ្យគេឆ្លើយ។ ប៉ុន្តែមានអ្នកនៅក្បែរ ដែលអាចជួយខ្ញុំ ខ្ញុំមិន

នៅតែម្នាក់ឯងដាច់ខាត ប៉ុន្តែកម្រណាស់ដែលខ្ញុំនៅម្នាក់ឯងនោះ ពេលក្រោយនោះគឺថា ខ្ញុំឃើញបញ្ហាមួយចំនួន ដែលថា ខ្ញុំយល់ភាសាខ្មែរកម្រិតខ្លះមានអ្នកជំនួយដែរ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំអាចសូមបញ្ជាក់លោកសាឡើងវិញថា តាមសម្តីរបស់លោក ភាសាខ្មែររបស់លោក ដែលប្រើប្រាស់សម្រាប់ទំនាក់ទំនងធ្វើការស្រាវជ្រាវនោះគឺមានកម្រិត។ អ៊ីចឹងត្រឹមត្រូវទេ?

[១៤:០៩:៣៣]

**ឆ៖** ការប្រាស្រ័យទាក់ទងរបស់ខ្ញុំនៅជាមួយខ្មែរហ្នឹង គឺថាអាចនឹងមានកម្រិត ប៉ុន្តែខ្ញុំអាចយល់បានភាសាខ្មែរច្រើន។ ខ្ញុំអាចទុកចិត្តបាន គឺថាអាចនឹងនៅក្នុងឆ្នាំ៨០ និង៩០ គឺថា ភាសាបារាំង ក៏មិនមែនជាភាសាកំណើតខ្ញុំមានឃើញកម្រិតខ្លះ ក៏ប៉ុន្តែខ្ញុំបានប្រើអ្នកបកប្រែការសម្ភាសជាមួយមនុស្សមួយចំនួនជាភាសាបារាំងនោះ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរបញ្ជាក់អំពីស្ថានភាពនៅពេលដែលបកប្រែ -- ធ្វើការស្រាវជ្រាវនោះបន្ថែមបន្តិចថា នៅពេលដែលលោកសាកសួរទៅលើបុគ្គលណាម្នាក់ តើលោកសួរជាលក្ខណៈសម្ងាត់តែពីរនាក់បុគ្គលនោះ ឬក្នុងស្ថានភាពដែលមានមនុស្សដទៃទៀតនៅក្បែរហ្នឹងច្រើនហើយដែលមានការបញ្ចេញបញ្ចូលសួរយោបល់អីជាដើម?

**ឆ៖** វាអាស្រ័យទៅលើបរិបទ។ ការសម្ភាសខ្លះនោះ គឺថាការសម្ភាសសម្ងាត់ ប៉ុន្តែពេលខ្លះសម្ភាសនៅក្នុងបន្ទប់ដែលមានអ្នកផ្សេងអាចស្តាប់បាន គឺថាវាអាស្រ័យទៅលើប្រភពព័ត៌មានដែលខ្ញុំចង់បាន ដែលថាប្រភេទសំណួរនោះ វាមិនមែនលក្ខណៈធ្វើឲ្យមានបញ្ហាស្រួចស្រាល់ ឬក៏មានការខ្មាសអៀន គឺថាអ្នកផ្សេងអាចស្តាប់បាន ប៉ុន្តែពេលខ្លះគឺថាសម្ភាសដាច់ដោយឡែកនោះដែរ។

[១៤:១១:០៩]

**ស៖** លោកមានដែលជួបស្ថានភាពដែលថា នៅពេលដែលលោកសម្ភាសឈ្មោះ "ក" ក៏ប៉ុន្តែបុគ្គល "ខ" ជាអ្នកឆ្លើយជំនួសវិញទេ។ មានដែលជួបស្ថានភាពបែបហ្នឹងទេ?

**ឆ៖** ខ្ញុំមិនអាចចាំនូវករណីច្បាស់លាស់នោះទេ។ អត់ទេ មិនមែនបញ្ហាហ្នឹង ខ្ញុំយល់ពីសំណួររបស់លោក។ នៅពេលដែលខ្ញុំសួរអ្នកណាម្នាក់ អ្នកផ្សេងទៀតឆ្លើយជំនួស។ ខ្ញុំមិនបានចាំថា ខ្ញុំសម្ភាសជួបករណីនោះទេ។ វាអាចមានករណី ប៉ុន្តែខ្ញុំមិនចាំថាមានករណីនោះទេ ពេលដែលខ្ញុំសម្ភាសនោះ។ ប៉ុន្តែសុំបន្ថែម គឺថាអ្នកដែលខ្ញុំសម្ភាសហ្នឹង គឺថាគេមិនដែលនាំមកជាមួយអ្នកជួយគាត់គេ គឺថាគាត់

ច្រើនតែមកម្នាក់ៗឯង។ មិនមែនជាការសម្ភាសបែបច្បាប់ បែបផ្លូវតុលាការទេ គឺថាមិនមែនមានអ្នកណាម្នាក់ជាអ្នកនាំពាក្យជំនួសទេ គឺថាមិនធ្លាប់មានករណីបែបនេះទេ ពេលដែលខ្ញុំសម្ភាសនោះ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងពេល លោកអាចជម្រាបក្រុមប្រឹក្សាជំនុំជម្រះបានទេថា តើភាគច្រើនការសម្ភាសរបស់លោកនេះចាប់ពីពេលណា មកដល់ពេលណា? បានន័យថាពីឆ្នាំណាដល់ឆ្នាំណាក៏បាន បើសិនជាលោកមិនចាំថ្ងៃខែពិតប្រាកដ សម្រាប់ការសរសេរសៀវភៅអត្ថបទនានា ដែលពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមាននៅក្នុងឯកសាររបស់តុលាការនេះ?

[១៤:១២:៥៩]

**ឆ៖** បាទ ខ្ញុំបានចាប់ផ្ដើមការសម្ភាសទាក់ទងទៅនឹងការងាររបស់ខ្ញុំជាក់លាក់ហ្នឹង នៅឆ្នាំ ១៩៨៥ សម្ភាសជនភៀសខ្លួននៅ ខៅអ៊ីដាង គឺថាវាមានការទាក់ទងទៅនឹង -- ជាពិសេសនូវការងាររបស់ អូ.អិន.អេច.ស៊ី.អ័រ នៅឆ្នាំ១៩៨៥, ៨៦ រហូតដល់១៩៩០, ៩១, ៩២, ៩៣ គឺសម្ភាសនៅអូស្ត្រាលី បារាំង សហរដ្ឋអាមេរិក កាណាដា នៅកម្ពុជា និងប្រទេសថៃ។ ហើយដូច្នេះ កាលបរិច្ឆេទនោះគឺថា នៅកម្ពុជា គឺថាគឺមិនដែលមិនសម្ភាសនៅពេលយប់ទេ គឺថាម៉ោងពេលធ្វើការដូចនៅកម្ពុជា។ គឺថា ហើយក៏មិនដែលសម្ភាសនៅពេលយប់ជ្រៅដែរ គឺសម្ភាសនៅក្នុងពេលម៉ោងធ្វើការ ដោយមានការយល់ស្របពីអ្នកដែលផ្ដល់សម្ភាស ការសម្ភាសទាំងអស់នេះ គឺដូចដែលខ្ញុំបញ្ជាក់ខាងដើម គឺសួរជាអង់គ្លេស បារាំង ឬក៏ភាសាខ្មែរ។ គឺអាស្រ័យទៅលើភាសា អ្នកដែលផ្ដល់សម្ភាសគេចង់ស្ដាប់ភាសាអី។ ហើយខ្ញុំបានផ្ដល់បទសម្ភាសន៍ប្រជាជនខ្មែរមួយចំនួននៅប្រទេសបារាំង កាណាដា អ្នកខ្លះនៅក្នុងប្រទេសអូស្ត្រាលី ខ្ញុំសម្ភាសជាភាសាអង់គ្លេស ហើយនិងនៅសហរដ្ឋអាមេរិកក៏សួរជាភាសាអង់គ្លេសដែរ។

[១៤:១៤:៣២]

**ស៖** បើសិនជាលោកអាចផ្ដល់ជាភាគរយបាន ថាតើលោកភាគច្រើនធ្វើសម្ភាសចំពោះជនភៀសខ្លួន ឬមួយក៏អ្នកនៅស្រុកខ្មែរ?

**ឆ៖** សូមទោស ខ្ញុំមិនស្ដាប់បានពាក្យខាងដើមទេ។ តើលោកចង់សួរខ្ញុំ តើលោកសម្ភាសជនភៀសខ្លួនឬក៏អ្នកណាខ្លះ? ខ្ញុំបាត់សំណួរខាងដើមថា ខ្ញុំចាប់បានតែ ឬជនភៀសខ្លួន ពីមុនហ្នឹងខ្ញុំស្ដាប់មិនបាន។ បាទ សួរឡើងវិញ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរថា អ្នកដែលលោកបានសម្ភាសហ្នឹងភាគច្រើនជាជនភៀសខ្លួន ឬក៏ជាជនជាតិខ្មែរដែលរស់នៅស្រុកខ្មែរ?

[១៤:១៥:៣៦]

**ឆ៖** ភាគច្រើនជនភៀសខ្លួនរហូតមកដល់ឆ្នាំ១៩៩០ ហើយខ្ញុំមកកម្ពុជា ដើម្បីស្រាវជ្រាវនោះ គឺក្រោយពេលហ្នឹងនៅឆ្នាំ១៩៩០ ភាគច្រើននោះគឺខ្ញុំសួរនៅកម្ពុជា។ ប៉ុន្តែភាគច្រើននៃបទសម្ភាសន៍ហ្នឹងគឺចាប់ពី១៩៨៥ ដល់ឆ្នាំ៩៥ហ្នឹង គឺថាភាគច្រើនខ្ញុំសម្ភាសជនភៀសខ្លួន ប្រជាជននៅជំរំខៅអ៊ីដាង ហើយជាប្រជាជនដែលនៅក្រៅប្រទេសកម្ពុជានាសម័យនោះ។

**ស៖** បាទ សូមអរគុណ។ តើលោកមានធ្វើការបែងចែកប្រភេទអ្នកដែលលោកត្រូវសម្ភាសហ្នឹង ថាអ្នកណាជាអ្នកគាំទ្រកម្ពុជាប្រជាធិបតេយ្យ ហើយក្រុមណាជាអ្នកមិនគាំទ្រកម្ពុជាប្រជាធិប-តេយ្យដែរឬទេ?

**ឆ៖** គឺថាមិនបានដឹងទេ មុនពេលដែលខ្ញុំសម្ភាសពួកគាត់នោះ នៅពេលដល់ចំពោះ ខ្ញុំមិនដឹងថាគេប្រកាន់ជំហរអ្វី? គឺថាមានមនុស្សមួយចំនួនតូចដែលគាំទ្រខ្មែរក្រហមនៅពេលនោះ រហូតមកដល់ឆ្នាំ១៩៩០ ប៉ុន្តែអ្នកខ្លះមានទស្សនៈតុល្យភាពទេ ខ្ញុំមិនជំទាស់ទៅនឹងព័ត៌មានដែលគេផ្តល់ឲ្យខ្ញុំនោះទេ។ ម្យ៉ាងទៀត ខ្ញុំមិនបានស្វែងរកដូចថា ភស្តុតាងដាក់បន្ទុកឬក៏ការចោទប្រកាន់នោះទេ។ ខ្ញុំចង់បានព័ត៌មានជាអព្យាក្រឹតឲ្យបានច្រើនតាមដែលខ្ញុំអាចរកបាននោះ។

[១៤:១៧:១៥]

**ស៖** បាទសូមអរគុណ។ តើលោកមានវិធានការបែបណាដើម្បីទទួលបាននូវព័ត៌មានជាលក្ខណៈអព្យាក្រឹតពីអ្នកដែលលោកបានសម្ភាសនេះ ដែលថាអ្នកដែលលោក -- ដែលគេផ្តល់បទសម្ភាសន៍ឲ្យលោកនោះ គេមិនមាននិន្នាការនយោបាយក្នុងការវាយប្រហារអីជាដើម?

**ឆ៖** នេះ គឺជាសំណួរដ៏លំបាក ហើយគឺថាយើងអាចសួរទៅអ្នករស់រានមានជីវិតពីខ្មែរក្រហម គឺថា យើងចង់បានទស្សនៈអព្យាក្រឹតនោះ គឺខ្ញុំយល់ឃើញថា ខ្ញុំមិនដែលបានឃើញដែលថាគេមានទស្សនៈអំពីកម្ពុជាប្រជាធិបតេយ្យ អ្នកខ្លះគេយល់ស្របថា របបនោះពេល -- អ្នកខ្លះទៀតក៏គេបដិសេធអំពីរបបនោះ ប៉ុន្តែយើងតែត្រូវទទួលយកមតិគេទាំងពីរនេះ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមទាញអារម្មណ៍លោកទៅចំណុចថ្មីទាក់ទៅនឹងលោក ខៀវ សំផន តើលោកបានស្គាល់លោក ខៀវ សំផន ពីមុនមកទេ?

**ឆ៖** ទេ ខ្ញុំមិនដែលបានជួបគាត់ ឬក៏និយាយជាមួយគាត់ពីមុនមកទេ។ ប៉ុន្តែខ្ញុំសូមបន្ថែមថា ខ្ញុំស្គាល់គាត់ដោយសារគាត់មានប្រជាប្រិយភាព កិត្តិយស។ ខ្ញុំតាមដានអាជីពរបស់គាត់ដោយយកចិត្តទុកដាក់ ប៉ុន្តែខ្ញុំមិនដែលបានទាក់ទងជាមួយគាត់ទេ។

**ស៖** បាទ សូមអរគុណ។ តើលោកស្គាល់ពីឈ្មោះគាត់ ឬក៏ភាពល្បីល្បាញរបស់គាត់ហ្នឹងនៅពេលណាដែរ?

[១៤:១៩:១៨]

**ឆ៖** បាទ គឺថាក្នុងពេលជាមួយគ្នា នៅពេលដែលខ្ញុំនៅកម្ពុជាឆ្នាំ១៩៦០ ដល់៦២។ គាត់ជាមនុស្សល្បី ហើយជាមនុស្សដែលមនុស្សដាច់ខាត ហើយមនុស្សមានសរសើរអំពីភាពសុចរិតរបស់គាត់។ ខ្ញុំគិតថា ៗសម្តេចសីហនុ មានការភ័យខ្លាចគាត់ដោយសារថា គាត់មនុស្សមួយដែលស្អាតស្អំគឺថាមានកិត្តិយស គឺថាអាចនឹងជាមនុស្សសំខាន់ក្នុងសង្គមទាក់ទងទៅនឹងក្រុមមនុស្សសំខាន់ដែលថា ធ្វើឲ្យព្រះអង្គមានការព្រួយបារម្ភពីគាត់ ហើយវាជាក្របខ័ណ្ឌវិជ្ជមានមួយ។ ខ្ញុំចង់បន្ថែម ខ្ញុំធ្វើការឲ្យស្ថានទូតសហរដ្ឋអាមេរិក ហើយយើងយល់ថាគាត់ជាមនុស្សក្នុងក្រុមឆ្វេងនិយម គឺថា -- ហើយអ្វីដែលនៅជុំវិញអំពីគាត់ហ្នឹង ដែលកម្ពុជាផ្សេងៗ គេស្គាល់គាត់ហ្នឹង គឺថាមួយចំនួនច្រើន គឺកោតសរសើរគាត់។ ខ្ញុំបានចាកចេញពីស្រុកខ្មែរក្នុងឆ្នាំ១៩៦២។ បាទ អ៊ីចឹងគឺខ្ញុំបានដឹងឮគឺប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សូមឲ្យលោកបញ្ជាក់ទៅលើចម្លើយរបស់លោកអម្បាញ់មិញដែលថាសម្តេច នរោត្តម សីហនុ មានការព្រួយបារម្ភ ឬក៏ភ័យខ្លាចពីសមត្ថភាពរបស់លោក ខៀវ សំផននេះ។ តើមានមូលហេតុអីដែរ? សូមលោកជួយបញ្ជាក់បន្ថែមបន្តិចមើលថា ហេតុអីបានជាត្រូវមានការព្រួយបារម្ភបែបនេះ? បើខ្ញុំស្តាប់នូវសម្តីរបស់លោកមិនច្បាស់ សូមលោកជួយបញ្ជាក់សាឡើងវិញផង។

[១៤:២១:១៥]

**ឆ៖** ខ្ញុំព្យាយាមដូចខាងដើម ខ្ញុំមិន -- គឺថាគាត់ជាមនុស្សដែលសម្តេច សីហនុ មិនដឹងថាត្រូវធ្វើការជាមួយគាត់ដូចម្តេច។ គាត់ដឹងថា គាត់មានបទពិសោធន៍ជាមួយប្រជាជន គឺថាអាចនឹងមានឥទ្ធិពល ឬក៏អាចនឹងទាក់ទងទៅនឹងមួយចំនួនដែលថា អំពីបែបបទនយោបាយរបស់គាត់នេះ គាត់បានទទួលស្គាល់ក្នុងការសំណេររបស់គាត់ហ្នឹង គាត់និយាយថា ហ៊ុន សែន -- នៅក្នុងរបបមួយដែលថាជាផ្នែកពាណិជ្ជកម្មដែលថា ខៀវ សំផន នោះគឺថានៅក្នុងគណៈរដ្ឋមន្ត្រី គឺថាមិនពាក់ព័ន្ធទៅនឹងអំពើពុករលួយនោះទេសម័យគាត់នោះ សម្តេច សីហនុ នោះគាត់យល់ថានេះជាមនុស្សមិនថាគាត់មិនចូលចិត្តទេ

គាត់មិនចូលចិត្តមនុស្សជាច្រើន ប៉ុន្តែគាត់ថានេះជាមនុស្សដែលអាចធ្វើការទាក់ទងទៅនឹងគោលការណ៍
សីលធម៌ ទាក់ទងនឹងក្រុមការងាររបស់គាត់ ក្រុមមួយដែលបង្ហាញឃើញលេចធ្លោនោះ។

**ស៖** សូមអរគុណ។ ខ្ញុំសូមធ្វើការបញ្ជាក់សាឡើងវិញ អម្បាញ់មិញខ្ញុំមានឮសូរពាក្យតាមរយៈ
ការបកប្រែ ដូចជាមិនសូវច្បាស់ ថាទាក់ទងទៅ -- ឮដូចថា ហ៊ុន សែន យ៉ាងម៉េច ខ្ញុំអត់ស្តាប់បាន។
អាចសូមលោកជួយបញ្ជាក់ថា លោកមានបានប្រើពាក្យនេះទេ? បើអត់ទេ សូមជួយកែតម្រូវផងបាទ។

[១៤:២២:៥៥]

**ឆ៖** ខ្ញុំមិនបាននិយាយទេ។ ហើយខ្ញុំមិនដឹងថា ខ្ញុំនិយាយអំពីសម្តេច សីហនុ ទេ។ ហើយ
សម័យកាលនេះ ក្នុងឆ្នាំ៦០ ខ្ញុំមិនបាននិយាយពីឈ្មោះ ហ៊ុន សែន ទេ។ ខ្ញុំមិនបាន ហ៊ូ នឹម, ហ៊ូ យន់
នោះដែរ ដែលថាមិនធ្វើឲ្យពាក្យហ្នឹងមិនឲ្យឮឈ្មោះស្រដៀងនឹងពាក្យថា ហ៊ុន សែន នោះទេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំយល់ហាក់ដូចជាអត់សូវច្បាស់ ហើយខ្ញុំជឿថា អង្គជំនុំជម្រះ
ប្រហែលជាអាចយល់មិនច្បាស់ដែរ ទាក់ទងទៅនឹងថាហេតុអីបានជាសម្តេច នរោត្តម សីហនុ ខ្លាច
លោក ខៀវ សំផន ដោយសារតែលោក ខៀវ សំផន ជាមនុស្សល្អ មនុស្សស្មោះត្រង់ ធ្វើការគ្មានអំពើ
ពុករលួយ? តើលោកអាចមានអ្វីបញ្ជាក់បន្ថែមឲ្យច្បាស់ជាងនេះទៀតទេ?

**ឆ៖** មិនដោយសារសមត្ថភាពរបស់គាត់ទេ ព្រោះថាគាត់ជាមានមនុស្សមានសមត្ថភាពទទួល
ការអប់រំខ្ពស់ ហើយគាត់ថា គាត់មានជំនាញខាងសេដ្ឋកិច្ច។ ប៉ុន្តែសម្តេច សីហនុ មិនចូលចិត្តគាត់នោះ
គឺដោយហេតុថា ទោះបីជា ខៀវ សំផន ពលីកម្មចំពោះការងារមួយចំនួន គោរពទៅតាមក្រុមសីលធម៌
នៅក្នុងសម័យនោះ គាត់មាននិស្សិតច្រើន ហើយៗគាត់អាចឈានដល់តួនាទីមួយដែលថាមានឥទ្ធិពល
ក្នុងសង្គម។ ប្រហែលជាគេយល់បែបនេះ។

[១៤:២៤:៤៩]

**ស៖** បាទ សូមអរគុណ។ តាមការសិក្សាស្រាវជ្រាវរបស់លោក តើលោកអាចបង្ហាញអង្គជំនុំ
ជម្រះឲ្យបានច្បាស់ក្រៅពីថា លោក ខៀវ សំផន គាត់រត់ចូលព្រៃដោយសារតែមានការប្រកាសអំពី
ឈ្មោះអ្នកឆ្វេងនិយម ៣៤នាក់។ តើលោកមានហេតុផលអ្វីដែលអាចបញ្ជាក់អំពីការរត់ចូលព្រៃរបស់
លោក ខៀវ សំផន នោះទេ?

**ឆ៖** ខ្ញុំគួរតែយកសៀវភៅមកជាមួយខ្ញុំ ហើយខ្ញុំមិនអាចឆ្លើយលម្អិតអំពីបញ្ហានេះដែរទេ។ នៅ
ពេលដែលយើងសរសេរប្រវត្តិសាស្ត្រកម្ពុជានោះ សម័យកាលនេះគឺថាមានភាពមិនងាយស្រួលនៅក្នុង

បញ្ហាជម្លោះនៅកម្ពុជា ដូចការបះបោរនៅសំឡូត ដូចជាការប្រកាន់លទ្ធិម៉ៅ ហើយ ហ៊ូ នឹម រងការស្តីបន្ទោស ហើយលោក ខៀវ សំផន បាននៅទីនោះ ដោយមានការគាំទ្រនៅរដ្ឋសភា ឆ្នាំ១៩៦៦ ហើយមិនមានសមាជិកមួយចំនួនមិនត្រូវបានតែងតាំងដោយសម្តេច សីហនុ ទេ។ ហើយពេលនោះគាត់ប្រកាន់យកនយោបាយឆ្វេង ហើយក្រោយមក គឺថាគាត់មានសំឡេងភាគច្រើនគាំទ្រ ហើយពេលនោះគឺថា គេចាត់ទុកថាជាខ្មាំងនោះ គឺថាជាក្រុមខុសពីទិសដៅរបស់សហរដ្ឋអាមេរិក ដូចជាបក្សកុម្មុយនីស្តកម្ពុជា យើងមិនបាច់ប្រៀបធៀបទេ គឺថាគេហៅថាខ្មាំងនៅក្នុងប្រទេស អាចនឹងជំទាស់ទៅនឹងព្រះអង្គ។ ប្រហែលជាគាត់យល់ត្រូវ ហើយយើងដឹងហើយគឺថាប្រវត្តិលោក ខៀវ សំផន ហ្នឹង គឺថាគាត់ធ្វើទំនងជាជំទាស់ទៅនឹងរបបសង្គមរាស្ត្រនិយមនោះ។

[១៤:២៦:៥៥]

ដូច្នេះហើយគាត់មានការព្រួយបារម្ភ ហើយគាត់ក៏ចាត់ការតាមរបៀបមួយរបស់ព្រះអង្គនោះដែរ។ ហើយលោក ខៀវ សំផន ក៏បានបញ្ជាក់នៅក្នុងប្រវត្តិរូបរបស់គាត់ផងដែរ គាត់ថា ធ្វើឲ្យសម្តេច សីហនុ យល់ថាអាចជាការគំរាមកំហែង ប៉ុន្តែមិនបាននិយាយជាពាក្យទេ។ ប៉ុន្តែប្រហែលជាសម្តេច សីហនុ យល់ថារឿងការគិតហ្នឹងត្រូវ ពីព្រោះថាក្រោយមក គឺថាលោក ខៀវ សំផន ក៏មានការភ័យខ្លាច ហើយក៏បានចាកចេញពីភ្នំពេញទៅ ក្រោយមកនោះ។

**ស៖** បាទសូមអរគុណ។ ចំពោះប្រសាសន៍របស់លោក ដែលបានបញ្ជាក់ថា លោក ខៀវ សំផន មានការភ័យខ្លាច ហើយបានចាកចេញទៅហ្នឹង តើមានសញ្ញាណអ្វី ឬក៏សកម្មភាពអ្វី ដែលបញ្ជាក់ធ្វើឲ្យលោក ខៀវ សំផន ហ្នឹងភ័យខ្លាច ហើយដែលគាត់ត្រូវតែចាកចេញពីទីក្រុងទៅចូលព្រៃដែរឬទេ?

[១៤:២៨:១៦]

**ឆ៖** ភស្តុតាងដែលខ្ញុំទទួលបានហ្នឹង គឺនៅក្នុងប្រវត្តិរូបរបស់គាត់ គឺថាខ្ញុំត្រូវមើលពិនិត្យឡើងវិញ គឺគំនិតហ្នឹង គឺថាមិនផុសចេញពីពាក្យរបស់គាត់ដោយផ្ទាល់ទេនៅពេលដែលគាត់ចាកចេញពីភ្នំពេញនោះទេ។ គាត់មិនបាននិយាយថា ខ្ញុំចេញពីភ្នំពេញ ហើយខ្ញុំមិនសប្បាយចិត្ត ខ្ញុំត្រូវទៅរស់នៅជនបទទេ គាត់ទទួលស្គាល់ផង។ ខ្ញុំត្រូវមើលអត្ថបទហ្នឹង ខ្ញុំប្រាកដថា គាត់ទទួលស្គាល់ថា គាត់អាចមានការភ័យខ្លាចនឹងអ្វីកើតឡើងចំពោះគាត់។ ហើយមិនបានបញ្ជាក់នៅក្នុងប្រវត្តិរបស់គាត់ដែរ គឺថាដែលថាយុទ្ធនាការរបស់សម្តេច សីហនុ គឺថាអាចនឹង រីកធំទៅៗ ពួកឆ្វេងនិយមគឺថាអាចបង្កគ្រោះទៅ

ដល់ពួកគាត់។ ជាពិសេសចំពោះវត្តមានរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលលោក ខៀវ សំផន ជាសមាជិកសម្ងាត់នៅក្នុងនោះ។

[១៤:២៩:១៣]

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញលោកមានប្រសាសន៍ថា លោក ខៀវ សំផន ជាសមាជិកសម្ងាត់របស់ ស៊ី.ភី.ខេ។ គឺគណបក្សកុម្មុយនីស្តកម្ពុជា អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** តើលោកៗមានភស្តុ--

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** សូមអធ្យាស្រ័យ សូមលោកមានប្រសាសន៍ម្តងទៀត ដើម្បីឲ្យមានការបកប្រែទៅភាសាផ្សេង។ អម្បាញ់មិញហ្នឹង គាត់ឆ្លើយថា ខ្ញុំឮគាត់ឆ្លើយថា "*យេស*" ប៉ុន្តែអត់មានបកប្រែអ៊ីចឹង សូមឲ្យជួយពន្យល់ទៅគាត់ឲ្យបកប្រែផង។ សូមជួយបកប្រែឲ្យគាត់ឆ្លើយផង។

**ឆ៖** បាទ ចម្លើយគឺថា ខ្ញុំឆ្លើយថា បាទ។ ជួនកាលខ្ញុំឆ្លើយទៅ មីក្រូមិនទាន់បើកបាទ។

**ស៖** ខ្ញុំចង់សួរបញ្ជាក់ទៅលោកសាស្ត្រាចារ្យថា តើលោកមានភស្តុតាង ឬក៏អ្វីបញ្ជាក់ថា លោក ខៀវ សំផន ជាសមាជិកសម្ងាត់ក្នុងបក្សកុម្មុយនីស្តកម្ពុជានោះ?

[១៤:៣០:៥០]

**ឆ៖** ខ្ញុំមិនមានចំពោះមុខខ្ញុំថ្ងៃនេះទេ ប៉ុន្តែខ្ញុំអាចយកមកថ្ងៃស្អែកបាន គឺថាមិនមាននៅក្នុងដីកាដំណោះស្រាយទេ។ ខ្ញុំអាចត្រឡប់មកវិញ គឺថាដោយមានឯកសារយោងជាក់លាក់ គឺថា គេភាគច្រើនបានដឹង គឺថាមិនមានការបដិសេធជាសាធារណៈទេ។ ប៉ុន្តែខ្ញុំមិននិយាយដោយស្មានទេ គឺថា គឺជាអង្គហេតុដែលគេបានទទួលស្គាល់យូរណាស់មកហើយ ហើយខ្ញុំចង់បានឃើញៗភស្តុតាងណាដែលផ្ទុយពីនេះ។ ហើយខ្ញុំឃើញពីប្រភពរបស់ខ្ញុំៗនឹងប្រើឯកសារនោះជាបង្អែក។

**ស៖** ខ្ញុំអាចសួរបញ្ជាក់ថា អ៊ីចឹងស្អែកលោកនឹងយកឯកសារ ដែលលោកបញ្ជាក់នេះ យកមកជូនក្រុមប្រឹក្សាជំនុំជម្រះដើម្បីបង្ហាញ ឬមួយយ៉ាងម៉េច?

**ឆ៖** បាទ ហើយខ្ញុំគ្រាន់តែស្នើឲ្យសមាជិក នៃ -- ហើយគាត់មិនមែនជាសមាជិករហូតមកដល់ឆ្នាំ១៩៧១ ប្រសិនបើខ្ញុំឆ្លើយខុស ហើយខ្ញុំច្រឡំគឺថា ខ្ញុំនឹងយកឯកសារមកបង្ហាញលោកនៅថ្ងៃស្អែក។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីពេលវេលាផងបានទេ ថាតើពេលវេលាហ្នឹងចាប់ពីពេលណាមកដល់ពេលណា ដែលថាលោក ខៀវ សំផន ជាសមាជិកសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជា?

**ផ៖** ហើយខ្ញុំត្រូវឆ្លើយនៅថ្ងៃស្អែកផងដែរ។ បាទ ខ្ញុំមិនមានព័ត៌មានកាលបរិច្ឆេទនេះទេនៅថ្ងៃនេះនោះបាទ។

[១៤:៣២:៥៩]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរលោកជាលក្ខណៈពិសេសមួយថា តើលោកបានសិក្សាអំពីប្រវត្តិរូបរបស់លោក ខៀវ សំផន ដោយឡែកដែរឬទេ? ឬមួយក៏លោកគ្រាន់តែសិក្សាជាលក្ខណៈទូទៅទេ?

**ផ៖** យើងឃើញថា វាមានឯកសារភ្ជាប់នៅក្នុងសៀវភៅរបស់គាត់ ហើយខ្ញុំបានមើលសៀវភៅនេះយ៉ាងលម្អិតផងដែរ។ ខ្ញុំមិនផ្តោតជីវប្រវត្តិរបស់គាត់ផ្ទាល់នោះទេ ដូចវាខុសពីប្រវត្តិរូបរបស់ ប៉ុល ពត ក៏ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំបានសិក្សាចាប់អារម្មណ៍ទៅលើប្រវត្តិរូបរបស់គាត់ផងដែរ។

**ស៖** បាទ សូមអរគុណ។ ការចាប់អារម្មណ៍របស់លោកនេះគឺ ដោយសារតែលោក ខៀវ សំផន គាត់ជាមេដឹកនាំក្នុងសម័យក្រោយឆ្នាំ៧៩ ឬមួយក៏ចាប់តាំងពីសម័យដែលលោក ខៀវ សំផន រត់ចូលព្រៃដំបូង?

[១៤:៣៤:៣២]

**ផ៖** ខ្ញុំប្រហែលជាមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ទៅលើចំណុចនេះ។ ខ្ញុំសិក្សាគាត់យ៉ាងចាប់អារម្មណ៍ ដោយសារតែយើងឃើញថា គាត់ជាជនមួយរូប ថ្នាក់ដឹកនាំដែលល្បីមួយរូបនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយគាត់ជនឆ្វេងនិយមនៅក្នុងសម័យ សីហនុ ហើយនៅក្នុងប្រទេសកម្ពុជា គឺគាត់គេស្គាល់គាត់ច្រើន គាត់ល្បី។ ខ្ញុំអានព័ត៌មានពាក់ព័ន្ធនឹងគាត់ ដោយសារតែមានព័ត៌មានច្រើនណាស់ដែលពាក់ព័ន្ធទៅនឹងគាត់។ ហើយខ្ញុំមិនចាប់អារម្មណ៍ថា ពីពេលណាមកនោះទេ ដែលខ្ញុំចាប់អារម្មណ៍គាត់នោះ គឺថាខ្ញុំអានរយៈ -- ពាក់ព័ន្ធនឹងគាត់ គឺនៅពេញអ្វីដែលជាព័ត៌មានទាក់ទងនឹងគាត់តែម្តង។

[១៤:៣៥:២៩]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរសំណួរនេះ ដើម្បីភ្ជាប់ទៅសំណួរក្រោយទៀតរបស់ខ្ញុំ ទាក់ទងទៅនឹងសមាជិកភាពរបស់លោក ខៀវ សំផន ជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា។ លោកអាចបញ្ជាក់បានទេថា តើលោក ខៀវ សំផន គាត់ចូលក្នុងបក្សកុម្មុយនីស្តកម្ពុជានៅពេលណា?

**ឆ៖** គឺគិតថា លោកបានសួរប្រាំនាទីមុនផងដែរ។ ដូច្នេះហើយ គឺខ្ញុំមិនអាចប្រាប់លោកនោះទេនៅថាគាត់ចូលទៅពេលនោះ គឺខ្ញុំអាចប្រាប់នៅថ្ងៃស្អែកបាន។

**ស៖** ប៉ុន្តែសំណួរមុនរបស់ខ្ញុំ គឺលោកបានមានប្រសាសន៍អំពីការចូលបក្សជាសម្ងាត់ ហើយពេលនេះ ខ្ញុំសួរនេះ គឺក្នុងលក្ខណៈ បើតាមន័យជាសម្ងាត់របស់លោក អ៊ីចឹងបានន័យថា វាមានលក្ខណៈជាចំហ។ អ៊ីចឹង ខ្ញុំចង់សួរបញ្ជាក់ជាលក្ខណៈជាចំហដែលគេដឹងនេះ។ តើលោកអាចបញ្ជាក់បានទេ បើឬមួយក៏លោកថារង់ចាំស្អែកដែរ?

[១៤:៣៦:៥៥]

**ឆ៖** គឺមិនមែន -- មិនមានពេលណាមួយ ដែលថាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជានោះចូលជាចំហនោះទេ គឺការចូលបក្សនោះ គឺជាចូលដោយសម្ងាត់។ ដូច្នេះហើយ នៅពេលដែលគេចូលបក្សនោះ គឺចូលជាសមាជិកសម្ងាត់ទាំងអស់គ្នា។ គឺថាព័ត៌មានដែលខ្ញុំអាចផ្តល់បាន គឺនឹងយកចេញពី -- ទៅមើលនៅក្នុងបន្ទប់របស់ខ្ញុំសិន ទើបខ្ញុំអាចមកប្រាប់លោកបញ្ជាក់ឲ្យបានច្បាស់បាន។ យើងឃើញថា បក្សនេះមិនមែនដំណើរការជាចំហនោះទេ។ យើងឃើញថា បក្សនេះ មិនដំណើរការជាចំហរហូតមកដល់ឆ្នាំ៧៧។ ដូច្នេះហើយ សមាជិកហ្នឹង គឺបានន័យថា ចូលជាសមាជិកហ្នឹងដោយសម្ងាត់ទាំងអស់ មិនមានចូលជាចំហនោះទេ។

**ស៖** បើខ្ញុំសួរលោកអំពីតួនាទីរបស់លោក ខៀវ សំផន នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា តើលោកអាចឆ្លើយបានទេមើលទៅ នៅពេលនេះ?

**ឆ៖** គឺថាខ្ញុំអាចឆ្លើយបាន ហើយខ្ញុំសង្ឃឹមថា ខ្ញុំអាចជួយពន្យល់ប្រាប់លោកបាន។

**ស៖** បាទ សូមអរគុណ។ តើលោកដឹងថា លោក ខៀវ សំផន ចូលជាសមាជិកមជ្ឈិមត្រៀមនៅពេលណាទេ?

[១៤:៣៨:៥០]

**ឆ៖** បាទ គឺបាន គឺគាត់ចូលជាសមាជិកមជ្ឈិមត្រៀមនៅក្នុងឆ្នាំ១៩៧១។

**ស៖** ចុះគាត់ពេញសិទ្ធិនៅឆ្នាំណា?

[១៤:៣៩:០៩]

**ឆ៖** នេះជាចំណុចមួយដែលគេសួរខ្ញុំម្តងដែរ ហើយខ្ញុំគិតថា ខ្ញុំប្រាកដជាសរសេរនៅក្នុងកំណត់ហេតុរបស់ខ្ញុំទៅលើឆ្នាំនេះ ខ្ញុំព្យាយាមរកមើលសិន សូមលោកចាំបន្តិច។ បាទ អក្សរខ្ញុំរបស់គឺគគ្រិច។ ខ្ញុំកំពុងតែរកហើយ។ គឺក្នុងឆ្នាំ -- គាត់ក្លាយជាសមាជិកមជ្ឈិមត្រៀមឆ្នាំ៧១។ ប្រភពដែលខ្ញុំប្រើប្រាស់ គឺឯកសារដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងឯកសារកំណត់ហេតុស្តាប់ចម្លើយ និងកំណត់ហេតុសួរចម្លើយរបស់ ខៀវ សំផន។ ហើយនៅក្នុងកំណត់ហេតុនោះ លេខជើងទំព័រ៤៤៣៥ ហើយគាត់ក្លាយជាសមាជិកពេញសិទ្ធិនៅក្នុងខែកក្កដា ឆ្នាំ១៩៧៦។

**ស៖** លោកមានប្រសាសន៍លឿនពេក អ៊ីចឹងទៅការបកប្រែ ខ្ញុំពិបាកស្តាប់ជាភាសាខ្មែរ ព្រោះខ្ញុំស្តាប់ជាភាសាខ្មែរ។ សូមលោកជួយពន្យឺតបន្តិច។ សូមអធ្យាស្រ័យ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មិនបាច់ឆ្លើយទេ--

**លោក គង់ សំអុន៖**

អាចសុំឱ្យគាត់បញ្ជាក់សំណួរ -- ចម្លើយចុងក្រោយរបស់គាត់នេះបន្តិចទៅលោកប្រធាន។

[១៤:៤១:០៣]

**ប្រធានអង្គជំនុំ៖**

សូមលោកអ្នកជំនាញ សូមបញ្ជាក់នូវចម្លើយរបស់លោកចុងក្រោយនេះអម្បាញ់មិញនេះ ដោយសារលោកនិយាយញាប់ពេក ការបកប្រែហ្នឹង បាត់នូវខ្លឹមសារខ្លះ។ សូមលោកបញ្ជាក់នូវចម្លើយចុងក្រោយរបស់លោកសាជាថ្មីម្តងទៀត។

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំប្រហែលជា ហាក់ដូចជាចង់ឆ្លើយពាក្យ ដូច្នេះហើយទើបខ្ញុំបានមើលទៅលើព័ត៌មានទាំងអស់នេះ។ គាត់ក្លាយជាសមាជិកមជ្ឈិមត្រៀមនៅក្នុងឆ្នាំ១៩៧១ ព័ត៌មានដែលខ្ញុំដកស្រង់ចេញមកនេះ គឺចេញពីលេខជើងទំព័រ៤៤៣៥ នៃដីកាដំណោះស្រាយចេញមកពីកថាខណ្ឌ១១៣០ ហើយនិងកំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន។ វាជាឯកសារជំនុំជម្រះ ហើយចេញពីមាត់របស់លោក ខៀវ សំផន ដោយផ្ទាល់។ គាត់ក្លាយជាសមាជិកពេញសិទ្ធិនៅក្នុងខែកក្កដា ឆ្នាំ១៩៧៦។ ឯកសារនេះ ប្រភពខ្ញុំយកចេញមកពីលេខទំព័រ៤៦៣៩។ ដូច្នេះហើយគឺ យើងអាចពិនិត្យមើលទៅលើព័ត៌មាននេះបាន។

[១៤:៤២:៣១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់លោកមេធាវី អរគុណអ្នកជំនាញ។ ឥឡូវនេះដល់ពេលសមល្មមសម្រាក ហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូល វិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីអ្នក ជំនាញ ដល់អ្នកជំនាញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលា ម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:១១]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

លោកមេធាវីមានបញ្ហា? សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា សូមលោក ឲ្យនូវប្រធានបទនៃ -- សង្ខេបដែលលោកមានបំណងក្នុងការធ្វើសេចក្តី -- ដែលលើកនិយាយនេះ ឬក៏ សំណូមពរនេះ ដើម្បីឲ្យអង្គជំនុំជម្រះពិនិត្យសម្រេចលើបញ្ហានេះមុនថា ឲ្យនិយាយ ឬក៏មិនឲ្យនិយាយ។

[១៥:០២:២២]

**លោក អេនឌ្រូ អ៊ីអាន្ធូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកស្រីចៅក្រម ដោយសង្ខេបខ្ញុំចង់ស្នើដើម្បីឲ្យ

ទទួលស្គាល់ឯកសារថ្មីមួយ ដើម្បីសូមការបំភ្លឺពីអង្គជំនុំជម្រះ អំពីឯកសារថ្មីមួយ។ ខ្ញុំបានកាន់ឯកសារថ្មីមួយគឺថានៅក្នុងឯកសារដែលបានបង្កើតកាលពីម្សិលមិញនេះ គឺដែលមានព័ត៌មានដែលទាក់ទងនឹងរឿងក្តី គឺមានព័ត៌មានមួយចំនួនដែលខ្ញុំចង់ដាក់សួរដេញដោលសាស្ត្រាចារ្យ ឆេនដ័ល័រ ដែលថាអាច នៅពេលដែលគាត់វត្តមាន ហើយខ្ញុំសូមការណែនាំពីអង្គជំនុំជម្រះ ដោយការសួរថា តើៗខ្ញុំបានការអនុញ្ញាតដើម្បីផ្តល់សេចក្តីសន្និដ្ឋានពីរមីនុត ដើម្បីទាក់ទងរឿងហ្នឹងដែរឬអត់ទេ? ខ្ញុំអាចធ្វើសេចក្តីសន្និដ្ឋាន ហើយខ្ញុំនឹងអាចជូនឯកសារទៅឲ្យភាគីទាំងអស់ ឲ្យពួកគាត់អាចមើលយប់នេះ ហើយដើម្បីឲ្យគាត់ឆ្លើយនៅព្រឹកស្អែក។ ពេលនោះអង្គជំនុំជម្រះអាចសម្រេច សម្រេចថាតើយើងខ្ញុំបានការអនុញ្ញាតដើម្បីសួរសាស្ត្រាចារ្យ ឆេនដ័ល័រ ពីឯកសារថ្មីនេះដែរបានបោះពុម្ពផ្សាយម្សិលមិញនេះ គឺមាន១១ទំព័រ ហើយខ្ញុំនឹងមើលនៅយប់នេះ។ ហើយខ្ញុំនឹងធ្វើសេចក្តីសន្និដ្ឋានស្អែកព្រឹក ខ្ញុំនឹងគោរពទៅតាមវិធាន៨៧(៤) គោរពទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ នេះជាសំណើរបស់ខ្ញុំលោកប្រធាន។

[១៥:០៣:៥៧]

**ប្រធានអង្គជំនុំ៖**

ឯកសារថ្មី ឯកសារមាននៅក្នុងសំណុំរឿង ឬក៏ឯកសារមាននៅក្នុងបញ្ជីនៃឯកសារ ដែលភាគីណាមួយនៃភាគីក្នុងសំណុំរឿង០០២ បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ? សូមលោកបញ្ជាក់អំពីប្រភពឯកសារដែលលោកមានបំណងក្នុងការលើកឡើងនេះឲ្យបានច្បាស់។

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

បាទ លោកប្រធានជាឯកសារថ្មីថៃស នៅក្នុងអត្ថន័យថា ជាអត្ថបទសារព័ត៌មានផ្សាយពីម្សិលមិញនៅក្នុងកាសែត ញូវយ៉កប៉ុស្តិ៍ គឺជាឯកសារថ្មីមិនធ្លាប់មានពីមុនមកទេ គឺថា២៤ម៉ោង មុនសវនាការបើកមិនមានទេ ក្រោយបានយើងមាន។

[១៥:០៤:៥៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០៦:៥២]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីចៅក្រម ដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ សំណើត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ អនុលោមទៅតាមវិធាន៨៧(៤) ហើយយ៉ាងហោចណាស់គឺថាមូលហេតុដែលយើងបញ្ជាក់នោះ គឺថាអត្ថបទសារព័ត៌មានដែលទាក់ទងហ្នឹងមានតែភាសាមួយទេ ហើយមិនអាចឲ្យធ្វើសេចក្ដីសម្រេចបានទេ រហូតទាល់តែឯកសារវែងនេះ ត្រូវបានបកប្រែទៅជាភាសាខ្មែរយ៉ាងហោចណាស់។ ដូច្នេះ ដើម្បីឲ្យអង្គជំនុំជម្រះអាចពិភាក្សា ហើយអាចឈានដល់សេចក្ដីសម្រេចបាន។ សូមអរគុណ។

[១៥:០៧:៤៣]

**លោក អេនឌ្រូ អ៊ីនួហ្ស៊ី៖**

សូមអរគុណចៅក្រម ខាត់វ៉ាយថ៍ ចំពោះសេចក្ដីសម្រេចនេះ។ មូលហេតុដែលខ្ញុំស្នើនៅពេលនេះនោះគឺថា ខ្ញុំអាចធ្វើដោយផ្ទាល់មាត់ ដោយសង្ខេប គឺថាអាចបកប្រែទៅភាសាខ្មែរ ដើម្បីភាគីផ្សេងៗស្ដាប់បាននោះ។

**ប្រធានអង្គជំនុំ៖**

បានហើយ យើងសម្រេចរួចហើយ អង្គជំនុំជម្រះសម្រេចរួចហើយ។ មានអីចង់បន្ថែម សូមអញ្ជើញលោកស្រីចៅក្រម ខាតវ៉ាយថ៍!

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើសេចក្ដីថ្លែងរបៀបនេះទេ។ យើងបានកំណត់នូវវិធីសាស្ត្រក្នុងការគ្រប់គ្រងសវនាការនេះឲ្យមានប្រសិទ្ធភាពតាមវិធីនេះ យើងបានរំឭកលោកច្រើនលើកច្រើនសាហើយ។ លោកព្យាយាម យើងក៏ព្យាយាមគ្រប់គ្រងកិច្ចដំណើរការសវនាការនេះឲ្យខានតែបានដែរ នៅពេលវេលាក្នុងការពិភាក្សាដេញដោលឲ្យមានប្រសិទ្ធភាព។

[១៥:០៨:៣៥]

**លោក អេនឌ្រូ អ៊ីនួហ្ស៊ី៖**

សូមអរគុណលោកចៅក្រម ហើយខ្ញុំព្យាយាមចង់បង្ហាញមូលហេតុ។ ប្រសិនបើសំណើទាក់ទងទៅនឹងសាស្ត្រាចារ្យ ឆេនដ័ល័រ--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមបន្តសំណួរ។

[១៥:០៩:១៣]

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរសាជាថ្មីលោកសាស្ត្រាចារ្យ។ ឥឡូវ -- មុនពេលសម្រាកនេះ យើងបានពិភាក្សាអំពីការចូលជាសមាជិកភាពនៅក្នុងបក្សកុម្មុយនីស្តកម្ពុជារបស់លោក ខៀវ សំផន។ លោកបានឆ្លើយបញ្ជាក់ថា ចូលពេញសិទ្ធិនៅឆ្នាំ១៩៧៦ បាទ ហើយនិងចូលត្រៀមនោះឆ្នាំ១៩៧១។ អ្វីដែលលោកបានបញ្ជាក់ទៀតនោះ គឺថាលោកបានអានទៅលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបសួរនៅតុលាការនេះ ដែលជាឯកសាររបស់តុលាការនេះដែលបានបញ្ជាក់អំពីកាលបរិច្ឆេទនេះផងដែរ។ អ៊ីចឹងខ្ញុំសូមសួរលោកបញ្ជាក់សាឡើងវិញថា បើពីពេលមុន មុនដីកាដំណោះស្រាយនេះចេញ ឬក៏មុនពេលដែលលោកបានទទួលដីកាដំណោះស្រាយ ប្រហែលជាលោកមិនអាចដឹងពីកាលបរិច្ឆេទនៃការចូលជាសមាជិកភាពរបស់លោក ខៀវ សំផន នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ទាំងត្រៀមនិងពេញសិទ្ធិនោះទេ។ តើអ៊ីចឹងមែនទេ?

[១៥:១០:៥០]

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** ទាក់ទងទៅចំណុចនេះ ខ្ញុំសូមកែតម្រូវអំពីការឆ្លើយរបស់ខ្ញុំក្នុងការបកប្រែ។ ខៀវ សំផន មិនបានក្លាយជាសមាជិកត្រៀមនៅឆ្នាំ១៩៧១ទេ។ គាត់ជាសមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៧១ហើយគាត់ក្លាយជាសមាជិកពេញសិទ្ធិនៅក្នុងគណៈកម្មការដដែលហ្នឹងឆ្នាំ១៩៧៦។ ហើយយើងអាចយល់ថា អាចមានសមាជិកដែលមិនទាន់ជាសមាជិក គេអាចប្រកាសជាសមាជិកត្រៀម ហើយគាត់បាន គាត់អាចបានចូលសមាជិកហ្នឹង២៤ម៉ោងមុនហ្នឹង។ ខ្ញុំអាចរកមើលកាលបរិច្ឆេទ នៅពេលគាត់ចូល ចម្លើយដែលខ្ញុំឆ្លើយដូចអ្វីដែលខ្ញុំឆ្លើយនោះទេ។ គឺថាមិនមែនក្នុងបក្សទេ គឺនៅក្នុងមជ្ឈិមបក្ស គណៈមជ្ឈិមបក្ស។ ខ្ញុំព្យាយាមចង់ពន្យល់ជូនជាកាលបរិច្ឆេទនោះ គឺថាខ្ញុំផ្តល់កាលបរិច្ឆេទដែលគាត់ចូលត្រៀមនៅក្នុងគណៈមជ្ឈិម។ សូមកុំសួរខ្ញុំផ្ចាញ់ខ្ញុំបែបនេះ ខ្ញុំមិនចង់ឲ្យលោកសួរខ្ញុំបែបនេះទេ។

[១៥:១១:៥៨]

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមសួរបញ្ជាក់សាឡើងវិញ ពីព្រោះខ្ញុំស្តាប់ឮអ្វីដែលតាមរយៈការ

បកប្រែនេះថា លោក ខៀវ សំផន ចូលជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់មជ្ឈិមបក្សរបស់បក្សកុម្មុយនីស្តកម្ពុជា។ តើអ៊ីចឹង លោកឆ្លើយអ៊ីចឹង ឬមួយក៏ជាសមាជិករបស់គណៈមជ្ឈិម? សូមលោកជួយបញ្ជាក់ចំណុចនេះ។

**ឆ៖** សូមទោសបើសិននេះជាចម្លើយនៅក្នុងការបកប្រែ គឺថាដែលខ្ញុំអានពីកំណត់ហេតុហ្នឹង សូមអភ័យទោស។ គណៈអចិន្ត្រៃយ៍ជាផ្នែកនៃគណៈមជ្ឈិម ហើយបើលោកចាំគឺថា បើសិនជាលោកជាសមាជិកគណៈអចិន្ត្រៃយ៍ ហើយបើជាសមាជិកនៃគណៈមជ្ឈិម ជាសមាជិកអចិន្ត្រៃយ៍។ បើជាសមាជិកអចិន្ត្រៃយ៍ មិនមែនចាំបាច់ថា ចាំតែជាសមាជិករបស់មជ្ឈិមទេ។

**សៈ** សូមអរគុណ។ ប៉ុន្តែអំមិញនេះ បញ្ហាការបកប្រែ ខ្ញុំស្តាប់ដូចអត់សូវបាន។ អ៊ីចឹងសូមលោកមេត្តាពន្យឺតសម្តីរបស់លោកបន្តិច ដើម្បីឲ្យងាយដល់ការបកប្រែផង ពីព្រោះខ្ញុំស្តាប់ជាភាសាខ្មែរបាទ។

[១៥:១៣:២៨]

ខ្ញុំសូមលោកបញ្ជាក់ឡើងវិញអម្បាញ់មិញ លោកមានប្រសាសន៍ថា បើសិនជាបុគ្គលម្នាក់ជាសមាជិករបស់គណៈអចិន្ត្រៃយ៍ អ៊ីចឹងបានន័យថាជាសមាជិករបស់មជ្ឈិមហើយ។ ប៉ុន្តែ អ្នកដែលជាសមាជិកមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា មិនមែនជាសមាជិកអចិន្ត្រៃយ៍ទាំងអស់ទេ។ ខ្ញុំសូមឲ្យលោកជួយបញ្ជាក់។ លោកមានប្រសាសន៍អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំឆ្លើយអ៊ីចឹងមែន។

**សៈ** បាទ សូមអរគុណៗ។ ខ្ញុំសូមលោកបញ្ជាក់ទាក់ទងទៅនឹងកាលបរិច្ឆេទ ដែលថា លោកដឹងថា លោក ខៀវ សំផន ជាសមាជិកគណៈមជ្ឈិម ឬក៏ជាសមាជិកត្រៀមរបស់គណៈមជ្ឈិមហ្នឹង លោកដឹងនៅពេលណា?

[១៥:១៤:៥៤]

**ឆ៖** ខ្ញុំមិនអាចឆ្លើយឲ្យច្បាស់ទេនៅពេលនេះ។ ហើយខ្ញុំត្រូវរកកាលបរិច្ឆេទ ខ្ញុំនឹងប្រើឯកសារដែលមាននៅក្នុសណ្ឋាគាររបស់ខ្ញុំ។ ខ្ញុំបានដឹងពីមុន ខ្ញុំមិនអាចយោងទៅប្រភពនោះបាន។ ខ្ញុំមិនអាចឆ្លើយសំណួរបានទេ។ ខ្ញុំចង់ដឹងថា -- ខ្ញុំមិនចាំ ពីព្រោះថា ខ្ញុំអានប្រវត្តិរូបរបស់គាត់ ហើយខ្ញុំថាតើលោក ខៀវ សំផន បានបញ្ជាក់រឿងនេះ ហើយគាត់បានបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍ចំហានៅក្នុងប្រវត្តិរូបផ្ទាល់ខ្លួន។ អ៊ីចឹងគឺថា ខ្ញុំអានសៀវភៅរបស់គាត់ហ្នឹង គឺថាបីបួនឆ្នាំហើយ បើមិនមែននៅក្នុង

ប្រវត្តិរូបរបស់គាត់ទេ គឺថា ខ្ញុំនឹងរកប្រភពផ្សេងទៀតដែលនិយាយពីរឿងនេះ។

[១៥:១៥:៤០]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់សាឡើងវិញ ដោយសារយោងទៅលើសម្ដីរបស់លោក សក្ខីកម្មរបស់លោកមុនពេលឈប់សម្រាកនោះ លោកបានលើកអំពីការអានដីកាដំណោះស្រាយដែលលោកបានទទួល។ ដូច្នេះហើយបានខ្ញុំចង់សួរបញ្ជាក់ ថាតើលោកដឹងពីកាលបរិច្ឆេទដែលលោក ខៀវ សំផន ចូលជាសមាជិកមជ្ឈិមនិងមជ្ឈិមត្រៀមនោះ ក្រោយពីបានបានអានអត្ថបទដីកាដំណោះស្រាយនោះ ឬមួយក៏លោកដឹងមុន? នេះ ខ្ញុំគ្រាន់តែខ្ញុំចង់បញ្ជាក់រយៈពេលតែប៉ុណ្ណោះទេ។

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយ! ចាំស្ដាប់សេចក្ដីជំទាស់ របស់តំណាងសហព្រះរាជអាជ្ញា ជាមុនសិន។

**លោក អាប់ឌុលឡាក់ ថារីក៖**

សំណួរនេះបានសួរ ហើយលោកសាស្ត្រាចារ្យលោកបានឆ្លើយហើយ គឺថាគាត់បានដឹងព័ត៌មាននេះមុនអានដីកាដំណោះស្រាយ។

[១៥:១៧:១៧]

**លោក គង់ សំអុន៖**

សូមអធ្យាស្រ័យ ព្រោះក្នុងភាសាខ្មែរខ្ញុំអត់បានឮទេលោកប្រធាន។ អត់មានការបកប្រែឱ្យខ្ញុំដឹង។ ហើយបើអ៊ីចឹងមែន ដោយសារលោកសាស្ត្រាចារ្យនៅទីនេះហើយ លោកអាចបញ្ជាក់សាជាថ្មីក៏បានដែរ ព្រោះអម្បាញ់មិញនេះជាចម្លើយខ្លីទេ មិនទាមទារវែងទេ។

**លោក ដេវីដ ឆេនដ័ល័រ៖**

បាទ ខ្ញុំសូមអភ័យទោស។ ខ្ញុំគិត ខ្ញុំប្រមូលមកពីដំណើរការនីតិវិធីគឺថា បកប្រែទៅជាភាសាខ្មែរហ្នឹងគឺថា មានអ្នកជំនាញ ហើយខ្ញុំៗសូមអរគុណគឺថា គេបានធ្វើការងារល្អនោះ ប៉ុន្តែប្រភពមួយដែលខ្ញុំយកជាមួយខ្ញុំនោះ ដែលបោះពុម្ពបួនឆ្នាំមកហើយនោះគឺ សាលម៉ុន ខេន ជាទស្សនាវដ្ដី អ៎! ឯកសារវចនានុក្រមខ្មែរក្រហមគឺថាវាមានប្រវត្តិរូបគឺ និយាយពីកាលបរិច្ឆេទនេះដែរ។ គាត់មិនបានដាក់លេខយោងទេ ហើយខ្ញុំមិនបានយោងទៅរកប្រភព នេះជាសៀវភៅដែលខ្ញុំបានកាន់បួនឆ្នាំមកហើយ នៅពេលដែលខ្ញុំបានសរសេរហ្នឹង។

[១៥:១៨:៣៤]

ហើយនេះជាការចង្អុលបង្ហាញ គឺថាព័ត៌មាននេះ គឺខ្ញុំទទួលបានមុនខ្ញុំអានដីកាដំណោះស្រាយ។ ប៉ុន្តែឆ្លើយតបទៅនឹងសំណួរដែលសហព្រះរាជអាជ្ញាបានសួរហ្នឹង គឺផ្ដល់ឯកសារយោងច្បាស់លាស់ ដោយសារថា វាចេញមកពីឯកសារសាធារណៈហ្នឹង គឺថា *ហ្វូតណូត* នៅក្នុងដីកាដំណោះស្រាយមានលេខយោងគឺថា ដែលខ្ញុំលើកឡើងគឺថា ចម្លើយរបស់ ខៀវ សំផន នៅក្នុងឯកសារតុលាការ។ ប៉ុន្តែនេះជាព័ត៌មានអ្វីដែលថា លើសពីខ្ញុំបានព្រាងទុក អ្វីដែលលោកបានសួរខ្ញុំបន្ថែមនោះ។

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញលោកបានមានប្រសាសន៍ថា លោកបានអានអត្ថបទរបស់លោក ខៀវ សំផន សរសេរអំពីប្រវត្តិរូបរបស់លោក។ អ៊ីចឹង តើខ្ញុំអាចសរុបថា លោកមិនបានសិក្សាលម្អិត អំពីលោក ខៀវ សំផន ទេ។ អ៊ីចឹងត្រឹមត្រូវទេ?

[១៥:១៩:៤៤]

**ឆ៖** ទាក់ទងទៅនឹងយោងទៅរកអ្វីដែលខ្ញុំឆ្លើយពីមុនមិនត្រូវទេ។ ពេលខ្លះខ្ញុំបានអានដោយប្រុងប្រយ័ត្ន គឺថាសៀវភៅនិយាយអំពីប្រវត្តិរូប គឺថាវាមានប្រយោជន៍ខាងប្រវត្តិសាស្ត្រ។ ខ្ញុំមិនបានយកប្រវត្តិរូបផ្ទាល់ខ្លួនមកភ្នំពេញនេះទេ ប៉ុន្តែការប្រមូលឯកសារសៀវភៅរបស់ខ្ញុំ ក៏ខ្ញុំដាក់សៀវភៅមួយដែល-- សៀវភៅជាភាសាបារាំង និយាយថា "វចនានុក្រមសម័យខ្មែរក្រហម" ខ្ញុំមើលថា នេះជាប្រភពមួយដែលខ្ញុំយោង។ នេះមិនមែនប្រភពសម្រាប់ផ្អែកទៅលើប្រវត្តិរូបរបស់ ខៀវ សំផន។ ពេលខ្លះ ខ្ញុំអានប្រវត្តិរូបផ្ទាល់ខ្លួនរបស់គាត់ ហើយខ្ញុំទទួលស្គាល់ថា ជាឯកសារដែលត្រឹមត្រូវ គឺថាហើយមិនមែនខ្ញុំឆ្លើយមកពីប្រភពណាមួយ គ្មានប្រភពច្បាស់លាស់ទេ។ នេះគឺជា ខ្ញុំត្រូវតែមានលក្ខណៈអត្ថប្រយោជន៍ក្នុងឋានៈជាសាក្សី ដូចដែលខ្ញុំបានឆ្លើយលោកខាងដើមអ៊ីចឹង។

**ស៖** ខ្ញុំស្ដាប់ចម្លើយរបស់លោកដូចអត់ច្បាស់នឹងសំណួររបស់ខ្ញុំ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យដោយខ្លីទេ ថាអំពីប្រវត្តិរូបរបស់លោក ខៀវ សំផន នេះ លោកមិនបានសិក្សាលម្អិតទេ។ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ? ឧទាហរណ៍ដូចជា ក្នុងករណីលោក ប៉ុល ពត --*ប្រាយ៉ុរ ណាំប៊ីរ៉ែន*-- ដែលលោកបានសរសេរអ៊ីចឹង លោកបានសរសេរយ៉ាងលម្អិត តើវាមានលក្ខណៈអ៊ីចឹងទេ?

[១៥:២១:២៧]

**ឆ៖** ទេ ខ្ញុំមិនដែលសិក្សាប្រវត្តិរូប ខៀវ សំផន ដោយមានការយកចិត្តទុកដាក់សំខាន់ ដូចជាដូច បីឆ្នាំដូចរបស់ ប៉ុល ពត ទេ។ ប៉ុន្តែខ្ញុំសិក្សាពីប្រវត្តិរូបដោយលម្អិត ដោយមានការយកចិត្តទុកប្រភព

សំខាន់នៃព័ត៌មាននោះ គឺថាប្រវត្តិរូបផ្ទាល់ខ្លួនរបស់គាត់ ទាក់ទងទៅនឹងការបកប្រែ ទៅសេចក្ដីផ្ដើម -- *តែស* របស់គាត់នៅក្នុងឆ្នាំ១៩៧០ នោះ គឺថាហើយប្រភពហ្នឹង គឺថាតាមការស្រាវជ្រាវ គឺមិនបាន លម្អិតដូចការសិក្សាសរសេរសៀវភៅពី ប៉ុល ពត ថា "បងទី១" នោះទេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមបង្វែរអារម្មណ៍លោកទៅលើរចនាសម្ព័ន្ធ នៃកម្ពុជាប្រជាធិប-តេយ្យវិញម្ដង។ តើលោកអាចផ្ដល់សក្ខីកម្មជូនក្រុមប្រឹក្សាជំនុំជម្រះអំពីបញ្ហានេះបានទេ? ខ្ញុំនឹងតាំង សំណួរ។

**ឆ៖** ខ្ញុំរង់ចាំសំណួររបស់លោក ពីព្រោះបានពិភាក្សាច្រើននៅក្នុងសក្ខីកម្មកាលពីមុន។ ចម្លើយ របស់ខ្ញុំទាក់ទងទៅនឹងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ មិនដឹងថាចាប់ផ្ដើមពីដល់ណា ចំណុចណា ដល់ពេលណានោះ ដើម្បីវាស្របឲ្យស៊ីសង្វាក់គ្នានោះ គឺថាយើងមានពេល៤៥នាទីឯណោះ ដើម្បីនឹង ឆ្លើយ។ ប៉ុន្តែខ្ញុំចាំស្ដាប់សំណួរជាក់លាក់ពីលោកមកមុនសិន។

**ស៖** បាទ សូមអរគុណ។ សំណួររបស់ខ្ញុំ សូមសួរលោកថា តើកម្ពុជាប្រជាធិបតេយ្យមាន អង្គការអ្វីដែលដឹកនាំធំជាងគេ?

**ឆ៖** នេះជាសំណួរល្អណាស់។ មន្ទីរខ្ពស់បំផុតនៃកម្ពុជាប្រជាធិបតេយ្យ គឺប្រធាននៃគណៈ ប្រធានរដ្ឋ ដែលជាមុខតំណែងរបស់លោក ខៀវ សំផន ដូចដែលយើងដឹង។ យើងសង្ឃឹមថា ពីរបីថ្ងៃ នេះ លោកបានដឹងរួចហើយ ថាខ្ញុំបានឆ្លើយពីរបីថ្ងៃមកនេះ គឺជាមុខងារខ្ពស់បំផុតដែលមិនស្មើទៅៗនឹង មនុស្សផ្សេងទៀត ឬក៏ប្រជាជនផ្សេងទៀត ដែលអនុវត្តអំណាចនៅក្នុងកម្ពុជាប្រជាធិបតេយ្យទេ គឺជា មនុស្ស ជាមុខងារដែលមាន ហើយយើងមិនមានដឹងអ្វីអំពីភារកិច្ចដែលស្ថិតនៅក្នុងនោះទេ។ ប៉ុន្តែជា សាធារណៈ ជាតំណែងដែលបង្ហាញនៅក្នុងឯកសារសាធារណៈ ដូចជា រដ្ឋធម្មនុញ្ញ ការផ្សាយព័ត៌មាន បរទេសរបស់វិទ្យុភ្នំពេញ។ នេះហើយ គឺជាព័ត៌មានដែលយើងដឹង។

[១៥:២៤:៥១]

**ស៖** លោកផ្អែកទៅលើរដ្ឋធម្មនុញ្ញត្រង់ចំណុចត្រង់ណាដែរ ដែលលោកថា ប្រធានរដ្ឋ គណៈ ប្រធានរដ្ឋហ្នឹងជាអ្នកមានតំណែងធំជាងគេនៅក្នុងកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ខ្ញុំចង់បានអត្ថបទរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យនៅលើអេក្រង់។ ប៉ុន្តែ ខ្ញុំប្រាកដ គឺថានេះជាតួនាទីដែលគាត់បានទទួល គេចាត់តាំងគាត់ជាៗតំណែងដែលខ្ពស់បំផុតនៅក្នុងសម័យនោះ នៅក្នុងៗសភាតំណាងប្រជាជនគេនោះ។ ដូច្នេះហើយជាប្រធានគណៈប្រធានរដ្ឋ។ ខ្ញុំៗដឹងថា នៅក្នុងរដ្ឋ

ធម្មនុញ្ញ ប៉ុន្តែមិនដឹងក្នុងមាត្រាណា ឬក៏ឃ្លាបែបណា។ ខ្ញុំមិនចាំ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមស្តេះទុកចំណុចនេះត្រឹមនេះសិន ហើយខ្ញុំនឹងត្រឡប់មកវិញនៅពេលក្រោយ។ ខ្ញុំសូមត្រឡប់ទៅសំណួរដើមរបស់ខ្ញុំ ទាក់ទងទៅនឹងស្ថាប័នរបស់កម្ពុជាប្រជាធិបតេយ្យ ដែលមានគណបក្សកុម្មុយនីស្តកម្ពុជា និងមានរដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យ តើលោក--

[១៥:២៦:៣២]

**ឆ៖** ខ្ញុំ ចាំស្តាប់លោកឲ្យចប់សិន។

**ស៖** --តើលោកអាចធ្វើការវាយតម្លៃទៅតាមការស្រាវជ្រាវរបស់លោកបានទេថា ស្ថាប័នណាដែលមានឥទ្ធិពលខ្លាំងជាងគេ?

**ឆ៖** សូមអរគុណ។ ផ្អែកតាមសក្ខីកម្មពីខាងដើមរបស់ខ្ញុំ មានប្រភពបោះពុម្ពជាទូទៅនោះគឺថា កម្ពុជាប្រជាធិបតេយ្យនោះគឺថា មានអំណាចខ្លាំងជាងស្ថាប័នដែលបញ្ជាក់នៅក្នុងរដ្ឋធម្មនុញ្ញ។ នៅពេលដែលរដ្ឋាភិបាលដំណើរការគឺសមាជិកបក្សជាអ្នកដឹកនាំ ប៉ុន្តែរដ្ឋាភិបាលដែលបញ្ជាក់ក្នុងរដ្ឋធម្មនុញ្ញនេះ គឺចង់បង្ហាញថាវាមានការបែងចែកអំណាច។ មួយផ្នែកនេះខ្ញុំគិតថា ដើម្បីៗឲ្យអន្តរជាតិគេយល់បានកុំឲ្យថាជារដ្ឋផ្តាច់ការ។ ហ្នឹងគឺជាអំណាចហ្នឹងគឺវាមានការបែងចែកមែន ក៏ប៉ុន្តែបើយើងចង់និយាយគឺថា ស្ថាប័នរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យគឺមិនអាច -- មិនមានចែងនៅកន្លែងណាផ្សេងទេ មានលើកលែងតែនៅក្នុងលក្ខន្តិកៈបក្ស។ គឺថាមានតែបក្សកុម្មុយនីស្តកម្ពុជាទេដែលមានអំណាចនោះ គឺមិនមានប្រភពផ្សេងទៀតនៃអំណាចទេនៅកម្ពុជា នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ មានតែបក្សកុម្មុយនីស្តកម្ពុជាតែប៉ុណ្ណោះ។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់អម្បាញ់មិញថា បក្សកុម្មុយនីស្តកម្ពុជាអ្នកមានអំណាច។ ខ្ញុំសូមសួរបន្ថែមថា តើបក្សកុម្មុយនីស្តកម្ពុជានេះប្រើប្រាស់អំណាចរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាហ្នឹងតាមរយៈស្អីដែរ តាមរយៈអ្វីដែរ? ស្ថាប័នណា?

[១៥:២៨:៤៧]

**ឆ៖** ខ្ញុំគិតថា យើងបាននិយាយពីខាងដើម ជាសំណួរល្អ។ គេអនុវត្តអំណាចរបស់គេតាមរយៈគណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិមបក្ស ជាអំណាចកំពូលរបស់គេ ប៉ុន្តែគេបង្ហាញគេថា ត្រូវអនុវត្តតាមពីរ៉ាមីត ដូចដែលខ្ញុំនិយាយ។ ប៉ុន្តែសកម្មភាពរបស់រដ្ឋាភិបាលនិងបក្សកុម្មុយនីស្តកម្ពុជា គឺគ្របដណ្តប់

ដោយបក្សកុម្មុយនីស្តកម្ពុជា គឺមានឥទ្ធិពលលើមន្ទីរក្រសួងផ្សេងៗដែលថា ដែលមន្ទីរខ្លះមាននៅក្នុងរដ្ឋធម្មនុញ្ញ មន្ទីរខ្លះអត់។ អ៊ីចឹងហើយ ហើយដែលអ្នកខ្លះគេយល់ថា គឺជាបុគ្គលមានអំណាច។ ដូចជាលោកអៀង សារី មានក្រសួង -- គាត់កាន់ក្រសួងការបរទេស ជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេសជាដើមអ៊ីចឹង។ មិនមើលដូចជារដ្ឋាភិបាល ដែលយើងងាយក្នុងការពិនិត្យទេ។ មិនមែនជារដ្ឋាភិបាលដែលយើងងាយនឹងបែងចែកក្រសួងមន្ទីរដូចដែលប្រទេសធម្មតានោះទេ។ ពេលខ្លះគឺថាមានជាន់គ្នា ពេលខ្លះគឺស្រពេចស្រពិលក្នុងការបែងចែកអំណាចក្រសួងមន្ទីររបស់គេនោះ។ ដូចជាលោកនិយាយអំពីមន្ទីរ៨៧០ អ៊ីចឹង ជួនកាលគេនិយាយមនុស្ស ជួនកាលគេនិយាយពីស្ថាប័ន ជួនកាលស្ថាប័នហ្នឹងវាជាន់ អ៎! មុខងារនោះវាជាន់គ្នា។ មនុស្ស -- លេខកូដមនុស្ស និងលេខកូដស្ថាប័នហ្នឹងវាធ្វើឲ្យច្រឡំ។ អាហ្នឹងគឺបែបហ្នឹង។

[១៥:៣០:២២]

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ ខ្ញុំសុំលោកប្រធានអនុញ្ញាតដាក់បង្ហាញឯកសារដែលបានបង្ហាញជាច្រើនដងហើយលេខ E3/12 ទាក់ទងនឹងសេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ តើមានឯកសារជាក្រដាសជូនគាត់ទេ?

**លោក គង់ សំអុន៖**

បាទ មាន បើសិនជាលោកសាស្ត្រាចារ្យត្រូវការ ប៉ុន្តែក្រែងលោកធ្លាប់ទទួលបានច្រើនដងហើយ។

[១៥:៣១:២៣]

**លោក ដេវីដ ឆេនដ៍ល័រ៖**

ខ្ញុំមើលភាសាខ្មែរនៅលើអេក្រង់ វាក៏ល្អដែរ ក៏ប៉ុន្តែបើសិនបើអាចនោះឲ្យក្រដាសខ្ញុំជា -- ឲ្យឯកសារជាក្រដាសនោះកាន់តែល្អទៀត -- ឲ្យឯកសារអង់គ្លេស។

**ប្រធានអង្គជំនុំ៖**

យកឯកសារក្រដាសពីមេធាវីជាភាសាអង់គ្លេសជូនអ្នកជំនាញពិនិត្យ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមបង្ហាញឯកសារនេះតាមអេក្រង់នៅត្រង់លេខ ERN

00003142 ជាភាសាខ្មែរ, ជាភាសាអង់គ្លេស 00182814, ជាភាសាបារាំង 00224367។ សូមលោកសាស្ត្រាចារ្យពិនិត្យទៅលើចំណុចទី២។ បើលោកពិនិត្យហើយ បាទ សូមអញ្ជើញ។ លោកពិនិត្យហើយ ខ្ញុំនឹងតាំងសំណួរដល់លោក។

**សួរដោយលោក គង់ សំអុន៖**

**ស៖** តាម -- ខ្ញុំសូមតាំងសំណួរដូចតទៅ។ តាមបទពិសោធន៍របស់លោក ក្នុងខ្លឹមសារនេះ តើលោកយល់ដូចម្តេចដែរ?

[១៥:៣៤:១០]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំលើកដៃ ដោយសារតែលោកបាននិយាយចំណុចទី២។ វាមានចំណុចពីរនេះ ២៥ចំណុចឯណោះ។ ខ្ញុំមិនដឹងថាចំណុចមួយណា។ ខ្ញុំបានលើកឡើងចំណុចនេះរួចមកហើយនៅក្នុងប្រតិចារឹកតាមការសន្និដ្ឋានរបស់ខ្ញុំនោះ។ នៅពេលដែល ប៉ែន យៀវនិន និងខ្ញុំ ចន្ទ ប៊ួ ព្យាយាមប្រមូលឯកសារ យើងបានលើកឡើងចំណុចនេះមុននៅក្នុងសៀវភៅ ដោយសារតែយើងគិតថាវាជាចំណុចមួយដែលចាប់អារម្មណ៍។ វាជាឯកសារពាក់ព័ន្ធទៅនឹងថ្នាក់ដឹកនាំនៅក្នុងប្រទេសដែលនិយាយទៅកាន់ខ្លួនឯង ឬក៏ធ្វើការពិភាក្សាសន្ទនាគ្នារវាងនិងគ្នា។ យើងមានចំណុចនេះជាច្រើន មានសរសេរជាច្រើននៅក្នុងឯកសារបណ្ណសារ។ អ្វីដែលលើកឡើងនៅក្នុងឯកសារនេះ ដោយសារចំនួនមនុស្សចូលរួមនៅក្នុងនេះតិច គឺយើងគិតថា នេះជាការលើកឡើងនៅក្នុងអង្គប្រជុំ ហើយបានសម្រេច។ ដូច្នេះនៅពេលនោះដែលមាន ប៉ុល ពត ជាប្រធាន។ ដូច្នេះហើយ គឺព័ត៌មានទាំងអស់នេះត្រូវបានបញ្ជូនទៅវិញទៅមក។ ខ្ញុំគិតថា ព័ត៌មាននៅក្នុងនេះ គឺត្រឹមត្រូវ ហើយវាជាព័ត៌មានមួយមិនខុសទេនៅក្នុងឯកសារនេះ។

[១៥:៣៥:៤៤]

**ស៖** បាទ សូមអរគុណ។ សូមអធ្យាស្រ័យ ដើម្បីជាកំណត់ត្រា ខ្ញុំបាទសូមអានចំណុចនេះ។ ចំណុចទីពីរ ការពិតទៅខ្ញុំបានផ្តល់លេខទំព័រជា ERN ហើយប៉ុន្តែដោយសារ -- ប្រហែលជាលោកមិនទម្លាប់ ចំពោះលេខERN។ អ៊ីចឹងបានលោកសាក្សីស្វែងរកលេខពីរផ្សេងទៀត។ បាទ សូមអធ្យាស្រ័យ។

"សមមិត្តលេខា លៃពេលជួបបរទេសតែប៉ុន្មានថ្ងៃក្នុងមួយខែ ក្រៅពីប៉ុន្មានថ្ងៃនេះ គិតគូរការងារបក្ស និងការងារមូលដ្ឋាន"។ អានេះជាវិធានការ -- សូមបិទវិញ។ នេះជាវិធានការដំណោះស្រាយទាក់ទងទៅនឹងតួនាទីរបស់នាយករដ្ឋមន្ត្រីនិងរដ្ឋាភិបាល។ អ៊ីចឹងតាមសម្តីរបស់លោកអម្បាញ់មិញ តើ

លោកយល់ថា សមមិត្តលេខា លោកស្គាល់ -- ខ្ញុំជឿហើយថា លោកស្គាល់ហើយថា សមមិត្តលេខានេះ គឺ សំដៅទៅដល់ ប៉ុល ពត។ ថាតើគាត់មានឥទ្ធិពលនៅក្នុងបក្សខ្លាំងជាងនៅក្នុងរដ្ឋាភិបាល ឬមួយយ៉ាង ដូចម្តេច?

**ឆ៖** ជាថ្មីម្តងទៀត ចំណុចនេះខ្ញុំក៏បានឆ្លើយរួចមកហើយដែរ។ ខ្ញុំគិតថា ចម្លើយរបស់ខ្ញុំបាន បញ្ជាក់ហើយ គ្មានខុសគ្នារវាងតួនាទីរបស់គាត់នៅក្នុងរដ្ឋាភិបាលនិងនៅក្នុងបក្សនោះឡើយ។ ចំណុចពីរ ហ្នឹងវាពាក់ព័ន្ធគ្នា។ ខ្ញុំគិតថា -- គាត់គិតថាការងាររបស់គាត់នៅក្នុងបក្សគាត់មិនត្រូវចែករំលែកទៅដល់ អ្នកបុគ្គលខាងក្រៅនោះទេ។ ហើយវាមានលក្ខណៈសំខាន់ជាងការងារនៅក្នុងរដ្ឋាភិបាលដូចជា ការងារ ជួបអ្នកជនបរទេសជាដើមនោះ។ ខ្ញុំគិតថា ការងារដែលបុគ្គលនេះធ្វើនៅក្នុងបក្សនោះ វាមានលក្ខណៈ សំខាន់។ ដូចនៅក្នុងនេះ គេថា "លៃពេលជួបបរទេសតែប៉ុន្មានថ្ងៃក្នុងមួយខែ"។ ខ្ញុំគិតថា ពាក្យថា "ប្រទេស" នោះអត់មានបកប្រែនៅក្នុងនេះទេ។ ដូច្នេះហើយ ខ្ញុំគិតថា វាមានពេលវេលាដែលគេបញ្ជាក់ យ៉ាងច្បាស់លាស់ថា ត្រូវធ្វើការងារហ្នឹងយ៉ាងម៉េច។

[១៥:៣៨:៤០]

**ស៖** បាទ សូមអរគុណ។ សូមលោកមេត្តាពិនិត្យទៅទំព័រខាងដើម ខាងលើនៅត្រង់លេខ ERN 00003141 ជាភាសាខ្មែរ និងជាភាសាអង់គ្លេស 00182813។ ចំណុចនេះមានជាប់ពីរទំព័រ អ៊ីចឹងទំព័រ មួយទៀត គឺ 00182814 ជាភាសាអង់គ្លេស, ជាភាសាបារាំង 00224366។ ត្រង់គណៈប្រធានរដ្ឋ ដែលខ្ញុំបានឃាត់លោកទុកអម្បាញ់មិញថាមិនទាន់ពិភាក្សា ឥឡូវខ្ញុំនឹងលើកយកមកពិភាក្សានៅពេលនេះ។ លោកមើលឃើញហើយឬនៅ?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំមើលឃើញហើយ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំសូមតាំងសំណួរ។ តើលោកស្គាល់ឈ្មោះទាំងអស់នៅក្នុង គណៈប្រធានរដ្ឋនេះទេ? ទីមួយមានប្រធាន សមមិត្ត ហែម បន្ទាប់មកទៀតអនុប្រធានទីមួយៈ ប៉ែន នុត អនុប្រធានទីពីរ សមមិត្ត ញឹម។ តើលោកស្គាល់ឈ្មោះទាំងបីនាក់នេះទេ?

**ឆ៖** ខ្ញុំស្គាល់ ខៀវ សំផន គឺជាឈ្មោះ ហែម នេះ ហើយ ប៉ែន នុត នេះគឺជាអតីតនាយករដ្ឋ មន្ត្រីនៅក្នុងសម័យ សីហនុ។ ចំពោះ ញឹម ខ្ញុំត្រូវតែៗពិនិត្យមើលឡើងវិញ ថាតើនរណាគេជាសមមិត្ត ញឹម។ ពាក្យថា "សមមិត្ត" ដែលថានៅពីមុខឈ្មោះរបស់គាត់នោះ គឺបានន័យថាគាត់ជាសមាជិករបស់ បក្សកុម្មុយនីស្តកម្ពុជា។

**ស៖** បាទ សូមអរគុណ។ លោកមានកត់សម្គាល់ឃើញ ហេតុអីបានជាឈ្មោះ ប៉ែន នុត អត់មានដាក់ថា សមមិត្ត?

[១៥:៤១:៤១]

**ឆ៖** តើលោកចង់សួរថាយ៉ាងម៉េច? ឬក៏ខ្ញុំអត់ដែលឃើញពាក្យថា សមមិត្តហ្នឹងពីមុនមក ឬក៏ខ្ញុំយ៉ាងម៉េចបាទ សំណួរ? ខ្ញុំដូចជាចាប់អត់បានបាទ។

**ស៖** បាទ ខ្ញុំចង់សួរថា ក្នុងពេលឥឡូវនេះដែលលោកបានឃើញនៅក្នុងអត្ថបទនេះ ហេតុអ្វីបានជា ប៉ែន នុត ហ្នឹង ឈ្មោះ ប៉ែត នុត ហ្នឹងអត់មានដាក់ដាក់ថាសមមិត្ត។ តើលោកយល់យ៉ាងដូចម្ដេចដែរ? អាចធ្វើការពន្យល់ដល់ក្រុមប្រឹក្សាជំនុំជម្រះបានដែរទេ?

**ឆ៖** ចម្លើយនោះ គឺថាវាច្បាស់លាស់ណាស់ បុគ្គលនេះគឺជាប់ពាក់ព័ន្ធនឹងរបប សីហនុ សម្ដេច សីហនុ ហើយដូច្នេះហើយ គឺគាត់អត់មានសរសេរសមមិត្ត។ ដូច្នេះបើគាត់អត់មានពាក្យថា សមមិត្ត ពីខាងមុខនោះ បានន័យថាគាត់ជាអ្នកខាងក្រៅ មិនមែនជាសមាជិករបស់បក្ស។ ខ្ញុំគិតថា គេបានលើចំណុចនេះយ៉ាងជាក់លាក់នៅក្នុងឯកសារជាលក្ខណៈឯកជននេះ គេមិនចង់ឲ្យតម្លៃទៅលើបុគ្គលនេះ។ ពាក្យថាសមមិត្តនេះ គឺគេកំណត់ទៅលើបុគ្គលមួយជាក់លាក់ណាស់។

**ស៖** បាទ សូមអរគុណ។ តើលោកអាចស្គាល់ថា អ្នកទាំងបីនាក់ហ្នឹងមានអ្នកណាជាសមាជិករបស់គណៈអចិន្ត្រៃយ៍ដែរទេ?

[១៥:៤៣:៤៦]

**ឆ៖** ខៀវ សំផន គឺជាសមាជិកក្នុងចំណោមអ្នកទាំងបីនេះ។ ប៉ែន នុត មិនដែលក្លាយជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជានោះទេ។ ញឹម នេះសមមិត្ត ញឹម នេះ ខ្ញុំត្រូវតែពិនិត្យមើលឡើងវិញ ថាតើអ្នកណាគេ ហើយខ្ញុំអាចប្រាប់ថ្ងៃស្អែកបាន។ ខ្ញុំមិនអាចឆ្លើយថាសមាជិក ថា ញឹម នេះគឺជាសមាជិករបស់គណៈអចិន្ត្រៃយ៍ឬក៏យ៉ាងណានោះទេ។ យើងដឹងហើយថា គណៈប្រធានរដ្ឋនេះគឺឯកសារនេះគឺជាឯកសារមួយសម្ងាត់។ ដូច្នេះហើយ គឺគេមិនអាចផ្សព្វផ្សាយផ្ដេសផ្ដាសនោះទេ។ ហើយចំណុចទាំងអស់នេះ គឺវាពាក់ព័ន្ធទៅនឹងតួនាទីសំខាន់របស់បុគ្គល។

**ស៖** សូមអរគុណ។ ខ្ញុំបាទ សូមបញ្ជាក់សាឡើងវិញ ព្រោះអំមិញខ្ញុំស្ដាប់តាមរយៈការបកប្រែភាសា ថាពាក់ព័ន្ធជាសមាជិកភាពរបស់បក្ស។ ប៉ុន្តែសំណួររបស់ខ្ញុំ គឺសំដៅទៅលើសមាជិករបស់គណៈអចិន្ត្រៃយ៍។ អ៊ីចឹងចម្លើយរបស់លោកអម្បាញ់មិញបានឆ្លើយទៅលើសមាជិកគណៈអចិន្ត្រៃយ៍ ឬ

ក៏សមាជិករបស់បក្ស?

[១៥:៤៥:១៣]

**ឆ៖** ខ្ញុំគិតថា សំណួររបស់លោកពាក់ព័ន្ធទៅនឹងសមាជិកគណៈអចិន្ត្រៃយ៍។ ខ្ញុំត្រូវតែនិយាយឲ្យឃើតៗ ដោយសារតែអ្នកបកប្រែត្រូវបញ្ជប់ចំណុចនេះ។ ខ្ញុំគិតថា គេកត់នូវប្រតិចារឹករួចមកហើយ។ ខ្ញុំគិតថា សមមិត្ត ហែម នេះគឺទំនងជាមិនមែនជាសមាជិកនៅក្នុងគណៈអចិន្ត្រៃយ៍នោះទេ។ ប៉ែន នុត នោះគឺជាបុគ្គលមួយខាងក្រៅ មិនមែនជាសមាជិកនោះឡើយ។ ខ្ញុំសូមអធ្យាស្រ័យ ហើយខ្ញុំសូមទោសផងចំពោះអ្នកបកប្រែ។

[១៥:៤៥:៥៦]

**ស៖** បាទ សូមអរគុណ។ ខ្ញុំអាចតាំងសំណួរលោកពាក់ព័ន្ធទៅនឹងកិច្ចការរបស់គណៈប្រធានរដ្ឋនេះបានទេ? លោកអាចឆ្លើយពាក់ព័ន្ធនឹងគណៈប្រធានរដ្ឋនេះបាន ទាក់ទងនឹងការងារ ដំណើរការស្ថាប័ន ជារចនាសម្ព័ន្ធផ្សេងទៀត ជាលក្ខណៈលម្អិត។ តើលោកអាចផ្តល់សក្ខីកម្មបានទេ?

**ឆ៖** ខ្ញុំឆ្លើយ សូមឆ្លើយថា ខ្ញុំមិនដឹងទេចំពោះចំណុចនេះ។ ហើយខ្ញុំមិនយកចំណុចនេះមកធ្វើការតវ៉ានៅក្នុងនេះទេ ក៏ប៉ុន្តែខ្ញុំមិនដឹងចំពោះចំណុចនេះទេ។ ខ្ញុំមិនអាចឆ្លើយចំពោះសំណួរនេះទេ។

**ស៖** បាទ សូមអរគុណ។

**លោក គង់ សំអុន៖**

សូមអធ្យាស្រ័យលោកប្រធាន អម្បាញ់មិញដោយសារតាមភាសាបារាំងបានឮថា លោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ ឆ្លើយថា ខៀវ សំផន ជាសមាជិកគណៈអចិន្ត្រៃយ៍។ ក៏ប៉ុន្តែជាភាសាខ្មែរនៅពេលដែលខ្ញុំសួរបញ្ជាក់នេះ គឺគាត់បានឆ្លើយបញ្ជាក់ច្បាស់ហើយថា មិនមានទេ បាទ។

[១៥:៤៨:១៤]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បើសិនជាលោកសាស្ត្រាចារ្យចង់បន្ថែមអាចបន្ថែមបាន។

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ចម្លើយចុងក្រោយរបស់ខ្ញុំ គឺខ្ញុំស្តាប់តែភាសា តែមួយភាសានោះទេ។ ដូច្នេះខ្ញុំមិនអាចដឹងភាសាផ្សេងយ៉ាងណានោះទេ។ ខ្ញុំមិននិយាយថា គាត់មិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍នោះទេ។ ក៏ប៉ុន្តែ ប៉ែន នុត មិនមែនជាសមាជិកអចិន្ត្រៃយ៍នោះទេ។ រស់ ញឹម នោះ អ៎! ចំពោះ ញឹម នេះគឺថាខ្ញុំ

មិនដឹងថាគាត់ជាសមាជិកគណៈអចិន្ត្រៃយ៍ ឬក៏យ៉ាងណានោះទេ។ ហើយចំពោះ ខៀវ សំផន នេះ គឺគាត់ជាសមាជិកអចិន្ត្រៃយ៍។

**ស៖** សូមអធ្យាស្រ័យ សូមបញ្ជាក់ម្ដងទៀត។ លោកថា លោក ខៀវ សំផន ជាសមាជិកអចិន្ត្រៃយ៍ មានន័យថាម៉េច?

[១៥:៤៩:២១]

**ឆ៖** គាត់គឺជាសមាជិកគណៈអចិន្ត្រៃយ៍។

**ស៖** តើលោកអាចមានអ្វីបង្ហាញអំពីសមាជិកភាពរបស់លោក ខៀវ សំផន នេះទេ?

**ឆ៖** ខ្ញុំអធ្យាស្រ័យ ដែលខ្ញុំមើលកំណត់ត្រារបស់ខ្ញុំឡើងវិញ។ សំណួរខាងមុនហ្នឹងគឺថា ពាក់ព័ន្ធទៅនឹងគណៈមជ្ឈិម ឬក៏គណៈ -- ឬក៏សមាជិកបក្ស ដូច្នេះហើយ គឺយើងត្រូវតែបែងចែកឲ្យបានច្បាស់លាស់ ហើយខ្ញុំគិតថា លោកមិនមានចេតនាណាមួយ សួរមកខ្ញុំទៅលើចំណុចនេះនោះទេ។ យើងដឹងហើយថា ចំពោះសមាជិកភាពកាលបរិច្ឆេទនោះ គឺខ្ញុំបានបញ្ជាក់យ៉ាងច្បាស់លាស់ហើយ ទៅលើកាលបរិច្ឆេទចំនួនពីរ ដែលខ្ញុំបានបញ្ជាក់ជូនលោករួចមកហើយ។ គឺខ្ញុំបានបញ្ជាក់ហើយ អំពីកាលបរិច្ឆេទគាត់ក្លាយជាសមាជិកនៃគណៈមជ្ឈិម ឬក៏សមាជិកគណៈមជ្ឈិមត្រៀមនោះទេ ដូចដែលខ្ញុំបានបញ្ជាក់អ៊ីចឹង គឺថាខ្ញុំដកស្រង់មកចេញពីប្រភព លេខជើងទំព័រ៤៤៣៥ ចេញពីដីកាដំណោះស្រាយជាដើម។ ខ្ញុំសូមអធ្យាស្រ័យ ប្រសិនបើមិនច្បាស់ចំពោះលោក។

[១៥:៥១:០០]

**ស៖** បាទ សូមអរគុណ។ តើលោកអាចជម្រាបអំពីដំណើរការរបស់គណៈអចិន្ត្រៃយ៍ ហើយនិងគណៈមជ្ឈិម មានលក្ខណៈខុសគ្នាដូចម្ដេចដែរ?

**ឆ៖** ជាថ្មីម្ដងទៀត។ ប្រហែលជាម៉ោងនេះគឺវា យឺតហើយ ដប់នាទីខ្វះម៉ោងបួននេះ។ ខ្ញុំអាចបញ្ជាក់នៅថ្ងៃស្អែកបាន មិនមែនខ្ញុំគេចពីការឆ្លើយនោះទេ។ ការងារខុសគ្នារវាងគណៈកម្មាធិការទាំងពីរនោះ គឺថាគណៈកម្មការមួយនោះ គឺមានការងារច្រើន និងធំជាងគណៈកម្មការមួយទៀត។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ យើងត្រូវគិតទៅលើចំណុចនេះ យើងឃើញថា សមាជិកមួយចំនួនជាសមាជិកគណៈមជ្ឈិម តែក៏មិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍នោះទេ។ ចំពោះសមាជិកនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍នោះ មានប្រហែលជា២០នាក់ ហើយអ្នកដែលជាសមាជិកនៅក្នុងគណៈមជ្ឈិមនោះ គឺជាអ្នកដែលមានឋានៈខ្ពស់ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ និងមានសេចក្ដីស្មោះស្ម័គ្រចំពោះបក្ស។ ក៏ប៉ុន្តែតាម

ប្រវត្តិសាស្ត្រយើងឃើញថា បុគ្គលមួយចំនួននៅក្នុងនោះគឺជាអ្នកដែលពាក់ព័ន្ធទៅនឹងការកាប់សម្លាប់។

ដូច្នេះស្ថាប័ន ឬក៏មន្ទីរទាំងឡាយនៅក្រោមគណៈអចិន្ត្រៃយ៍នោះគឺ ទទួលបញ្ជាពីគណៈអចិន្ត្រៃយ៍ ហើយជាអ្នកដំណើរប្រតិបត្តិការនៅក្រោមការគ្រប់គ្រងរបស់គណៈអចិន្ត្រៃយ៍។ យើងឃើញថា ថ្នាក់ក្រោមៗនោះគឺ ទទួលការណែនាំពីគណៈអចិន្ត្រៃយ៍។ នេះជាអ្វីដែលយើងយល់ទៅតាមប្រវត្តិសាស្ត្ររបស់បក្ស។ គណៈមជ្ឈិម គឺគេមិនអាចលើកឡើងថា អូ! យើងត្រូវតែធ្វើអ៊ីចេះ មិនត្រូវធ្វើដូច្នោះនោះឡើយ ក៏ប៉ុន្តែគឺសមាជិកគណៈមជ្ឈិមមួយចំនួន មានការស្មោះស្ម័គ្រទៅនឹងបក្ស។ នៅពេលដែលយើងមើលកំណត់ហេតុរបស់ការប្រជុំគណៈអចិន្ត្រៃយ៍ គឺមិនមានការចែកចាយទៅដល់អ្នកនៅខាងក្រៅនោះទេ។

[១៥:៥៣:៣៨]

ឯកសារកម្ពុជាប្រជាធិបតេយ្យមួយចំនួន ដែលនៅសល់នោះគឺបានបង្ហាញឲ្យយើងឃើញទៅនឹងចំណុចហ្នឹង។ ហើយហេតុអ្វីបានជាគេមិនចែកជូនទៅដល់បុគ្គលផ្សេងនៅក្នុងភូមិភាគ ស្រុក ឬក៏តំបន់នោះ? ក៏ប៉ុន្តែត្រឡប់មកវិញ គឺថាគណៈកម្មាធិការមួយ វាមានលក្ខណៈធំជាង និងការងារច្រើនជាងគណៈកម្មការមួយទៀត។ ជាថ្មីម្ដងទៀត ខ្ញុំគិត ខ្ញុំត្រូវតែទៅមើលលម្អិតជាមុនសិនទៅលើចំណុចហ្នឹង។ យើងឃើញថា ការប្រជុំសំខាន់ៗរបស់គណៈមជ្ឈិមនោះ គឺគេអនុញ្ញាតឲ្យសមាជិកគណៈអចិន្ត្រៃយ៍ចូលប្រជុំជាមួយផងដែរ ដើម្បីកុំឲ្យមានការអនុវត្តផ្ទុយទៅនឹងការណែនាំរបស់ ប៉ុល ពត។ ដូច្នេះហើយគឺការប្រជុំមួយចំនួនសំខាន់នោះ គេឲ្យមានការចូលរួមពីគណៈអចិន្ត្រៃយ៍ ដើម្បីឲ្យទទួលបានព័ត៌មានសម្រាប់យកមកអនុវត្តការងារ។

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញ ខ្ញុំបានស្ដាប់ឮថា លោកមានប្រសាសន៍ថា គណៈអចិន្ត្រៃយ៍មានសមាជិក២០នាក់។ តើលោកនិយាយថា គណៈអចិន្ត្រៃយ៍ ឬមួយក៏ជាគណៈមជ្ឈិម?

**ឆ៖** លោកបានស្ដាប់ថា ខ្ញុំឆ្លើយនៅពេលនេះ មានការបកប្រែហ្នឹងវាមានបញ្ហា។ នោះគឺថាសមាជិក២០នាក់នោះ ក្នុងគណៈ -- ២០រូប នៅក្នុងគណៈមជ្ឈិម ហើយគណៈអចិន្ត្រៃយ៍ហ្នឹងតូចជាង។ ខ្ញុំមិនបាននិយាយថា បែបនោះ ដូចដែលលោកថានោះទេ។

[១៥:៥៥:៣៤]

**ប្រធានអង្គជំនុំ៖**

បាទៗ អរគុណច្រើន។ ហើយបញ្ហានេះ មកពីការបកប្រែ។ សូមបកប្រែមានការប្រុងប្រយ័ត្ន

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

នូវការប្រើពាក្យទាំងអស់នេះ។ ពាក្យ "គណៈកម្មាធិការមជ្ឈិម" ហើយនិងពាក្យ "គណៈកម្មាធិការអចិន្ត្រៃយ៍" ឬក៏ "គណៈអចិន្ត្រៃយ៍"នេះ។ សូមប្រើប្រាប់ឲ្យបានមានការប្រុងប្រយ័ត្ន ចៀសវាងមានការភ័ន្តច្រឡំ ហើយធ្វើឲ្យមានការច្របូលច្របល់នៅក្នុងការតាំងសំណួរ ក៏ដូចជាការឆ្លើយរបស់អ្នកជំនាញ។ យើងកត់សម្គាល់ឃើញថា បញ្ហានេះ វាអាចកើតឡើងបណ្តាលមកពីការបកប្រែ ឬក៏មកអ្នកជំនាញផ្តល់ព័ត៌មាន ទៅឲ្យអ្នកបកប្រែដោយសារតែមានការភ័ន្តច្រឡំទេ។ ប៉ុន្តែជាភាសាខ្មែរដែលបានបកប្រែមកគឺពិតជា មានការភ័ន្តច្រឡំរវាងពាក្យពេចន៍ ដែលប្រើប្រាស់ក្នុងនាមជា -- រវាងគណៈអចិន្ត្រៃយ៍ ហើយនិងគណៈ មជ្ឈិមពិតប្រាកដ។ ម្តង គឺនិយាយអំពីគណៈអចិន្ត្រៃយ៍ទៅ ហើយម្តងថាជា គណៈមជ្ឈិម។ ឧទាហរណ៍ដូចជា ខៀវ សំផន ម្តងថាជាសមាជិកមជ្ឈិម ហើយម្តងទៀតថាសមាជិកអចិន្ត្រៃយ៍ អីអ៊ីចឹងទៅ នាំឲ្យមានបញ្ហា។

[១៥:៥៦:៤៧]

ហើយសំណួរច្រំដែល សំណួរដដែលៗនេះ តាមការពិនិត្យជាក់ស្តែងក្នុងការសិក្សា ក៏ដូចជាការអនុវត្តវាកើតឡើងដោយសារបញ្ហាអី បានជានៅក្នុងនីតិវិធីព្រហ្មទណ្ឌ គេហាមមិនឲ្យសួរច្រំដែល។ កាលណាបើសួរច្រំដែល ទីមួយ វាខាតពេលអត់ប្រយោជន៍ រឿងដដែល។ ទីពីរ រឿងដដែលនេះ វាអាចធ្វើឲ្យចម្លើយខុសគ្នា។ រវាងចម្លើយទីមួយ ទីពីរ ទីបី។ អ៊ីចឹង ធ្វើឲ្យការគិតពិចារណាលើលទ្ធផលនៃការតាំងសំណួរច្រំដែលនេះ វាកើតនូវភាពច្របូលច្របល់ចំពោះអង្គជំនុំជម្រះដែលទទួលខុសត្រូវក្នុងការពិនិត្យពិចារណា វាយតម្លៃនូវភស្តុតាងលើស្ថានភាពចុងក្រោយនៃសំណុំរឿងទាំងមូល ដើម្បីវិនិច្ឆ័យនោះ វាច្របូលច្របល់។ អ៊ីចឹង សូមឲ្យមានការប្រុងប្រយ័ត្ន ហើយសូមស្នើភាគី ហើយនិងលោកអ្នកជំនាញសូមបន្ធូរបន្ថយនូវការនិយាយញាប់ផង ដើម្បីឲ្យការបញ្ជាក់លើបញ្ហាចំណុចទាំងអស់នេះឲ្យកាន់តែច្បាស់លាស់ ចៀសវាងមានការច្របូលច្របល់ ដូចអម្បាញ់មិញនេះ គឺនឹងអាចខាតពេលអត់ប្រយោជន៍ ហើយធ្វើឲ្យមានការច្របូលច្របល់ដល់ប្រតិចារឹកទៀតផង ការពិនិត្យទៅថ្ងៃក្រោយ នឹងជួបប្រលយមនឹងលំបាកជាមិនខាន។ លោកអាចមានសំណួរអីផ្សេងទៀតទេ សូមអញ្ជើញបន្ត អាចពីរសំណួរអីទៀតយ៉ាងច្រើន។

[១៥:៥៨:០៧]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសូមសួរខ្លីទេ ទាក់ទងទៅនឹងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក។ តើលោកបានសិក្សាស្រាវជ្រាវពីរឿងនេះទេ? អម្បាញ់មិញនេះ ខ្ញុំបានឮលោកមេធាវីរបស់លោក អៀង សារី បានសាកសួរមួយចំនួនហើយ ហើយខ្ញុំក៏ចង់សួរបញ្ជាក់ តើអំពីចំនួនគ្រាប់បែកដែលសហរដ្ឋអាមេរិកបានទម្លាក់ក្នុងសម័យមុនកម្ពុជាប្រជាធិបតេយ្យនោះ។ តើលោកមានបានដឹងថាមានចំនួនប៉ុន្មានដែរទេ?

**លោក ផេរីង ផេនដ័ល័រ៖**

**ឆ៖** ខ្ញុំមិនមានតួលេខច្បាស់ទេ គឺថាមានរាប់រយពាន់តោន។ ខ្ញុំចង់មើលតួលេខឲ្យច្បាស់ ការរកឃើញ មានឆ្នាំ១៩៧៩ នោះ ការប៉ាន់ប្រមាណ គឺថាច្រើនជាងទម្លាក់ទៅជប៉ុនទៀត។ ពេលថ្មីៗនេះ យើងបានពិភាក្សានៅក្នុងសំណួរដែលសួរអំពីការទម្លាក់គ្រាប់បែកនោះ គឺថា ដែលថារកទៅឃើញកម្រិតខ្ពស់ជាង។ ខ្ញុំឆ្លើយនៅក្នុងចម្លើយនោះ គឺថាបញ្ហាដែលខ្ញុំថាចំនួនច្រើនហ្នឹង គឺមិនអាចទុកចិត្តបានទេ គឺថាដោយសារថាមិនមានអ្វីបញ្ជាក់ពីប្រភពឲ្យច្បាស់ដែលថា ការបោះពុម្ពផ្សាយតួលេខនេះ ហើយខ្ញុំរង់ចាំនូវអ្វីដែលចេញមកពីប្រភព ដែលអាចជឿទុកចិត្តបាន ដែលថាវាមានប្រភពដែលអាចយោងបាន ដែលថាធ្វើឲ្យខ្ញុំយល់ថា វាអាចទៅរួច ប៉ុន្តែគឺថាច្រើនពាន់បន្ថែមទៀត ទម្លាក់នៅកម្ពុជានោះ។ ការខូចខាតនោះ គឺថាអាចធ្ងន់ធ្ងរជាងអ្វីដែលយើងស្មាន ដែលយើងគិតទុក។ ខ្ញុំមិនមានតួលេខរាប់តោនប៉ុន្មានទេ បើគ្រាន់តែច្រើនរយពាន់តោន។ អ្វីដែលខ្ញុំអាចឆ្លើយ។ ប៉ុន្តែមិនខ្ពស់ មិនច្រើនជាងអ្វីដែលទម្លាក់នៅវៀតណាមទេ ដែលថាច្រើនជាជប៉ុន គឺថាគ្រាន់តែបង្ហាញថាវាមានភាពធ្ងន់ធ្ងរ។ ប៉ុន្តែ ហើយប្រហែលជាង១០ឆ្នាំជាងដែលទម្លាក់នៅប្រទេសវៀតណាមនោះ គឺគ្រាន់ធ្វើម៉េច គឺបំបាក់ស្មារតី ទឹកចិត្តរបស់កងទ័ពគេ ទាហានរបស់គេនោះ។ អ៊ីចឹងហើយលោកអាចផ្តោះគំនិតដែលខ្ញុំបញ្ជាក់ខាងក្រោយនេះ។ គឺថានេះគឺជាឧបទ្ទវហេតុដ៏គួររន្ធត់និយាយពីរឿងការទម្លាក់គ្រាប់បែកនេះ។ គឺថាមានរាប់រយពាន់តោន។ អ្វីដែលខ្ញុំអាចឆ្លើយប្រាប់លោក គឺបានប៉ុណ្ណឹង។

[១៦:០០:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើនលោកមេធាវី។ ហើយអរគុណយ៉ាងច្រើនអ្នកជំនាញ។ ដោយសារពេលវេលាសមល្មមនឹងសម្រាកហើយសម្រាប់កិច្ចដំណើរការសវនាការថ្ងៃនេះ។

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការ

លើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធទី២៥ ខែកក្កដា ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការថ្ងៃស្អែកនឹងបន្តធ្វើការតាំងសំណួរដេញដោលដោយ -- ចំពោះអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ដោយក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

សូមភាគី និងសាធារណជនជ្រាប!

លោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ ការស្តាប់សក្ខីកម្មរបស់លោកអ្នកជំនាញនៅមិនទាន់ចប់នៅឡើយទេ។ ហើយសវនាការត្រូវបន្តធ្វើនៅថ្ងៃស្អែកទៀត គឺទំនងចំណាយពេលវេលាមួយព្រឹកទៀត។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត។

ហើយមន្ត្រីរដ្ឋបាលតុលាការសមសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ នៅក្នុងការជូនអ្នកជំនាញវិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់ផ្តល់សក្ខីកម្មបន្ទប់សវនាការនេះនៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក អៀង សារី នៅព្រឹកថ្ងៃស្អែកនេះ ប្រសិនបើគាត់បង្ហាញជំហរជាក់ច្បាស់ក្នុងការលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយការលះបង់សិទ្ធិចូលរួមសវនាការតាមរយៈពាក្យសុំលាយលក្ខណ៍អក្សរ ដែលធ្វើតាមរយៈមេធាវីការពារក្តីរបស់គាត់នោះ បានមុនពេលកិច្ចដំណើរសវនាការចាប់ផ្តើម។ សុំឲ្យអនុរក្សមន្ទីរឃុំឃាំងទំនាក់ទំនងសួរព័ត៌មានជាមួយនឹងក្រឡាបញ្ជីសវនាការជាមុន និងឲ្យនាំគាត់មកនៅត្រឹមបន្ទប់ខាងក្រោមដែលរៀបចំនូវឧបករណ៍សោត-ទស្សន៍សម្រាប់គាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ហើយអង្គជំនុំជម្រះនឹងពិនិត្យសម្រេចលើពាក្យសុំរបស់គាត់ជាមុន មុនពេលដំណើរការសវនាការដេញដោលស្តាប់សក្ខីកម្មអ្នកជំនាញ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*